# ជីវិតអាពាហ៍ពិពាហ៍ ប្រកបដោយសុភមង្គល

(តាមបែបទស្សនៈព្រះពុទ្ធសាសនា)

ដោយ

ព្រះតេជព្រះគុណ បណ្ឌិត ក. ស្រីធម្មានន្ទ

ប្រែសម្រួលជាខេមរភាសា

ដោយភិក្ខុ ព្រំ ស៊ីណា

ព.ស ២៥៤៨ គ.ស ២០០៤

# HAPPY MARRIED LIFE

by

**Ven. Dr. K. Sri Dhammananda**

Translated from English into Khmer by

Bhikkhu Prum Sina
*(Sañjātavīviyo)*

B.C. 2548 A.D. 2004

# ជីវិតអាពាហ៍ពិពាហ៍

# ប្រកបដោយ

# (តាមបែបទស្សនៈព្រះពុទ្ធសាសនា) សុភមង្គល


ដោយ

ព្រះតេជព្រះគុណ បណ្ឌិត ក. ស្រីធម្មានន្ទ

ប្រែសម្រួលជាខេមរភាសា

ដោយភិក្ខុ ព្រំ ស៊ីណា



ព.ស ២៥៤៨ គ.ស ២០០៤

# អារម្ភកថា

ចាប់តាំងពីសម័យបរមបុរាណមក មនុស្សរវីរវល់មិនទំនេរការងារ ដើម្បីស្វែងរកសុភមង្គលនៅក្នុងជីវិត តាំងពីកើតរហូតដល់ស្លាប់។ គេធ្វើការងារនិងព្យាយាមតស៊ូយ៉ាងខ្លាំង ដើម្បីឈានទៅរកសុភមង្គល ជារឿយៗ ដោយមិនបានស្គាល់ពិតប្រាកដពីអ្វីដែលហៅថាសុភមង្គលនោះផង ពីព្រោះតែអវិជ្ជាអំពីធម្មជាតិនៃជីវិត។ ទោះបី សាសនាទាំងអស់ផ្តល់ដំបូន្មាននិងការណែនាំផ្លូវអ្នកកាន់លទ្ធិរបស់គេ ឱ្យប្រតិបត្តិដើម្បីសម្រេចបានសុភមង្គលនៅក្នុងជីវិត ជារឿយៗគេមិនអើពើនឹងដំបូន្មាននិងការណែនាំទាំងនេះ ពីព្រោះតែតណ្ហា ទោសៈ និងមោហៈរបស់មនុស្ស។ មនុស្សជាច្រើនដែលធ្លាប់ខកចិត្ត ខូចចិត្ត និងទទួលរងទុក្ខវេទនា សង្ឃឹមនិងបួងសួងរកសេចក្តីសុខសម្រាប់ជីវិតបច្ចុប្បន្ននិងបរលោក អ្នកដទៃផ្សេងទៀត ទោះបីគាប់នឹងសេចក្តីសុខធំសម្បើមនៅលើផែនដីនេះ ក៏នៅតែមិនគាប់ចិត្ត ហើយចង់បានសេចក្តីសុខនោះនៅក្នុងឋានសួគ៌ បន្ទាប់ពីលាចាកលោកនេះទៅ។ សម្រាប់មនុស្សសាមញ្ញ ក្នុងសភាពដូចកូនក្មេងដែរ ជាការពិបាកថែកឱ្យដាច់ពីគ្នារវាងសុភមង្គល និងសេចក្តីសប្បាយរីករាយ។ ចំពោះមនុស្សបែបនេះហៅថា អ្វីដែលសេចក្តីសប្បាយរីករាយ ផ្តល់សុភមង្គល ហើយដើម្បីមានសុភមង្គល គឺត្រូវមានសេចក្តីសប្បាយរីករាយ។

ជារឿយៗ យើងតែងតែហៅថាកុមារភាព ជាពេលវេលាដែលមាន

សុភមង្គល។ តាមពិតក្នុងវ័យជាកុមារ យើងមិនបានដឹងថាអ្វីជាសុភមង្គលនោះទេ។ ក្រោមការថែរក្សាការពារនៃមាតាបិតារបស់យើង យើងឆ្លងកាត់វ័យរបស់យើងនៅក្នុងរង្វង់មិនដែលដាច់ពីការសប្បាយរីករាយ ដែលផ្តល់ឱ្យយើងដោយគ្មានមន្ទិលសង្ស័យ។ ពេលយើងឈានចូលវ័យពេញជំទង់ការផ្លាស់ប្តូរកើតមាននៅក្នុងចិត្តនិងរូបរាងកាយ ដោយបណ្តាលឱ្យយើងមានការយល់ដឹងពីការកើតមាននៃភេទផ្ទុយគ្នា ហើយយើងចាប់ផ្តើមដឹងពីការទាក់ទាញ ដែលបង្កើតឱ្យមានការរំខានអារម្មណ៍។ នៅក្នុងអំឡុងពេលដំណាលគ្នា ការចង់ដឹងចង់ឃើញបង្ខំឱ្យយើងរកឱ្យឃើញភាពពិតនៃជីវិត តាមរយៈការពិភាក្សាជាមួយមនុស្សដែលមានវ័យស្មើគ្នា និងតាមរយៈការអានសៀវភៅ។ មិនយូរប៉ុន្មានយើងដឹងដោយខ្លួនឯងថាកំពុងស្ថិតនៅលើច្រកចូលនៃភាពពេញវ័យ ពេលវេលាសំខាន់នៅក្នុងជីវិតរបស់យើង ពេលយើងស្វែងរកដៃគូរជីវិតសមរម្យ ដើម្បីចាប់ផ្តើមទំនាក់ទំនងដែលនឹងសាកល្បងមើលគ្រប់គុណសម្បត្តិដែលយើងទទួលបានមកផ្ទាល់ខ្លួនពីមុននៅក្នុងជីវិត។ សេចក្តីស្រឡាញ់ ទំនាក់ទំនងផ្លូវភេទ និងអាពាហ៍ពិពាហ៍ បន្ទាប់មកបានក្លាយជាបញ្ហាទាំងឡាយនៃភាពសំខាន់ដ៏ធំធេងដែលនិងកំណត់គុណសម្បត្តិនៃជីវិតអាពាហ៍ពិពាហ៍ដែលយើងនឹងមាន។

សម័យបច្ចុប្បន្ននេះ គេលាតត្រដាងឱ្យយុវជនក្មេងៗដឹងអំពីប្រភេទផ្សេងៗនៃការហូរចូល "វប្បធម៌លោកខាងលិច" ដែលគេផ្សាយតាមរយៈ

បណ្តាញឃោសនាពតិមាន មានដូចជា សៀវភៅទស្សនាវដ្តី ទូរទស្សន៍ កាសែតវិដេអូ និងខ្សែភាពយន្ត ដែលជាលទ្ធផលនៃការទទួលយកគំនិតបំភ្លៃទាំងឡាយ ដោយចាត់ទុកថាជាសេចក្តីស្រឡាញ់ ទំនាក់ទំនងផ្លូវភេទ និងអាពាហ៍ពិពាហ៍។ គុណធមិនិងតម្លៃសីលធមិរបស់ "លោកខាងកើត" ដែលមានតាំងពីបុរាណ ត្រូវបានធ្វើឱ្យសឹករិចរិលជាលំដាប់ ដោយប្រឈមមុខទល់នឹងការហូរចូលទាំងនេះ។ ជំនាន់ចាស់ៗ គេមិនដែលឮនិងមិនបានអនុវត្ត ការប្រព្រឹត្តទាំងឡាយដែលបានក្លាយជារឿងសាមញ្ញក្នុងចំណោមយុវជនក្មេងៗនាពេលបច្ចុប្បន្ននេះ។ តើការហូរចូលនៃ "វប្បធមិលោកខាងលិច" ពិតជាទទួលខុសត្រូវចំពោះស្ថានភាពនៃហេតុការណ៍នេះ ឬតើគេគួរស្តីបន្ទោសមាតាបិតា ចំពោះទង្វើខុសឆ្គងរបស់បុត្រធីតារបស់ពួកគេ ព្រោះបានអនុវត្តការគ្រប់គ្រង និងការត្រួតត្រាមើលកូនចៅរបស់ពួកគេឬទេ? នៅក្នុងសៀវភៅនេះបានពន្យល់ថា កម្មវិធីទូរទស្សន៍និងខ្សែភាពយន្តភាគច្រើន មិនបានបង្ហាញវិធីដែលមនុស្សសមរម្យច្រើនបំផុត នៅក្នុងការគិត ឬការប្រព្រឹត្តិរបស់ពួកលោកខាងលិច ហើយបានពន្យល់ទៀតថាមាន "ចំនួនភាគច្រើនដែលនៅនឹងថ្កល់" ដ៏ធំធេងនៃកំលោះក្រមុំគួរជាទីពេញចិត្តដែលយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងសាសនា និងមានគំនិតអភិរក្សនិយមអំពីសេចក្តីស្រឡាញ់ ទំនាក់ទំនងផ្លូវភេទ និងអាពាហ៍ពិពាហ៍ដូចកំលោះក្រមុំ "លោកខាងកើត"។ បើយុវជនក្មេងៗចង់ធ្វើតាមលោកខាង

លិច ពួកគេត្រូវបានផ្តល់ដំបូន្មានឱ្យធ្វើតាម "ចំនួនភាគច្រើននៅនឹងន" នេះ មិនខុសគ្នាពីអ្នកជិតខាងមុនរបស់គេ ដែលរស់នៅជិតពួកគេឡើយ ។

ជីវិតរស់នៅក្នុងសម័យទំនើប ពោរពេញទៅដោយភាពយ៉ាប់យឺន និងភាពតានតឹងក្នុងខួរក្បាលគ្រប់យ៉ាងទាំងអស់ ។ ជារឿយៗ ភាពយ៉ាប់យឺន និងភាពតានតឹងក្នុងខួរក្បាល វាមុខជាបង្កើតឱ្យមានបញ្ហានៅក្នុងអាពាហ៍ពិពាហ៍ជាច្រើន ។ បើគេធ្វើការវិភាគមួយសមរម្យ ទៅក្នុងហេតុទាំងឡាយជាមូលនៃបញ្ហាសង្គមបែបនេះ ដូចជាទំនាក់ទំនងផ្លូវភេទមុនពេលរៀបអាពាហ៍ពិពាហ៍ ការមានផ្ទៃពោះរបស់យុវវ័យ អាពាហ៍ពិពាហ៍គ្មានសុភមង្គលនិងការលែងលះប្តីប្រពន្ធ ការធ្វើទុក្ខទោសដល់កូន និងការវាយតប់ប្រពន្ធ ដោយចៀសមិនរួចរកឃើញថា សំខាន់គឺបណ្តាលមកពីអត្តទត្ថភាព និងការខ្វះធមិខន្តី ខ្វះសេចក្តីអត់អោនត្រាប្រណី និងការយល់អធ្យាស្រ័យចំពោះគ្នាទៅវិញទៅមកទាំងសងខាង ។ នៅក្នុងសិគាលោវាទសូត្រ ព្រះពុទ្ធទ្រង់សម្តែងទូន្មានឱវាទល្អៗ អំពីវិធីរក្សាភាពស្ងប់ស្ងាត់ និងភាពចុះសម្រុងគ្នា នៅក្នុងផ្ទះរវាងប្តីនិងប្រពន្ធដើម្បីសម្រេចបានជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល ។ ទំនួលខុសត្រូវរបស់ឳពុកម្តាយចំពោះកូន និងកាតព្វកិច្ចរបស់កូនចំពោះមាតាបិតា ក៏មានសម្តែងយ៉ាងច្បាស់លាស់ ល្អិតល្អន់ផងដែរនៅសូត្រនេះ ដើម្បីជាការណែនាំផ្លូវមានប្រយោជន៍ដើម្បីសម្រេចបានសុភមង្គលនៅក្នុងគ្រួសារ ។ នៅក្នុងសៀវភៅនេះ

ព្រះតេជគុណ ជាអ្នកនិពន្ធបានសង្កត់ធ្ងន់ទៅលើចំណុចសំខាន់ដែលថា អាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងនៃបុគ្គលពីររូប។ គេធ្វើឱ្យប្រសើរនិងមានខ្លឹមសារនូវទំនាក់ទំនងនេះ ពេលទំនាក់ទំនងនេះអនុញ្ញាតិឱ្យបុគ្គលិកភាពទាំងឡាយដែលជាប់ពាក់ព័ន្ធលូតលាស់ឡើង។ នៅក្នុងទស្សនវិស័យព្រះពុទ្ធសាសនា អាពាហ៍ពិពាហ៍មានន័យថា ការយល់ដឹងនិងការគោរពជំនឿនិងការសម្ងាត់របស់គ្នាទៅវិញទៅមក។ ពេលបច្ចុប្បន្ននេះ គឺជាឱកាសល្អបំផុតសម្រាប់សៀវភៅស្តីអំពីលក្ខណៈនេះ ត្រូវបានបោះពុម្ពដើម្បីផ្តល់ឱ្យអ្នកកាន់ព្រះពុទ្ធសាសនា ជាពិសេសយុវជនឱ្យយល់កាន់តែច្បាស់ អំពីបញ្ហាសំខាន់ៗរបស់ជីវិត មានដូចជាសេចក្តីស្នេហា ទំនាក់ទំនងផ្លូវភេទ និងអាពាហ៍ពិពាហ៍ ដែលមិនត្រឹមតែជួយពួកគេឱ្យរស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គលប៉ុណ្ណោះទេ ថែមទាំងជួយពួកគេឱ្យដឹកនាំជីវិតដែលប្រកបដោយសុខសាន្តត្រាណ និងមានអារម្មណ៍សប្បាយចិត្តទៀតផង

ក្នុងនាមនៃសមាគមផ្សព្វផ្សាយព្រះពុទ្ធសាសនា ខ្ញុំសូមសម្តែងនូវកតញ្ញូតាធមិ គោរពយ៉ាងជ្រាលជ្រៅ និងការកោតសរសើរ ចំពោះបុគ្គលិកដែលមានភក្តីភាពលះបង់ខ្ពស់របស់យើង ដែលបានជួយ និងបម្រើការ ក្នុងការរៀបចំការបោះពុម្ភសៀវភៅនេះ។

# មាតិការឿង

**ទំព័រ**


១. សេចក្ដីផ្ដើម.....................................................................1

២. ធម្មជាតិនៃសេចក្ដីស្រឡាញ់ និងសេចក្ដីសប្បាយរីករាយ...............4

សេចក្ដីស្រឡាញ់

ទំនាក់ទំនងផ្លូវភេទ

ការពន្យល់ណែនាំរបស់ព្រះសម្មាសម្ពុទ្ធ

សេចក្ដីសប្បាយរីករាយ

៣. សភាពពិតនៃជីវិតអាពាហ៍ពិពាហ៍ .......................................11

បញ្ហា

ការចែករំលែកនិងទំនុកចិត្ត

ងងឹតងងល់ដោយអារម្មណ៍រំភើបចិត្ត

សេចក្ដីត្រូវការផ្នែកសម្ភារៈ

សេចក្ដីណែនាំមុនពេលរៀបអាពាហ៍ពិពាហ៍

៤. ទស្សនៈព្រះពុទ្ធសាសនាអំពីអាពាហ៍ពិពាហ៍ ............................19

តួនាទីរបស់សាសនា

៥. ទេវគ្រោះសាសនា.................................................................23

សិទ្ធិបុគ្គល
ភាពស្រងូតស្រងាត់ក្រោយពេលរៀបអាពាហ៍ពិពាហ៍
ពិធីរៀបអាពាហ៍ពិពាហ៍
៦. សុវត្ថិភាព ការគោរព និង ទំនួលខុសត្រូវ ..............................27
ការស្គាល់អសុវត្ថិភាព
ស្វាមី និង ភរិយា
ឱវាទរបស់ព្រះសម្មាសម្ពុទ្ធចំពោះភរិយាស្វាមី
អតីតកាល
សង្គមសម័យបច្ចុប្បន្ន
ការលែងលះ
ការទទួលខុសត្រូវចំពោះកូន
ទស្សនៈព្រះពុទ្ធសាសនា
៧. ពហុពន្ធភាព ឬ ឯកពន្ធភាព..................................................57
៨. បច្ចេកវិទ្យាថ្មី.....................................................................59
គម្រោងការណ៍គ្រួសារ
ទារកដែលកើតមកដោយសិប្បនិម្មិត
៩. សីលធម៌.............................................................................61
ទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ

ការប្រព្រឹត្តិខុសក្នុងកាម

អត្តចរិតមិនទទួលខុសត្រូវផ្លូវភេទ

១០. បូព៌ាប្រទេស និង បច្ចឹមប្រទេស........................................66

១១. ភាពនៅលីវ..........................................................................70

អ្វីទៅហៅថាភាពនៅលីវ?

សារៈសំខាន់នៃភាពនៅលីវ

ភាពនៅលីវ ទល់នឹង ទំនួលខុសត្រូវ

បទពិសោធន៍របស់ព្រះសម្មាសម្ពុទ្ធ

១២. សេចក្តីសង្ខេប ......................................................................76

បរិសិដ្ឋ

I.) មាតាដែលមានទឹកចិត្តសប្បុរស (ប្រេមវន្តមាតា) ..........82

II.) ក្បួនច្បាប់សីលធម៌ ................................................85

# ១. សេចក្តីផ្តើម

បើតាមទស្សនៈព្រះពុទ្ធសាសនា អាពាហ៍ពិពាហ៍គឺមិនមែនពិសិដ្ឋផងនិងទាំងមិនមែនមិនពិសិដ្ឋផង។ ព្រះពុទ្ធសាសនា មិនបានចាត់ទុកអាពាហ៍ពិពាហ៍ ថាជាកាតព្វកិច្ចផ្នែកសាសនា និងជាការប្រសិទ្ធីឱ្យពរជ័យដែលគេរៀបចំនៅក្នុងឋានសួគ៌នោះក៏ទេដែរ។ មនុស្សដែលមើលឃើញតែអាក្រក់បាននិយាយថា ពេលមនុស្សមួយចំនួនជឿថា អាពាហ៍ពិពាហ៍គឺជាការរៀបចំគម្រោងនៅក្នុងឋានសួគ៌ អ្នកនោះនិយាយថា វាជាការកត់ត្រានៅក្នុងឋាននរកផងដែរ! ជាមូលដ្ឋាន អាពាហ៍ពិពាហ៍គឺជាកាតព្វកិច្ចបុគ្គលនិងសង្គម មិនមែនជាការបង្ខិតបង្ខំបង្គាប់បញ្ជានោះទេ។ ស្ត្រីនិងបុរស ត្រូវតែមានសេរីភាព ទាំងរៀបចំអាពាហ៍ពិពាហ៍ ទាំងនៅលីវ (មិនចង់រៀបការ)។ នេះមិនមែនមានន័យថា ព្រះពុទ្ធសាសនាប្រឆាំងនឹងអាពាហ៍ពិពាហ៍នោះទេ។ គ្មានជនណាម្នាក់នៅលើលោកនេះ និយាយថាអាពាហ៍ពិពាហ៍អាក្រក់នោះទេ ហើយគ្មានសាសនាណាមួយដែលប្រឆាំងនឹងអាពាហ៍ពិពាហ៍នោះផងដែរ។

តាមការពិត សត្វលោកទាំងអស់កើតមក ក៏ព្រោះជីវិតផ្លូវភេទដែរ។ នៅក្នុងភាពជាមនុស្ស ស្ថាប័នអាពាហ៍ពិពាហ៍បានបង្កើតឡើង ហេតុដូច្នេះហើយសង្គមធានានូវនិរន្តកម្មនៃមនុស្សសត្វ និងធានាផងដែរថា គេគួរយកចិត្តទុកដាក់ដល់ក្មេងៗផងដែរ។ នេះគឺផ្អែកទៅលើហេតុផលថា

កុមារដែលកើតមក តាមរយៈការសប្បាយផ្លូវភេទ គឺត្រូវតែមានការទទួលខុសត្រូវពីភាគីដែលជាប់ពាក់ព័ន្ធ យ៉ាងហោចណាស់ រហូតដល់ពួកគេធំឡើង ហើយអាពាហ៍ពិពាហ៍ធានាថា ការទទួលខុសត្រូវនេះ គេត្រូវធ្វើនិងអនុវត្ត ។

សង្គមមួយលូតលាស់រីកចម្រើន តាមរយៈបណ្តាញទំនាក់ទំនងដែលឆ្វាក់ចូលគ្នា និងពាក់ព័ន្ធអាស្រ័យគ្នាទៅវិញទៅមក ។ រាល់ទំនាក់ទំនង គឺជាការប្តេជ្ញាចិត្តដែលពេញចិត្ត ដើម្បីគាំទ្រនិងការពារអ្នកដទៃទៀត នៅក្នុងក្រុមមួយឬសហគមន៍មួយ ។ អាពាហ៍ពិពាហ៍ដើរតួយ៉ាងសំខាន់នៅក្នុងបណ្តាញដ៏រឹងមាំនៃទំនាក់ទំនង ផ្តល់ការគាំទ្រនិងការការពារនេះ ។ អាពាហ៍ពិពាហ៍ល្អប្រសើរ គួរលូតលាស់និងរីកចម្រើនជាលំដាប់ ពីការយល់ដឹង មិនមែនជាសន្ទុះចិត្ត គឺពីការស្មោះត្រង់ពិតប្រាកដ មិនមែនគ្រាន់តែជាការផ្តេកផ្តួល បណ្តោយខ្លួនទាំងស្រុងនោះទេ ។ ស្ថាប័នអាពាហ៍ពិពាហ៍ ផ្តល់នូវមូលដ្ឋានល្អមួយសម្រាប់ការរីកចម្រើននៃវប្បធម៌ សមាគមដែលផ្តល់ភាពរីករាយមួយរបស់បុគ្គលពីររូប ដើម្បីថែរក្សានិងចៀសផុតពីភាពនៅឯកោ ទុរគតភាព និងសេចក្តីភ័យខ្លាច ។ នៅក្នុងអាពាហ៍ពិពាហ៍ ដៃគូនីមួយៗ បង្កើតឱ្យមានតួនាទី ដែលត្រូវពឹងពាក់គ្នាទៅវិញទៅមក ដោយផ្តល់កម្លាំង និងការលើកទឹកចិត្តផ្នែកសីលធម៌ទៅឱ្យដៃគូម្ខាងទៀត ដៃគូម្ខាងៗបង្ហាញជាក់ស្តែងនូវការទទួលស្គាល់ ដែលផ្តល់នូវការគាំទ្រ និង

គួរឱ្យកោតសរសើរនៃជំនាញរបស់ដៃគូផ្សេងទៀត ក្នុងការថែទាំនិងការផ្ដល់ដល់គ្រួសារ។ មិនត្រូវមានការគិតថា ស្ត្រីឬបុរសត្រូវមានឋានៈខ្ពស់ជាងទេ ម្នាក់ៗគឺត្រូវពឹងពាក់គ្នាទៅវិញទៅមក អាពាហ៍ពិពាហ៍គឺភាពជាដៃគូនៃភាពស្មើគ្នា ស្លូតបូត ទន់ភ្លន់ សប្បុរស ស្ងប់ស្ងាត់ មិនឆេវឆាវ និងលះបង់។

នៅក្នុងព្រះពុទ្ធសាសនា គេអាចស្វែងរកឃើញនូវដំបូន្មានចាំបាច់ទាំងអស់នេះ ដែលអាចជួយគេឱ្យមានជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល។ គេមិនគួរមិនអើពើនឹងដំបូន្មាន ដែលសម្ដែងដោយព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទេ បើគេពិតជាចង់បានជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុមង្គលនោះ។ នៅក្នុងសូត្រទាំងឡាយរបស់ព្រះអង្គ ព្រះពុទ្ធទ្រង់បានសម្ដែងឱវាទជាច្រើនសម្រាប់គូភរិយាស្វាមីដែលរៀបការហើយ និងសម្រាប់អ្នកទាំងឡាយណា ដែលគិតបម្រុងនឹងរៀបអាពាហ៍ពិពាហ៍។ ព្រះពុទ្ធទ្រង់សម្ដែងថា "បើបុរសអាចរកបានភរិយាសមរម្យនិងមានការយល់ដឹង និងស្ត្រីអាចរកបានស្វាមីសមរម្យនិងមានការយល់ដឹង ទាំងពីរនាក់ ជាមនុស្សមានភ័ព្វសំណាងល្អពិតប្រាកដ"។

## ២. ធម្មជាតិនៃសេចក្ដីស្រឡាញ់និងសេចក្ដីសប្បាយរីករាយ

### សេចក្ដីស្រឡាញ់

សេចក្ដីស្នេហាមានប្រភេទខុសគ្នាជាច្រើន ហើយសេចក្ដីស្នេហាបង្ហាញឱ្យឃើញផ្សេងៗពីគ្នា ដូចជាសេចក្ដីស្នេហាមាតាបិតា សេចក្ដីស្នេហាកាមគុណ សេចក្ដីស្នេហាវេទនារម្មណ៍ សេចក្ដីស្នេហាផ្លូវភេទ សេចក្ដីស្នេហាអត្តទត្ថភាព(ស្រឡាញ់ខ្លួនតែម៉្យាង) សេចក្ដីអនត្តទត្ថភាព(មិនស្រឡាញ់តែខ្លួនតែម៉្យាង) និងសេចក្ដីស្នេហាសកល។

បើមនុស្សទាំងឡាយ មានត្រឹមតែសេចក្ដីស្នេហាប្រកបដោយកាមគុណ ឬអត្តទត្ថភាពចំពោះគ្នានឹងគ្នា ស្នេហាប្រភេទនេះមិនអាចមានរយៈពេលយូរអង្វែងទេ។ នៅក្នុងទំនាក់ទំនងសេចក្ដីស្នេហាពិតប្រាកដ គេមិនគួរសួរពីទំហំស្នេហាប៉ុនណាដែលគេអាចទទួលបាន ប៉ុន្តែគេគួរសួរថាទំហំនៃសេចក្ដីស្នេហាប៉ុនណាដែលគេអាចផ្ដល់ឱ្យ។

ពេលសម្រស់ ពណ៌សម្បុរស្បែក និងយុវភាព ចាប់ផ្ដើមបាត់បង់ ស្វាមីដែលគិតតែអំពីទិដ្ឋភាពនៃសេចក្ដីស្រឡាញ់ផ្នែករូបរាងកាយ អាចគិតអំពីការទទួលបានថ្មីមួយទៀតដែលមានវ័យនិងរូបរាងក្មេងជាង។ សេចក្ដីស្នេហាប្រភេទនោះ ជាសេចក្ដីស្នេហា ឬការត្រេកត្រអាលរបស់សត្វតិរច្ឆាន បើបុរសពិតជាបង្កើតសេចក្ដីស្នេហាមួយ ដែលជាការបង្ហាញក្ដីកង្វល់របស់មនុស្សចំពោះមនុស្សសត្វមួយផ្សេងទៀត គេនឹងមិនសង្កត់ធ្ងន់ត្រឹមតែទៅ

លើសោភ័ណភាពផ្នែកខាងក្រៅ និងការទាក់ទងផ្នែករូបរាងកាយដៃគូរបស់គេនោះទេ។ សម្រស់និងការទាក់ទាញរបស់ដៃគូ គួរមាននៅក្នុងបេះដូងនិងចិត្តរបស់គេ មិនមែននៅលើអ្វីដែលគេមើលឃើញនោះទេ។ ដូចគ្នានេះដែរ ភរិយាដែលប្រតិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា នឹងនៅអើពើស្វាមីរបស់នាង សូម្បីតែគាត់បានចាស់ជរា ក្រខ្សត់ ឬមានជម្ងឺក៏ដោយ។

*"ខ្ញុំមានសេចក្ដីភ័យខ្លាចមួយដែលថា ក្មេងស្រីសម័យទំនើបស្រឡាញ់ចង់ក្លាយជាហ៊្សែល្បែតដែលមានរូមអូបួនដប់។ នាងស្រឡាញ់ការផ្សងព្រេង... ក្មេងស្រីសម័យទំនើបស្លៀកពាក់មិនដើម្បីការពារខ្លួននាងពីខ្យល់ ភ្លៀង និងកំដៅថ្ងៃនោះទេ ប៉ុន្តែដើម្បីទាក់ទាញការចាប់អារម្មណ៍។ នាងកែច្នៃធម្មជាតិ ដោយផាត់ពណ៌លើរូបរាងកាយនាង ដើម្បីឱ្យមើលទៅឃើញមិនធម្មតា"។*

(មហាត្មៈគន្ធី)

## ទំនាក់ទំនងផ្លូវភេទ

ទំនាក់ទំនងផ្លូវភេទ ដោយខ្លួនវា មិនមែនអាក្រក់គ្មានសីលធម៌នោះទេ ទោះបីចំណង់និងតណ្ហាប្រាថ្នាចង់បានទំនាក់ទំនងនេះ រំខានដោយចៀសមិនផុតដល់សេចក្ដីស្ងប់ស្ងៀមផ្លូវចិត្ត ដូច្នេះហើយ វាមិនជួយឱ្យសម្រេចប្រយោជន៍ដល់ការអភិវឌ្ឍផ្នែកសតិបញ្ញាទេ។

នៅក្នុងស្ថានភាពមានឧត្ដមគតិ ទំនាក់ទំនងផ្លូវភេទគឺជាការឡើងដល់កម្រិតខ្ពស់ផ្នែករាងកាយនៃទំនាក់ទំនងផ្លូវអារម្មណ៍ ដែលធ្វើឱ្យស្កប់ស្កល់ពេញលេញ ដែលដៃគូទាំងពីរផ្ដល់និងទទួលបានស្មើៗគ្នា។

ការគូររូបពណ៌នាអំពីសេចក្ដីស្នេហាដោយក្រុមធ្វើពាណិជ្ជកម្ម តាមរយៈបណ្ដាញផ្សព្វផ្សាយពត៌មាន នូវអ្វីដែលយើងហៅថា វប្បធម៌ "**លោកខាងលិច**" មិនមែនជាសេចក្ដីស្នេហា"ពិតប្រាកដ"ទេ។ ពេលសត្វតិរច្ឆានចង់រួមសង្វាស វាបង្ហាញ "សេចក្ដីស្នេហា"របស់វា ប៉ុន្តែបន្ទាប់ពីរួមសង្វាសហើយ វាក៏បានភ្លេចសេចក្ដីស្នេហានោះទៅ។ សម្រាប់សត្វតិរច្ឆាន ការរួមសង្វាស គឺគ្រាន់តែជាគោលបំណងសភាវគតិចាំបាច់សម្រាប់ការធ្វើ**ជាតិកម្ម** (ការមានកូនចៅរហូតតទៅ) ប៉ុណ្ណោះ។ ប៉ុន្តែ មនុស្សជាតិមានអ្វីៗច្រើនថែមទៀត ដើម្បីផ្ដល់ឱ្យក្នុងបញ្ញាតិនៃសេចក្ដីស្នេហា។ កាតព្វកិច្ចនិងទំនួលខុសត្រូវ គឺជាគ្រឿងផ្សំសំខាន់ ដើម្បីថែរក្សាសាមគ្គីភាព ការចុះសម្រុងគ្នា និងការដឹងចិត្តថ្លើមគ្នា នៅក្នុងទំនាក់ទំនងរវាងមនុស្សជាតិ។

ទំនាក់ទំនងផ្លូវភេទ មិនមែនជាគ្រឿងផ្សំសំខាន់បំផុតសម្រាប់ជាសុភមង្គលនៅក្នុងជីវិតអាពាហ៍ពិពាហ៍នោះទេ។ អ្នកទាំងឡាយណាដែលបានក្លាយជាទាសករផ្លូវភេទ គឺបានត្រឹមតែបាត់បង់សេចក្ដីស្នេហានិងធម្មជាតិជាមនុស្ស នៅក្នុងអាពាហ៍ពិពាហ៍ប៉ុណ្ណោះ។ ក្រៅពីនោះ ស្ត្រីភេទត្រូវតែឈប់ចាត់ទុកខ្លួនឯង ថាជាឧបករណ៍នៃចំណង់ត្រេកត្រអាលរបស់បុរស

នាងត្រូវតែបដិសេធមិនតុបតែងខ្លួនប្រាណនាងជាធម្មតា ដើម្បីធ្វើឱ្យបុរសពេញចិត្ត សូម្បីតែគេជាស្វាមីរបស់នាងក៏ដោយ ។ បើស្ត្រីចង់ធ្វើជាដៃគូស្នេហាពជាមួយបុរស នាងគួរតែរៀបចំឱ្យបានល្អ ធ្វើដូច្នេះសេចក្ដីថ្លៃថ្នូររបស់នាង ត្រូវបានធ្វើឱ្យប្រសើរឡើង ហើយនាងមិនក្លាយជានិមិត្តរូបផ្លូវភេទផង ។ អាពាហ៍ពិពាហ៍សម្រាប់បំពេញចំណង់ផ្លូវភេទ មិនមែនជាអាពាហ៍ពិពាហ៍ទេ ។ វាជាការត្រេកត្រអាលនឹងកាម ។

(មហាត្ម័គន្ធី)

សេចក្ដីស្នេហា តាមពិតអាចជាផលនៃទំនាក់ទំនងផ្លូវភេទ ប៉ុន្តែការបញ្ច្រាសមកវិញ ក៏ពិតដូចគ្នាដែរ ពោលគឺទំនាក់ទំនងផ្លូវភេទ គឺការបង្ហាញនូវសេចក្ដីស្រឡាញ់ ។ នៅក្នុងជីវិតអាពាហ៍ពិពាហ៍មានសុភមង្គលប្រកបដោយឧត្តមគតិ ទាំងសេចក្ដីស្រឡាញ់ ទាំងទំនាក់ទំនងផ្លូវភេទគឺមិនអាចកាត់ផ្ដាច់ពីគ្នាបានឡើយ ។

## ការពន្យល់របស់ព្រះសម្មាសម្ពុទ្ធ

យើងអាចសិក្សាពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធដោយចាត់ទុកអារម្មណ៍ទាំងឡាយ ដែលស្ត្រីនិងបុរសមានចំពោះគ្នាទៅវិញទៅមក ។ ព្រះពុទ្ធទ្រង់សម្ដែងថា ព្រះអង្គមិនឃើញមានវត្ថុណាមួយនៅលើលោកនេះ ដែលទាក់ទាញការចាប់អារម្មណ៍របស់បុរសខ្លាំងជាងរូបរបស់

ស្ត្រីនោះទេ។ ទន្ទឹមនឹងនេះ ការទាក់ទាញសំខាន់សម្រាប់ស្ត្រីគឺរូបរបស់បុរស។ មានន័យថា តាមធម្មជាតិស្ត្រីនិងបុរស ផ្តល់ឱ្យគ្នាទៅវិញទៅមកនូវសេចក្តីសុខលោកីយ៍។ គេមិនអាចទទួលបានសេចក្តីសុខបែបនេះពីវត្ថុផ្សេងទៀតទេ។ ពេលយើងសង្កេតមើលដោយប្រុងប្រយ័ត្ន យើងសម្គាល់ឃើញថា ក្នុងចំណោមវត្ថុទាំងអស់ ដែលផ្តល់សេចក្តីសប្បាយរីករាយ គ្មានវត្ថុណាដទៃទៀត ដែលអាចធ្វើឱ្យវិញ្ញាណទាំងប្រាំគាប់ចិត្ត ក្នុងពេលជាមួយគ្នា ក្រៅពីរូបរបស់បុរសនិងរូបរបស់ស្ត្រីនោះទេ។

ប្រជាជនក្រិចសម័យបុរាណបានដឹងពីរឿងនេះ ពេលគេនិយាយថា កាលពីដើម ស្ត្រីនិងបុរសគឺជាមនុស្សតែមួយ។ ពួកគេត្រូវបានកាត់ផ្តាច់ជាពីរផ្នែក ហើយផ្នែកទាំងពីរដែលកាត់ផ្តាច់ចេញពីគ្នានេះ កំពុងស្វែងរកគ្នាជាបន្ត ដើម្បីតភ្ជាប់គ្នាឡើងវិញ ជាស្ត្រីនិងបុរស[១]។

## សេចក្តីសប្បាយរីករាយ

តាមធម្មជាតិ យុវជនក្មេងៗចូលចិត្តបណ្តោយខ្លួនតាមអំពើចិត្តនៅក្នុងសេចក្តីសុខលោកីយ៍ ដែលអាចរួមមានទាំងរឿងល្អនិងអាក្រក់។ រឿងល្អ ដូចជាការចូលចិត្តតូរ្យតន្ត្រី កំណាព្យ ការរាំរែក អាហារល្អៗ សំលៀកបំពាក់ និងការស្វែងរកស្រដៀងៗគ្នា ដែលមិនធ្វើទុក្ខទោសដល់រាងកាយ។ វត្ថុទាំងនោះគ្រាន់តែបន្លប់យើង មិនឱ្យមើលឃើញធម្មជាតិដែលកន្លងទៅ

---

[១] រឿងនិទានបុរាណរបស់ក្រិច

យ៉ាងឆាប់រហ័សនិងភាពមិនពិតប្រាកដនៃការកើត ហើយដោយហេតុនោះ ពន្យាភាពអាចដឹងដោយវិញ្ញាណរបស់យើង អំពីធម្មជាតិពិតនៃតួខ្លួន។

ឥន្ទ្រីយ៍និងវិញ្ញាណទាំងឡាយរបស់យុវជនក្មេងៗស្អាតបរិសុទ្ធ និងមានស្មារតីវាងវៃណាស់ ពួកគេសកម្មណាស់ដើម្បីផ្គត់ផ្គង់វិញ្ញាណទាំងប្រាំ។ ស្ទើរតែរាល់ថ្ងៃ ពួកគេមានគម្រោងនិងគិតរកវិធីនិងមធ្យោបាយ ដើម្បីទទួលបានទម្រង់ខ្លះនៃសេចក្ដីសុខ។

តាមធម្មជាតិនៃការកើតនោះ គេនឹងមិនស្កប់ស្កល់ទាំងស្រុងជាមួយសេចក្ដីសុខសប្បាយរីករាយ អ្វីក៏ដោយដែលគេទទួលបាននិងវិបាកតណ្ហា ជាផលបង្កើតឱ្យមានត្រឹមតែសេចក្ដីប្រាថ្នា ភាពរសាប់រសល់និងក្ដីព្រួយបារម្ភថែមទៀតប៉ុណ្ណោះ។

ពេលយើងគិតឱ្យបានល្អិតល្អន់អំពីបញ្ហានេះ យើងអាចយល់បានថាជីវិតគឺគ្មានអ្វីទាំងអស់ ប៉ុន្តែគ្រាន់តែជាសុបិន។ នៅក្នុងទីបញ្ចប់ តើអ្វីខ្លះដែលយើងទទួលបានពីឧបាទាន ពោលគឺការប្រកាន់មាំទៅនឹងជីវិតនេះ? គឺគ្រាន់តែការព្រួយបារម្ភ ការខកចិត្ត និងការខូចចិត្តតែប៉ុណ្ណោះ។ យើងអាចមានសេចក្ដីសប្បាយរីករាយខណៈខ្លីប៉ុណ្ណោះ ប៉ុន្តែនៅក្នុងការវិភាគចុងក្រោយ យើងត្រូវតែព្យាយាមរកឱ្យឃើញថា អ្វីទៅជាគោលបំណងពិតប្រាកដនៃជីវិតរបស់យើង។

ពេលគេឈប់ប្រាថ្នាលើសលប់ដោយចង់បានកាមរាគៈ ព្រមទាំង

មិនស្វះស្វែងរកសេចក្ដីសុខផ្លូវកាយនៅក្នុងក្រុមនៃអ្នកដទៃទៀត សេចក្ដីប្រាថ្នាចង់រៀបអាពាហ៍ពិពាហ៍មិនកើតឡើងនោះទេ។ សេចក្ដីទុក្ខនិងការសប្បាយរីករាយផ្លូវលោក ទាំងពីរនេះគឺជាផលនៃតណ្ហា ឧបាទាន និងវេទនារម្មណ៍។ បើយើងព្យាយាមគ្រប់គ្រង និងទប់អារម្មណ៍របស់យើងដោយកែសម្រួលតាមមធ្យោបាយមិនប្រាកដនិយម យើងបង្កើតឱ្យមានការរំខាននៅក្នុងចិត្តនិងកាយរបស់យើង។ ហេតុនេះ យើងត្រូវតែដឹងពីវិធីដោះស្រាយនិងគ្រប់គ្រងតណ្ហា កាមរាគៈរបស់យើង។ ដោយគ្មានការប្រើប្រាស់កាមរាគៈនេះខុសឬហួសកម្រិត យើងអាចផ្សាំតណ្ហារបស់យើងតាមរយៈការយល់ដឹងត្រឹមត្រូវសមរម្យ។

## ៣. សភាពពិតនៃជីវិតអាពាហ៍ពិពាហ៍

លោក ចន ជេ. រ៉ូប៊ិនសុន នៅក្នុងសៀវភៅរបស់គាត់ **“នៃការពិត”** បានផ្តល់ដំបូន្មានស្តីអំពីសេចក្តីស្រឡាញ់ ទំនាក់ទំនងផ្លូវភេទ និងជីវិតអាពាហ៍ពិពាហ៍ដូចតទៅ ÷ "ចូរប្រុងប្រយ័ត្ន និងចែកឱ្យដាច់ពីគ្នាថា ជាការងាយបំផុត ក្នុងការរៀបអាពាហ៍ពិពាហ៍ជាងការមិនរៀបអាពាហ៍ពិពាហ៍។ បើលោកអ្នកមានគូស្រករល្អត្រឹមត្រូវ វាជាឋានសួគ៌ ប៉ុន្តែបើមិនមានគូស្រករល្អត្រឹមត្រូវទេ លោកអ្នករស់នៅក្នុងឋាននរក ជាប្រចាំម្ភៃបួនម៉ោង ហើយនរកនេះតោងលោកអ្នកស្អិតជាដរាប វាអាចជារឿងជូរចត់បំផុតមួយ ក្នុងចំណោមរឿងជូរចត់បំផុតដទៃទៀតនៅក្នុងជីវិត។ ជីវិតពិតជាចម្លែកមែនមិនដឹងជាយ៉ាងម៉េច ពេលលោកអ្នករកបានគូស្រករល្អ លោកអ្នកដឹងវានៅក្នុងចិត្តរបស់លោកអ្នក វាមិនមែនត្រឹមតែភាពស្រើបស្រាលមួយស្របក់ប៉ុណ្ណោះទេ ប៉ុន្តែការជម្រុញផ្លូវភេទដ៏មានឥទ្ធិពល បង្ខំយុវជនក្មេងម្នាក់ ដោយឥតគិតគូរ ឱ្យធ្លាក់ទៅក្នុងអំពើងងឹតងងល់ ហើយគេមិនអាចជឿជាក់លើអារម្មណ៍របស់គេច្រើនពេកទេ។ នេះជាសេចក្តីពិតវិសាមញ្ញមួយ គឺថា បើគេផឹកគ្រឿងស្រវឹងហើយធ្វើឱ្យមានការយល់ច្រឡំអីចឹងហើយស្រីចេកដ៏អាក្រក់បំផុតនៅក្នុងរង្គសាលងងឹត អាចមើលទៅដូចព្រះនាងកាមទេព ហើយសម្រស់របស់នាងក្លាយទៅជាពុំអាចទប់ទល់បាន។ ទោះបីជាសេចក្តីស្រលាញ់ប្រសើរជាង ទំនាក់ទំនងផ្លូវភេទយ៉ាងណា

វាជាមូលដ្ឋានផ្នែកជីវសាស្ត្ររវាងស្ត្រីម្នាក់និងបុរសម្នាក់ សេចក្ដីស្រឡាញ់និងទំនាក់ទំនងផ្លូវភេទ ទៅជាឆ្ងាក់គ្នានិងមានទំនាក់ទំនងជាមួយគ្នា។

## បញ្ហា

ស្ទើរតែរាល់ថ្ងៃ យើងបានឮគេត្អូញត្អែរអំពីអាពាហ៍ពិពាហ៍របស់ពួកគេ។ យើងកម្រឮរឿងរ៉ាវទាំងឡាយ អំពីអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គលណាស់។ យុវជនក្មេងៗ ដែលអានរឿងប្រលោមលោកមនោសញ្ចេតនា និងមើលខ្សែភាពយន្តមនោសញ្ចេតនា តែងតែសន្និដ្ឋានថាអាពាហ៍ពិពាហ៍គឺជាផើងផ្កាកុលាប។ ជាអកុសល អាពាហ៍ពិពាហ៍មិនមែនផ្អែមល្ហែមដូចដែលគេគិតនោះទេ។ អាពាហ៍ពិពាហ៍ និងបញ្ហាទាំងឡាយមានការទាក់ទងគ្នាទៅវិញទៅមក ហើយគេត្រូវតែចង់ចាំថា ពេលគេរៀបអាពាហ៍ពិពាហ៍ គេនឹងត្រូវប្រឈមមុខ នឹងបញ្ហាទទួលខុសត្រូវទាំងឡាយដែលគេមិនដែលរំពឹងទុកជាមុន ឬបានដឹងរហូតមកដល់ពេលនេះ។ មនុស្សជាច្រើនតែងគិតថា ជាកាតព្វកិច្ចត្រូវតែរៀបអាពាហ៍ពិពាហ៍មានគូស្រករ ហើយពិធីរៀបអាពាហ៍ពិពាហ៍នោះ គឺជាព្រឹត្តិការណ៍សំខាន់បំផុតនៅក្នុងជីវិតរបស់ពួកគេ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីធានាបាននូវអាពាហ៍ពិពាហ៍ប្រកបដោយជោគជ័យមួយ គូស្រករត្រូវតែធ្វើឱ្យជីវិតរបស់ពួកគេស្របគ្នា ដោយធ្វើឱ្យតិចទៅនូវភាពខុសគ្នាអ្វីក៏ដោយដែលគេ

អាចមានរវាងគូស្រករនោះ។ បញ្ហាទាំងឡាយនៃអាពាហ៍ពិពាហ៍នាំឱ្យមនុស្សដែលមើលឃើញតែអាក្រក់ និយាយថា អាចមានត្រឹមតែជីវិតអាពាហ៍ពិពាហ៍ស្ងប់ស្ងាត់មួយ បើអាពាហ៍ពិពាហ៍នោះជាអាពាហ៍ពិពាហ៍រវាងភរិយាខ្វាក់និងស្វាមីថ្លង់ ពីព្រោះភរិយាខ្វាក់មិនអាចមើលកំហុសរបស់ស្វាមី ហើយស្វាមីថ្លង់មិនអាចស្ដាប់ឮការនិយាយច្រាំដែលរបស់ភរិយាគាត់។

## ការចែករំលែកនិងទំនុកចិត្ត

បុព្វហេតុមួយ ក្នុងចំណោមបុព្វហេតុចំបងៗជាច្រើននៃបញ្ហារវាងប្ដីឬប្រពន្ធ គឺការសង្ស័យនិងការមិនទុកចិត្តគ្នា។ អាពាហ៍ពិពាហ៍គឺជាការប្រសិទ្ធិពរជ័យ ប៉ុន្តែមនុស្សជាច្រើនបានធ្វើឱ្យក្លាយជាការស្ដីបន្ទោសដោយគេខ្វះការយល់ដឹង។

ទាំងភរិយាទាំងស្វាមី គួរតែបង្ហាញការទុកចិត្ត ដែលមាននៅក្នុងខ្លួនទៅឱ្យគ្នាទៅវិញទៅមក ហើយព្យាយាមកុំឱ្យមានការលាក់កំបាំងរវាងគ្នា។ ការលាក់កំបាំងបង្កើតឱ្យមានការសង្ស័យៗ នាំឱ្យមានការប្រច័ណ្ឌៗ បង្កើតឱ្យមានកំហឹងៗ បណ្ដាលឱ្យមានភាពអមិត្តៗ អាចបណ្ដាលឱ្យលែងលះគ្នា ធ្វើអត្តឃាត ថែមទាំងធ្វើឃាតកម្ម។

បើគូស្រករអាចចែករំលែកសេចក្ដីទុក្ខ និងសេចក្ដីសុខនៅក្នុងជីវិត

ពីមួយថ្ងៃទៅមួយថ្ងៃរបស់គេ គេអាចលួងលោមគ្នាទៅវិញទៅមកឱ្យធូរចិត្ត និងធ្វើឱ្យតិចទៅនូវសេចក្ដីទុក្ខព្រួយរបស់ពួកគេ។ ហេតុដូចនេះ ភរិយាឬស្វាមី គួរតែកុំរំពឹងឱ្យមានត្រឹមតែសេចក្ដីសុខ។ មានសេចក្ដីទុក្ខ និងសេចក្ដីក្រខ្សត់ជាច្រើនដែលពួកគេនឹងត្រូវតែប្រឈមមុខ។ ពួកគេត្រូវតែមានអំណាចផ្លូវចិត្តខ្លាំងក្លា ដើម្បីកាត់បន្ថយបន្ទុកនិងការយល់ខុសរបស់ពួកគេ។ ការពិភាក្សាបញ្ហាទាំងសងខាង នឹងផ្ដល់ឱ្យពួកគេនូវជំនឿទុកចិត្ត ដើម្បីរស់នៅរួមគ្នា ជាការយល់ដឹងកាន់តែប្រសើរ។

ស្ត្រីនឹងបុរស ត្រូវការចង់បានសេចក្ដីសុខពីគ្នាពេលប្រឈមមុខនឹងបញ្ហា និងភាពលំបាកលំបិន។ ការមានអារម្មណ៍ថាមានភាពអសន្តិសុខ និងភាពលំបាកវេទនា នឹងរលាយបាត់ ហើយជីវិតនឹងកាន់តែមានន័យ មានសុភមង្គល និងគួរឱ្យចាប់អារម្មណ៍ថែមទៀត បើមាននរណាម្នាក់មានបំណងចង់ចែករំលែកបន្ទុករបស់ម្នាក់ទៀត។

## ខចឹតខខល់ដោយអារម្មណ៍រំភើបចិត្ត

ពេលបុគ្គលពីររូបស្រលាញ់គ្នា ពួកគេមានទំនោរចង់បង្ហាញត្រឹមតែទិដ្ឋភាពប្រសើរបំផុតនៃធម្មជាតិនិងអត្តចរិតរបស់ពួកគេទៅឱ្យគ្នា ដើម្បីបង្ហាញឱ្យឃើញចំណាប់អារម្មណ៍ល្អអំពីខ្លួនពួកគេផ្ទាល់។ គេនិយាយថា សេចក្ដីស្នេហាបែបនេះ គឺងងឹតងងល់ ហេតុដូច្នេះហើយមនុស្សទាំងឡាយ

ដែលមានសេចក្តីស្នេហា មានទំនោរទៅជាភ្លេចភ្លាំងទាំងស្រុងនូវភាពខ្មៅងងឹតនៃធម្មជាតិរបស់ម្នាក់ៗ។

ជាការពិតជាក់ស្តែង ម្នាក់ៗនឹងព្យាយាមធ្វើឱ្យលេចឡើងនូវគុណសម្បត្តិខ្ពស់បំផុតរបស់គេម្នាក់ៗដល់អ្នកដទៃ ហើយពួកគេស្លុងខ្លាំងនៅក្នុងសេចក្តីស្នេហា ពួកគេមានទំនោរទទួលយកគ្នាទៅវិញទៅមកត្រឹមតែ "តម្លៃសន្មត់" ប៉ុណ្ណោះ។ គូស្នេហ៍ម្នាក់ៗនឹងមិនបញ្ចេញឱ្យឃើញភាគខ្មៅងងឹតនៃធម្មជាតិរបស់ខ្លួន ពីព្រោះតែសេចក្តីភ័យខ្លាចបាត់បង់គ្នា។ គុណវិបត្តិផ្ទាល់ខ្លួនណាមួយ ត្រូវបានគេបោសសំអាតដោយដាច់ៗពីគ្នា ក្រោមកម្រាលព្រំ និយាយដូច្នេះ មិនដើម្បីនឹងបង្កគ្រោះថ្នាក់ដល់ឱកាសទាំងឡាយនៃការយកឈ្នះគ្នាទៅវិញទៅមករបស់ពួកគេ។ មនុស្សទាំងឡាយដែលមានសេចក្តីស្នេហា មានទំនោរផងដែរមិនអើពើកំហុសរបស់ដៃគូដោយគិតថាពួកគេនិងអាចកែប្រែបានបន្ទាប់ពីអាពាហ៍ពិពាហ៍ ឬនឹងគិតថាពួកគេអាចរស់នៅជាមួយកំហុសទាំងនេះបាន ឬនឹងគិតថា "សេចក្តីស្នេហានឹងយកជ័យជំនះលើអ្វីៗទាំងអស់"។

ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីអាពាហ៍ពិពាហ៍ ពេលអារម្មណ៍មនោសញ្ចេតនាពីមុនរលាយអស់ទៅ ពួកគេនឹងបញ្ចេញឱ្យដឹងពីធម្មជាតិនៃអត្តចរិតរបស់គេម្នាក់ៗ។ បន្ទាប់មក ការខកចិត្តរបស់ដៃគូទាំងពីរ ភាគច្រើនគឺការបិទបាំងតាមបែបជាសុភាសិត ដែលគេបានលាក់

ទុកជាយូរមកហើយ អារម្មណ៍ដែលចូលជ្រៅរបស់ដៃគូម្ខាង១ ត្រូវបានបំបាត់ចោលដើម្បីលាតត្រដាងធម្មជាតិពិតរបស់ដៃគូទាំងពីរ។ ហេតុដូចនេះ ភ្លេចនិយាយថាសេចក្តីស្រឡាញ់ចិត្តយ៉ាងខ្លាំងចាប់កើតមាន។

## សេចក្តីត្រូវការផ្នែកសម្ភារៈ

សេចក្តីស្រឡាញ់ ដោយខ្លួនថា មិនមែនជីវិតមានតែខ្យល់អាកាសបរិសុទ្ធនិងរស្មីពន្លឺព្រះអាទិត្យតែឯងនោះទេ។ ពិភពលោកសម័យបច្ចុប្បន្នគឺជាពិភពលោកសម្ភារៈនិយម ហើយដើម្បីបំពេញនូវសេចក្តីត្រូវការផ្នែកសម្ភារៈនេះបាន ការធ្វើហិរញ្ញប្បទាននិងការផ្តល់ថវិការដ៏សមរម្យ គឺមានសារៈសំខាន់ណាស់។ បើគ្មានវាទេ គ្មានគ្រួសារណាមួយអាចរស់នៅបានដោយសុខស្រួលបានឡើយ។ នៅពេលដែលស្ថានភាពបែបនេះកើតឡើងក៏មានលេចឮសុភាសិតមួយថា "ពេលភាពក្រីក្រហោះចូលតាមទ្វារ សេចក្តីស្នេហាហោះចេញតាមបង្អួច"។ នេះមិនមានន័យថា គេត្រូវតែជាអ្នកមានដើម្បីបង្កើតការងារនៃអាពាហ៍ពិពាហ៍នោះទេ។ ក៏ប៉ុន្តែ បើបុគ្គលមានសម្ភារៈចាំបាច់ជាមូលដ្ឋាននៃជីវិត ដែលបានផ្តល់តាមរយៈការងារនីងនមួយ និងការធ្វើគម្រោងដោយប្រុងប្រយ័ត្ន ក្តីបារម្ភមិនចាំបាច់ជាច្រើនអាចត្រូវបានគេដកចេញពីអាពាហ៍ពិពាហ៍មួយបាន ដោយពិត។

អផាសុកភាពខាងផ្លូវចិត្តដែលកើតចេញពីភាពក្រីក្រ អាចត្រូវបាន ជៀសផុត ប្រសិនបើគូស្រករនោះ មានការយល់ដឹងពេញលេញ។ ដៃគូទាំងពីរត្រូវតែយល់ដឹងតម្លៃនៃការសន្តោស។ ទាំងពីរនាក់ត្រូវតែចាត់ទុកបញ្ហាទាំងអស់ថាជា "បញ្ហារបស់ខ្លួន" ហើយចែករំលែក "វាសនាមិនទៀងទាត់" ទាំងអស់ក្នុងស្មារតីពិតនៃភាពជាដៃគូជីវិតដែលមានយូរមកហើយ។

## សេចក្តីណែនាំមុនពេលរៀបអាពាហ៍ពិពាហ៍

នៅក្នុងគម្ពីរអង្គុត្តរនិកាយ មានឱវាទពាក្យទូន្មានមានតម្លៃជាច្រើន ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងប្រៀនប្រដៅក្មេងស្រីៗ មុនពេលអាពាហ៍ពិពាហ៍របស់ពួកគេ។ ដោយដឹងថាអាចមានភាពលំបាកជាច្រើនជាមួយកូនប្រសារថ្មី គេបង្គាប់បញ្ជាឱ្យក្មេងស្រីៗ ផ្តល់នូវការគោរពចំពោះម្តាយក្មេកឪពុកក្មេក ដោយបម្រើពួកគេដោយសេចក្តីស្រឡាញ់ដូចមាតាបិតាបង្កើតរបស់ពួកគេ។ គេរំពឹងឱ្យក្មេងស្រីៗផ្តល់កិត្តិយសនិងការគោរពចំពោះសាច់ញាតិនិងមិត្តភក្តិរបស់ស្វាមីនាង ដោយបង្កើតឱ្យមានបរិយាកាសមានសុភមង្គលនិងគួរឱ្យចូលចិត្ត នៅក្នុងលំនៅដ្ឋានថ្មីរបស់ពួកគេ។

ព្រះពុទ្ធទ្រង់សម្តែងបន្ថែមថា ពួកគេត្រូវសិក្សានិងស្វែងយល់ផងដែរអំពីធម្មជាតិរបស់ស្វាមីពួកគេ ពិនិត្យឱ្យជាក់ច្បាស់ពីសកម្មភាព អត្តចរិតនិងអធ្យាស្រ័យរបស់ស្វាមីពួកគេ ហើយត្រូវធ្វើខ្លួនឱ្យមានប្រយោជន៍និង

ប្រកបដោយភាពសហការគ្រប់ពេល នៅក្នុងផ្ទះថ្មីរបស់ពួកគេ។ ពួកគេគួរតែមានភាពគួរសម ចិត្តល្អ និងប្រុងប្រយ័ត្នចំពោះទ្រព្យសម្បត្តិរបស់ស្វាមីដែលរកបាន ហើយពិនិត្យមើលថា ការចំណាយទៅលើផ្ទះសំបែងទាំងអស់ ត្រូវបានគ្រប់គ្រងចាត់ចែងបានសមរម្យឬទេ។ ពាក្យប្រៀនប្រដៅទាំងនេះដែលព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែង មានរយៈពេលជាងម្ភៃប្រាំសតវត្សហើយ នៅតែជាប្រយោជន៍ដល់សព្វសត្វ រហូតមកដល់សព្វថ្ងៃនេះ។

## ៤. ទស្សនៈព្រះពុទ្ធសាសនាអំពីអាពាហ៍ពិពាហ៍

នៅក្នុងទស្សនៈស្តីអំពី "ការកើតនិងសេចក្តីទុក្ខ" បុគ្គលមួយចំនួនបានរិះគន់ព្រះពុទ្ធសាសនាដោយនិយាយថា សាសនានេះប្រឆាំងនិងជីវិតអាពាហ៍ពិពាហ៍។ ពួកគេរិះគន់ខុស។ ព្រះពុទ្ធទ្រង់មិនដែលទេសនាប្រឆាំងនិងជីវិតអាពាហ៍ពិពាហ៍នោះទេ។ ទោះបីយ៉ាងណាក៏ដោយ ព្រះអង្គបានចង្អុលប្រាប់ពីបញ្ហា ការលំបាក និងការព្រួយបារម្ភទាំងអស់ ដែលមនុស្សទាំងឡាយនឹងត្រូវបានប្រឈមមុខ ពេលគេចូលខ្លួនទទួលខុសត្រូវលើអាពាហ៍ពិពាហ៍។ ដោយសារតែព្រះអង្គទ្រង់សម្តែងដាស់តឿនគេឱ្យទប់ទល់នឹងបញ្ហាទាំងឡាយ ដែលកើតមានក្នុងអាពាហ៍ពិពាហ៍ មិនមានន័យថា ព្រះសម្មាសម្ពុទ្ធទ្រង់ថ្កោលទោសអាពាហ៍ពិពាហ៍នោះទេ។

ច្បាប់អាពាហ៍ពិពាហ៍ បញ្ជាក់ដោយខ្លួនឯងថា បុគ្គលនៅតែជាប់ស្អិតកាន់តែខ្លាំងនឹងរូបលោកដោយសារតែ ញាណសតិរបស់យើងត្រូវជាប់ជំពាក់ដោយតណ្ហា ឧបាទាន និងវេទនារម្មណ៍ ប៉ុន្តែវាជាធម្មជាតិទៅហើយដែលបញ្ហានោះគង់នឹងកើតមានឡើងដដែល។ បញ្ហានេះកើតមានឡើងពេលយើងត្រូវពិចារណា អំពីសេចក្តីត្រូវការរបស់អ្នកដទៃទៀត ហើយយើងចុះញ៉មចំពោះអ្វីដែលអ្នកដទៃត្រូវការ។

### តួនាទីរបស់សាសនា

ការវិភាគល្អិតល្អន់អំពីធម្មជាតិនៃតួខ្លួន សំខាន់សម្រាប់ជួយយើង

ឱ្យយល់ដឹងពីប្រភពនៃបញ្ហា ការព្រួយបារម្ភ សេចក្តីទុក្ខវេទនា និងវិធីយក ឈ្នះលើបញ្ហាទាំងនេះ។ ការប្រៀនប្រដៅផ្នែកសាសនា មានសារៈសំខាន់ ចំពោះការរក្សាឱ្យមានជីវិតស្ងប់ស្ងាត់។ ទោះបីជាយ៉ាងណាក៏ដោយ គេ មិនគួរក្លាយជាទាសករនៃសាសនាណាមួយឡើយ។ មនុស្សមិនបម្រើឱ្យ សាសនាទេគឺសាសនាបម្រើឱ្យមនុស្ស។ មានន័យថាមនុស្សត្រូវតែដឹងពីវិធី ប្រើសាសនាជាប្រយោជន៍ ដើម្បីការធ្វើឱ្យប្រសើរឡើង និងដើម្បី សុភមង្គលរបស់គេ តាមមធ្យោបាយត្រឹមត្រូវ។ ជាធម្មតា ដោយគោរព តាមការស្បថស្បែ បញ្ញាតិ ឬការបង្គាប់បញ្ជាផ្នែកសាសនាចៀសមិនរួច ដោយជំនឿងងឹតងងល់ ឬការបង្ខិតបង្ខំ ដោយគិតថា យើងមានករណីយ កិច្ចត្រូវប្រតិបត្តិតាមការស្បថស្បែ បញ្ញាតិ នឹងការបង្គាប់បញ្ជាផ្នែក សាសនានោះ នឹងមិនធ្វើឱ្យការយល់ដឹងសមរម្យរីកចម្រើនបានទេ។

ទស្សនវិស័យសំខាន់មួយរបស់ព្រះពុទ្ធសាសនា គឺព្រះសម្មាសម្ពុទ្ធ ទ្រង់មិនដាក់ច្បាប់ឬការបង្គាប់បញ្ជាផ្នែកសាសនាណាមួយទេ។ ព្រះសម្មា សម្ពុទ្ធ គឺជាសាស្តាតែមួយគាត់ ទ្រង់បានបញ្ញាតិក្បួនច្បាប់វិន័យជាច្រើន សម្រាប់យើងយកទៅប្រតិបត្តិ គឺអនុលោមទៅតាមកម្រិតជីវភាពការរស់ នៅរបស់យើង។ អ្នកទាំងឡាយណាដែលប្រតិបត្តិតាមសិក្ខាបទ សមាទាន សិក្ខាបទទាំងនោះដោយស្ម័គ្រចិត្ត ប៉ុន្តែមិនមែនជាច្បាប់ផ្នែកសាសនាដែល បង្ខិតបង្ខំខានមិនបាននោះទេ។ វាអាស្រ័យលើយើងមានបំណងប្រតិបត្តិ

តាមឱវាទពាក្យប្រៀនប្រដៅ តាមរយៈការយល់ដឹង និងបទពិសោធន៍ផ្ទាល់របស់យើង នូវអ្វីដែលល្អសម្រាប់យើងនិងសម្រាប់អ្នកដទៃ។ តាមរយៈបទពិសោធន៍ព្រាវៗច្រើនដងដើម្បីសម្រេចអ្វីមួយ យើងនឹងរៀនប្រតិបត្តិតាមពាក្យប្រៀនប្រដៅ ដែលនឹងផ្ដល់ឱ្យយើងនូវសុខសន្តិភាពនិងសុភមង្គលប្រកបដោយហេតុផល។

គេគួរតែព្យាយាមស្វែងយល់ធម្មជាតិនៃជីវិតលោកីយ៍។ ដោយដឹងថាលោកអ្នកត្រូវប្រឈមមុខនិងបញ្ហាទាំងឡាយ លោកអ្នកនឹងអាចពង្រឹងផ្លូវចិត្តរបស់លោកអ្នក និងត្រៀមខ្លួនថែមទៀតដើម្បីប្រឈមមុខនឹងបញ្ហាទាំងនោះដែលនឹងអាចកើតមានឡើង បើលោកអ្នករៀបអាពាហ៍ពិពាហ៍។ សាសនាសំខាន់សម្រាប់ជួយលោកអ្នក ឱ្យយកឈ្នះលើបញ្ហាទាំងឡាយរបស់លោកអ្នក។ ចំណេះដឹងអ្វីក៏ដោយ ដែលលោកអ្នកបានរៀនសូត្រអំពីគោលការណ៍សាសនា ពេលលោកអ្នកនៅក្មេង អាចទទួលយកប្រើប្រាស់ ដោយចៀសវាងកុំឱ្យមានការយល់ខុស ការខកចិត្ត និងការខូចចិត្ត។ ជាមួយគ្នានេះដែរ គុណសម្បត្តិល្អៗពិតប្រាកដមួយចំនួន ដូចជាសេចក្ដីអត់ធន់និងការយល់ដឹង ដែលយើងបានរៀនសូត្រតាមរយៈសាសនាមានប្រយោជន៍ជួយយើងឱ្យមានជីវិតអាពាហ៍ពិពាហ៍ស្ងប់ស្ងៀមមួយ។

ជាធម្មតា អាស្រ័យដោយការខ្វះខាតការយល់ដឹងទាំងសងខាង ទើបគូស្រករដែលរៀបការហើយជាច្រើន មានជីវភាពរស់នៅមានទុក្ខ

លំបាក។ លទ្ធផលដែលចេញពីបញ្ហានេះ គឺកូនទាំងឡាយដ៏ស្លូតត្រង់របស់ពួកគេត្រូវរងទុក្ខផងដែរ។ ជាការប្រសើរត្រូវដឹងពីវិធីដោះស្រាយបញ្ហារបស់លោកអ្នក ដើម្បីដឹកនាំជីវិតអាពាហ៍ពិពាហ៍ ឱ្យមានសុភមង្គល។ សាសនាអាចជួយលោកអ្នកឱ្យសម្រេចបាននូវសុភមង្គលនោះ។

## ៥. ទេវគ្រោះសាសនា

### សិទ្ធិបុគ្គល

បុព្វហេតុមួយក្នុងចំណោមបុព្វហេតុជាច្រើន នៃកង្វល់ធំបំផុតដែលមាននៅក្នុងប្រជាជនទាំងឡាយ ដែលមិនកាន់សាសនារបស់ប្រជាជនសេអ៊ិត គឺបញ្ហានៃការពិភាក្សាគ្នាមុនពេលរៀបអាពាហ៍ពិពាហ៍។ ពេលព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូមិនដែលទាមទាថា គូស្រករត្រូវកាន់សាសនាដូចគ្នាមុនអាពាហ៍ពិពាហ៍ ដែលគេរៀបអាពាហ៍ពិពាហ៍ឱ្យត្រូវតាមបែបសាសនាទេ ឯមនុស្សជាច្រើនដទៃទៀត មានទំនោរចង់បានគុណប្រយោជន៍អំពីសេរីភាពក្នុងសាសនាទាំងនេះ។

អាពាហ៍ពិពាហ៍ដែលផ្ទុយពីអ្វី ដែលរឿងប្រលោមលោកមនោសញ្ចេតនា ជាច្រើនបាននិយាយ មិនមានន័យថា ការរួមបញ្ចូលមនុស្សពីរនាក់ទាំងស្រុងនិងពេញលេញទៅក្នុងក៏រិតមួយដែលម្នាក់ៗ បាត់បង់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់គេទេ។ ពេលសាសនាមួយទាមទារថា ដៃគូទាំងពីរត្រូវមានផ្លាកសាសនាតែមួយដូចគ្នា វាបដិសេធមិនទទួលស្គាល់សិទ្ធិមនុស្សជាមូលដ្ឋានរបស់បុគ្គលម្នាក់ៗជឿអ្វីដែលគេចង់។ បណ្ដាសង្គមទាំងឡាយមាននៅក្នុងប្រវត្តិសាស្ត្រទាំងមូលបានបង្ហាញថា "ឯកភាពនៅក្នុងភាពផ្សេងៗគ្នា" មិនត្រឹមតែអាចដូចនោះទេ ថែមទាំងគេប្រាថ្នាចង់បានផ្សេង

ទៀតផង។ ការគោរពនិងការយល់ដឹងកាន់តែខ្លាំងឡើង កើតចេញពីភាពផ្សេងៗគ្នា។ បញ្ហានេះគួរតែអនុវត្តចំពោះអាពាហ៍ពិពាហ៍ផងដែរ។ មានគំរូនៅមានជាច្រើនទូទាំងពិភពលោក ដែលភរិយាស្វាមីរក្សាជំនឿផ្ទាល់ខ្លួនរបស់ពួកគេ ហើយនៅតែអាចរក្សាជីវិតអាពាហ៍ពិពាហ៍ ប្រកបដោយសុភមង្គល ដោយមិនមានការទល់មុខដាក់គ្នា (សម្មុខីកម្ម) ឡើយ។

ពុទ្ធសាសនិកមិនជំទាស់ នឹងការកើតមានសាសនាដទៃទៀតនោះទេ សូម្បីនៅក្នុងផ្ទះសំបែងតែមួយក៏ដោយ។ ជាអកុសល អ្នកកាន់សាសនាទាំងឡាយដែលមិនមានការខ្មាស់អៀន ជាអ្នកមិនដឹងខ្លួន ទាក់ទាញឱ្យមនុស្សផ្លាស់សាសនាតាមគ្រប់មធ្យោបាយទាំងអស់ ហើយបានជញ្ជក់យកប្រយោជន៍ ពីឥរិយាបថដ៏សប្បុរសនេះទៀត។

ពុទ្ធសាសនិកដែលមានប្រាជ្ញា ត្រូវតែស្វែងយល់អំពីឧបាយកលនេះ។ គ្មានមនុស្សលោកដែលមានប្រាជ្ញា មានសេចក្តីគោរពចំពោះខ្លួនឯង ជាអ្នកបានយល់ដឹងពិតប្រាកដអំពីអ្វីដែលគេមានសទ្ធាជឿ អាស្រ័យដោយការមានជំនឿដោយខ្លួនឯងផ្ទាល់ ត្រូវលះបង់ជំនឿរបស់ខ្លួនចោល ដោយគ្រាន់តែបំពេញទៅតាមការទាមទាររបស់សាសនាមួយផ្សេងទៀត ដែលធ្វើឡើងដោយមនុស្សនោះទេ។ ពុទ្ធសាសនិកមិនទាមទារឱ្យដៃគូរបស់ គេកាន់យកព្រះពុទ្ធសាសនា ហើយពួកគេថែមទាំងមិនចាំបាច់លះបង់ជំនឿផ្ទាល់របស់ពួកគេផងដែរ។

# ភាពស្រួចស្រាវក្រោយពេលអាពាហ៍ពិពាហ៍

ពេលយុវជនក្មេងៗមានសេចក្តីស្នេហា ពួកគេរៀបចំខ្លួនដើម្បីធ្វើពលិកម្មជាច្រើន ស៊ូប្តូររហូតពួកគេអាចរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែបន្ទាប់ពីរយៈពេលពីរបីឆ្នាំក្រោយមក ពេលតួនាទីពិតប្រាកដនៃការសាងអាពាហ៍ពិពាហ៍ឱ្យជោគជ័យចាប់ផ្តើម ការរសាយចិត្តក៏ចាប់ផ្តើមកើតមានផងដែរ។ ពេលដៃគូម្នាក់ ជាអ្នកបានបោះបង់ជំនឿសាសនាដែលបានកាន់ជឿជាយូរមកហើយរបស់ខ្លួនដើម្បី "សេចក្តីស្នេហា" ចាប់ផ្តើមមានវិប្បដិសារី ដោយបានធ្វើដូច្នេះ ការយល់ខុសមិនចាំបាច់ឱ្យកើតមានទេ។ គឺបញ្ហាទាំងនេះកាន់តែផ្តល់ឱ្យមានភាពតានតឹងបន្ថែមទៀត ក្នុងអំឡុងពេលមានភាពធុញទ្រាន់នៅក្នុងអាពាហ៍ពិពាហ៍ ហើយនាំឱ្យមានការឈ្លោះប្រកែកគ្នាតែប៉ុណ្ណោះ។ ជាធម្មតា បុព្វហេតុមួយក្នុងចំណោមបុព្វហេតុសំខាន់ៗនៃការឈ្លោះប្រកែកទាំងនេះ បានចោទជាបញ្ហាឡើងថា តើកូនគួរកាន់សាសនាណាមួយ។

អាស្រ័យហេតុនេះ សំខាន់បំផុតសម្រាប់គេត្រូវដឹងថា បើមានដំណើរការនៃការផ្លាស់ប្តូរអ្វីៗដែលជាប់ពាក់ព័ន្ធ វាត្រូវតែផ្អែកលើជំនឿពិតប្រាកដដោយខ្លួនឯង និងមិនមែនគ្រាន់តែជាភាពសមរម្យ ឬការបង្ខិតបង្ខំតែប៉ុណ្ណោះទេ។ ពុទ្ធសាសនិករក្សាសេរីភាពរបស់បុគ្គលម្នាក់ៗ ដើម្បីធ្វើការជ្រើសរើស។ យើងទាំងអស់គ្នា គួរតែគោរពគោលការណ៍នេះ។

# ពិធីរៀបអាពាហ៍ពិពាហ៍

គ្មានពិធី ឬដំណើរការជាក់លាក់ទេផ្នែកព្រះពុទ្ធសាសនា ក្នុងការរៀបចំពិធីអាពាហ៍ពិពាហ៍។ ព្រះពុទ្ធសាសនាទទួលស្គាល់ប្រពៃណី និងវប្បធម៌ដែលគោរពដោយប្រជាជន នៅក្នុងប្រទេសទាំងឡាយផ្សេងៗគ្នា។ ហេតុដូចនេះ ពិធីផ្នែកសាសនារបស់ពុទ្ធសាសនិកតែងខុសគ្នា ពីប្រទេសមួយទៅប្រទេសមួយ។

នៅក្នុងការពិតជាក់ស្តែងទូទៅ ការរៀបចំពិធីផ្នែកសាសនា ដើម្បីប្រសិទ្ធិពរជ័យបវរសួស្តី និងផ្តល់ដំបូន្មានដល់គូស្រករ គឺគេប្រារព្ធធ្វើជាទម្លាប់នៅក្នុងព្រះវិហារក៏បាន ឬនៅផ្ទះក៏បាន ដើម្បីផ្តល់សារៈសំខាន់ដ៏ធំធេងដល់អាពាហ៍ពិពាហ៍។ សព្វថ្ងៃនេះ នៅតាមបណ្តាប្រទេសជាច្រើន ក្រៅពីការប្រសិទ្ធិពរជ័យ អង្គការស្ថាប័នសាសនា ក៏គេបានផ្តល់សិទ្ធិផងដែរ ដើម្បីធ្វើពិធីរៀបអាពាហ៍ពិពាហ៍ឱ្យត្រូវតាមបែបសាសនា និងចុះអាពាហ៍ពិពាហ៍ រួមជាមួយនឹងការចេញលិខិតបញ្ជាក់អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

ជាទូទៅ ចំណុចសំខាន់បំផុត គឺគូស្រករគួរតែស្មោះត្រង់មែនទែនក្នុងគោលបំណងសហប្រតិបត្តិការជាមួយគ្នា និងយល់ចិត្តថ្លើមគ្នាទៅវិញទៅមក មិនតែពេលមានសុភមង្គលនោះទេ ថែមទាំងក្នុងកាលៈទេសៈណាក៏ដោយ ដែលពួកគេត្រូវប្រឈមមុខនឹងភាពលំបាកលំបិន។

## ៦. សុវត្ថិភាព ការគោរព និង ទំនួលខុសត្រូវ

### ការស្គាល់អសុវត្ថិភាព

នៅក្នុងអតីតកាលកន្លងមក គ្មានរឿងរ៉ាវបែបនេះ ដែលគេចាត់ទុកថា ការចុះអាពាហ៍ពិពាហ៍ស្របច្បាប់នោះទេ។ ស្ត្រីនិងបុរសសម្រេចចិត្តទាំងសងខាង ទទួលយកគ្នាទៅវិញទៅមក ជាភរិយានិងស្វាមី ដោយហេតុនេះហើយទើបពួកគេអាចរស់នៅជាមួយគ្នា។ អាពាហ៍ពិពាហ៍របស់ពួកគេប្រារព្ធធ្វើឡើងចំពោះមុខសហគមន៍ ហើយការបែកបាក់គ្នាកម្រកើតមានណាស់។ រឿងសំខាន់បំផុតនោះគឺ ពួកគេធ្វើឱ្យស្នេហាពិតរីកលូត លាស់ ហើយគោរពការទទួលខុសត្រូវទៅវិញទៅមករបស់ពួកគេ។

សព្វថ្ងៃនេះ ការចុះអាពាហ៍ពិពាហ៍ស្របច្បាប់ គឺសំខាន់ណាស់ដើម្បីធានាសុវត្ថិភាពនិងការពារទ្រព្យសម្បត្តិនិងបុត្រាបុត្រី។ ដោយសារការស្គាល់អសុវត្ថិភាព គូស្រករប្រារព្ធអាពាហ៍ពិពាហ៍ស្របច្បាប់ ដើម្បីធានាថា ពួកគេបានជាប់កិច្ចសន្យាតាមផ្លូវច្បាប់ មិនត្រូវព្រងើយកន្តើយនឹងករណីយកិច្ចរបស់ពួកគេ និងមិនត្រូវប្រព្រឹត្តអំពើអាក្រក់ដាក់គ្នាទេ ហើយសព្វថ្ងៃនេះ គូស្រករមួយចំនួនថែមទាំងបានដាក់កិច្ចសន្យាតាមផ្លូវច្បាប់ ផ្អែកលើអ្វីដែលនឹងបានកើតឡើង ដល់ទ្រព្យសម្បត្តិរបស់ពួកគេ (គឺចែកទ្រព្យសម្បត្តិគ្នា) បើពួកគេលែងលះគ្នា។

## ស្វាមីនិងភរិយា

យោងទៅតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា នៅក្នុងអាពាហ៍ពិពាហ៍ ស្វាមីអាចរំពឹងរកមើលគុណសម្បត្តិខាងក្រោម ពីភរិយារបស់គេ ÷

- ការស្រឡាញ់
- ការយកចិត្តទុកដាក់ និងការប្រុងប្រយ័ត្ន
- កាតព្វកិច្ចគ្រួសារ
- ស្វាមីភក្តិ
- ការថែទាំកូន
- សន្សំសំចៃ
- រៀបចំទុកដាក់ម្ហូបអាហារ
- ធ្វើឱ្យស្វាមីសប្បាយចិត្ត ពេលគេមានទុក្ខព្រួយ
- ភាពផ្អែមល្ហែមគ្រប់បែបយ៉ាង

បញ្ច្រាសមកវិញ ការរំពឹងមើលគុណសម្បត្តិរបស់ភរិយាពីស្វាមីគឺ ÷

- សុភាពរាបសារទន់ភ្លន់
- ចេះគួរសម
- ការចូលចុះក្នុងសង្គម ( មានទំនាក់ទំនងល្អជាមួយអ្នកដទៃ)
-សុវត្ថិភាព

- ភាពយុត្តិធម៌
- ភក្តីភាព
- សេចក្តីទៀងត្រង់
- ការរាប់អានជាមិត្តភាពល្អ
- ការគាំទ្រសីលធម៌

ក្រៅពី ទស្សនវិស័យផ្នែកអារម្មណ៍ និងការត្រេកត្រអាលទាំងនេះ គូស្រករនឹងត្រូវតែយកចិត្តទុកដាក់ អំពីលក្ខខណ្ឌជីវភាពរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ មានដូចជាថវិការគ្រួសារ និងកាតព្វកិច្ចសង្គម។ ដូច្នេះ ការពិគ្រោះយោបល់គ្នាទៅវិញទៅមក រវាងស្វាមីនិងភរិយាស្តីអំពីបណ្តាបញ្ហាគ្រួសារ ជួយបង្កើតឱ្យមានបរិយាកាសជឿទុកចិត្តគ្នា និងការដឹងចិត្តថ្លើមគ្នា ក្នុងការដោះស្រាយបញ្ហាអ្វីមួយដែលអាចកើតមានឡើង នៅក្នុងរង្វង់គ្រួសារ។

## ឱវាទរបស់ព្រះសម្មាសម្ពុទ្ធចំពោះគូស្រករភរិយាស្វាមី

### I. ភរិយា

ក្នុងការទេសនាប្រៀនប្រដៅស្ត្រីអំពីតួនាទីរបស់ពួកគេ នៅក្នុងជីវិតអាពាហ៍ពិពាហ៍ ព្រះពុទ្ធទ្រង់កោតសរសើរថា សុខសន្តិភាពនិងភាពចុះសម្រុងគ្នានៅក្នុងផ្ទះ ពឹងផ្អែកយ៉ាងធំធេងលើស្ត្រី។ ពាក្យប្រៀនប្រដៅ

របស់ព្រះអង្គ មានលក្ខណៈប្រាកដនិយម និងមានប្រយោជន៍ ពេលព្រះអង្គទ្រង់សម្ដែងអំពីចរិតលក្ខណៈ ពីមួយថ្ងៃទៅមួយថ្ងៃដ៏ល្អៗជាច្រើនដែលស្ត្រីគួរ ឬមិនគួរបណ្ដុះឱ្យមានឡើង។ នៅក្នុងឱកាសនានា ព្រះពុទ្ធទ្រង់ឱ្យឱវាទថា ភរិយា ÷

ក) មិនគួរមានគំនិតអាក្រក់ជំទាស់នឹងស្វាមីនៅក្នុងខ្លួន

ខ) មិនគួរគ្មានចិត្តមេត្តា ប្រើពាក្យមិនពិរោះ ឬប្រើអំណាច

គ) មិនត្រូវចំណាយខ្ជះខ្ជាយ ត្រូវចេះសន្សំសំចៃ និងរស់នៅទៅតាមធនធានដែលមាន

ឃ) ការពារ និងសន្សំទុកដាក់ទ្រព្យសម្បត្តិ និងប្រាក់កាសដែលស្វាមីរកបានដោយលំបាក

ង) ត្រូវប្រុងប្រយ័ត្នគ្រប់ពេល និងបរិសុទ្ធទាំងចិត្តទាំងកាយ

ច) ត្រូវស្មោះត្រង់ និងចូលទៅកន្លែងកំបាំងមិនត្រូវមានគំនិតប្រព្រឹត្តអំពើផិតក្បត់

ឆ) មានពាក្យសម្ដីថ្លៃថ្នូរ និងចេះគួរសមទាំងកាយវិការ

ជ) ត្រូវមានចិត្តល្អ ឧស្សាហ៍និងព្យាយាមធ្វើការងារ

ឈ) ចេះគិតគូរ និងមានចិត្តអាសូរដល់ស្វាមី ហើយឥរិយាបថរបស់នាង គួរប្រៀបធៀបទៅនឹងសេចក្តីស្រឡាញ់និងក្តីកង្វល់របស់មាតាដែលមានបុត្រាតែមួយ។

៣) ចេះដាក់ខ្លួន ចេះគោរព

ង) មិនឆេវឆាវ និងចេះយល់ចិត្ត ពោលគឺបម្រើ មិនត្រឹមតែក្នុងឋានៈជាភរិយា ថែមទាំងជាមិត្តភក្តិ និងជាទីប្រឹក្សា ពេលមានតម្រូវការ ។

នៅក្នុងសម័យពុទ្ធកាល សាស្តានៃសាសនាដទៃទៀត ក៏បានផ្តល់ឱវាទផងដែរ អំពីករណីយកិច្ចនិងកាតព្វកិច្ចរបស់ភរិយាចំពោះស្វាមី ជាពិសេស សង្កត់ធ្ងន់ទៅលើករណីយកិច្ចរបស់ភរិយា ដោយអត់ទ្រាំនឹងការបន្តពូជសម្រាប់ស្វាមី ផ្តល់ទឹកចិត្តស្មោះសរ និងផ្តល់សុភមង្គលប្តីប្រពន្ធ ។

សហគមមួយចំនួន ផ្តោតការយកចិត្តទុកដាក់ទៅលើការមានកូនប្រុសនៅក្នុងគ្រួសារ ។ ពួកគេជឿថា កូនប្រុសចាំបាច់សម្រាប់ប្រារព្ធធ្វើពិធីបុណ្យសពរបស់ពួកគេ ដោយមានជំនឿថា ជីវិតបន្ទាប់របស់ពួកគេជាជីវិតមួយល្អប្រសើរ ។ ការមិនមានកូនប្រុស ជាមួយភរិយាទីមួយ ផ្តល់សេរីភាពឱ្យបុរសរកភរិយាមួយទៀតដើម្បីមានកូនប្រុស ។ ព្រះពុទ្ធសាសនាមិនគាំទ្រជំនឿបែបនេះទេ ។

អនុលោមទៅតាមព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង អំពីកម្មនិយាម គេមានការទទួលខុសត្រូវចំពោះអំពើផ្ទាល់របស់ខ្លួន និងផលវិបាករបស់វា ។ មិនថាឡើយ កូនដែលកើតមកជាកូនប្រុសឬកូនស្រី មិនមែនកំណត់បានដោយមាតា ឬក៏បិតានោះទេ គឺអាស្រ័យដោយកម្មរបស់កូននោះឯង ។ ហើយសុខុមាលភាពរបស់បិតាឬជីតា មិនអាស្រ័យលើកម្ម

គឺអំពើរបស់កូនប្រុសឬចៅប្រុសនោះទេ។ មនុស្សម្នាក់ៗទទួលខុសត្រូវចំពោះកម្មផ្ទាល់របស់ខ្លួន។ ដូច្នេះ ជាការខុសសម្រាប់បុរសស្តីបន្ទោសភរិយារបស់ពួកគេ ឬសម្រាប់បុរសមានអារម្មណ៍មិនគ្រប់គ្រាន់ ពេលកូនប្រុសមិនបានកើត។ បរមពុទ្ធោវាទបែបនេះ ជួយកែតម្រូវទស្សនៈរបស់មនុស្សជាច្រើន និងកាត់បន្ថយជាធម្មតា នូវក្តីបារម្ភរបស់ស្ត្រីដែលមិនអាចបង្កើតកូនប្រុសដើម្បីប្រារព្ធ "ពិធីបុណ្យរំលឹកវិញ្ញាណក្ខន្ធដូនតា"។

ទោះបី នៅក្នុងក្បួនច្បាប់វិន័យរបស់ខុងជឺ ក៏មានចែងពីករណីយកិច្ចរបស់ភរិយាចំពោះស្វាមី តែមិនមានចែងសង្កត់ទៅលើករណីយកិច្ចនិងកាតព្វកិច្ចរបស់ស្វាមីចំពោះភរិយាផងទេ។ ទោះបីយ៉ាងនេះក៏ដោយ ក៏នៅក្នុងសិគាលោវាទសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្តែងយ៉ាងច្បាស់លាស់ពីករណីយកិច្ចរបស់ស្វាមីចំពោះភរិយា។

## II. **ស្វាមី**

ដើម្បីឆ្លើយតបទៅនឹងសំនួរ ថាតើស្វាមីគួរជួយផ្គត់ផ្គង់ភរិយារបស់ខ្លួនដោយរបៀបណាក្នុងនាមជាមេគ្រួសារ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសថា ស្វាមីគប្បីស្ញើចសរសើរឱ្យកិត្តិយសនិងគោរពឱ្យសមឋានៈជាភរិយា ស្មោះត្រង់ មិនប្រព្រឹត្តកន្លងចិត្តរបស់នាង ប្រគល់ភាពជាធំឱ្យនាងដើម្បីគ្រប់គ្រងកិច្ចការក្នុងផ្ទះ និងផ្តល់គ្រឿងតុបតែងខ្លួនឱ្យនាង។ ពាក្យទូន្មានប្រៀន

ប្រដៅនេះ ព្រះពុទ្ធទ្រង់សម្ដែងអស់រយៈពេលជាងម្ភៃប្រាំសតវត្សកន្លងមកហើយ ហើយនៅតែផ្ដល់គុណប្រយោជន៍រហូតមកដល់សព្វថ្ងៃនេះ។

ដោយដឹងពីចិត្តសាស្ត្ររបស់បុរស ដែលមានទំនោរគិតថា ខ្លួនមានភាពជាធំជាង ព្រះពុទ្ធទ្រង់ធ្វើការផ្លាស់គួរឱ្យកត់សម្គាល់ ហើយបានលើកឋានៈស្ត្រីដោយការផ្ដល់យោបល់សាមញ្ញថា ស្វាមីគប្បីស្មោះត្រង់នឹងប្រពន្ធរបស់ខ្លួន មានន័យថា ស្វាមីគប្បីបំពេញនឹងថែរក្សាកាតព្វកិច្ចប្ដីប្រពន្ធរបស់ខ្លួនចំពោះភរិយា ដោយបន្តទ្រទ្រង់ជំនឿទុកចិត្តក្នុងទំនាក់ទំនងប្ដីប្រពន្ធគ្រប់អត្ថន័យទាំងអស់។ ស្វាមីក្នុងឋានៈជាអាណាព្យាបាល អាចស្នាក់នៅឆ្ងាយពីផ្ទះជាប់ជាប្រចាំ ហេតុដូចនេះ គេគប្បីប្រគល់ភារកិច្ចផ្ទះសំបែងក្នុងគ្រួសារទៅឱ្យភរិយា ជាអ្នកគប្បីគេចាត់ទុកថាជាអ្នកថែរក្សា និងអ្នកចែកចាយទ្រព្យសម្បត្តិ និងជាអ្នកគ្រប់គ្រងសេដ្ឋកិច្ចនៅក្នុងផ្ទះ។ ការផ្ដល់គ្រឿងតុបតែងខ្លួនទៅឱ្យភរិយា គប្បីជានិមិត្តរូបនៃសេចក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ និងការថែទាំរបស់ស្វាមីដែលបង្ហាញភរិយា។ ការអនុវត្តជានិមិត្តរូបនេះ ត្រូវបានអនុវត្តតាំងពីសម័យបរមបុរាណមក នៅក្នុងសហគមព្រះពុទ្ធសាសនា។ ជាអកុសល វាស្ថិតនៅក្នុងគ្រោះថ្នាក់នៃការរលាយសាបសូន្យ ពីព្រោះតែឥទ្ធិពលនៃអរិយធមិសម័យទំនើប។

## អតីតកាល

នៅក្នុងអតីតកាល ដោយសាររចនាសម្ព័ន្ធសង្គមនៃសហគមជាច្រើន

ខុសពីរចនាសម្ព័ន្ធដែលយើងឃើញមានសព្វថ្ងៃ ស្វាមីនិងភរិយាពឹងពាក់គ្នាទៅវិញទៅមក។ មានការដឹងចិត្តថ្លើមទាំងសងខាង ហើយចំណងទាក់ទងមានស្ថេរភាព ពីព្រោះម្នាក់ៗបានដឹងច្បាស់លាស់ពីតួនាទីរបស់ខ្លួននៅក្នុងភាពជាដៃគូ។ "សេចក្តីស្រឡាញ់" ដែលស្វាមីនិងភរិយាមួយចំនួនព្យាយាមបង្ហាញអ្នកដទៃ ដោយអោបរឹតគ្នានៅក្នុងទីប្រជុំជន មិនបានបង្ហាញដោយចាំបាច់ពីសេចក្តីស្រឡាញ់ ឬការយល់ចិត្តពិតប្រាកដនោះទេ។ នៅក្នុងអតីតកាល ទោះបីគូស្រករដែលរៀបការហើយ មិនបានបង្ហាញសេចក្តីស្រឡាញ់ ឬអារម្មណ៍ខាងក្នុងរបស់ពួកគេជាសាធារណៈក៏ដោយ ពួកគេមានការយល់ចិត្តថ្លើមយ៉ាងជ្រាលជ្រៅ ស្ទើរតែមិនអាចនិយាយបាន ព្រមទាំងមានការគោរពគ្នាទៅវិញទៅមក។

ទំនៀមទម្លាប់សម័យបុរាណ ដែលមាននៅក្នុងបណ្តាប្រទេសមួយចំនួន តម្រូវឱ្យភរិយាពលីជីវិតរបស់នាង បន្ទាប់ពីមរណភាពរបស់ស្វាមីនាង និងទំនៀមទម្លាប់ដែលហាមឃាត់ផងដែរ មិនឱ្យភរិយាមេម៉ាយ រៀបការជាថ្មី ទាំងអស់នេះជាទំនៀមទម្លាប់ដែលចម្លែក សម្រាប់ព្រះពុទ្ធសាសនា។ ព្រះពុទ្ធសាសនាមិនចាត់ទុកភរិយា ថាមានឋានៈតូចទាបអន់ជាងស្វាមីនោះទេ។

## សង្គមសម័យបច្ចុប្បន្ន

ស្ត្រីមួយចំនួនមានអារម្មណ៍ថា សម្រាប់ពួកគេ ការផ្តោតយកចិត្តទុក

ដាក់ទៅលើការអប់រំក្នុងគ្រួសារ គឺជាការធ្វើឱ្យអាប់អោនកិត្តិយស និង អភិរក្សនិយម។ ជាការពិតដែលថា នៅក្នុងអតីតកាល ស្ត្រីបានត្រូវគេប្រព្រឹត្តយ៉ាងអាក្រក់បំផុត ប៉ុន្តែនេះអាស្រ័យលើភាពអវិជ្ជមានផ្នែកខាងបុរស ជាងភាពទន់ភ្លន់ដែលមានជាប់មកជាមួយ ក្នុងទស្សនៈនៃការពឹងផ្អែកលើស្ត្រីដើម្បីចិញ្ចឹមកូន។

ស្ត្រីបានធ្វើការតស៊ូអស់រយៈពេលដ៏យូរ ដើម្បីទទួលបានសិទ្ធិស្មើគ្នាជាមួយបុរស ក្នុងវិស័យអប់រំ អាជីពនយោបាយ និងមធ្យោបាយដទៃទៀត។ ឥឡូវនេះ ពួកគេស្មើនឹងបុរស ក្នុងកម្រិតដ៏ធំធេង។ មនុស្សប្រុសជាទូទៅមានទំនោរឈ្លានពានពីធម្មជាតិ ហើយមនុស្សស្រីរំភើបចិត្តខ្លាំងជាង។ នៅក្នុងទិដ្ឋភាពក្នុងគ្រួសារ ជាពិសេសនៅអាស៊ី មនុស្សប្រុសច្រើនប្រើអំណាចខ្លាំងក្នុងឋានៈជាប្រមុខគ្រួសារ ក្នុងខណៈដែលមនុស្សស្រីមានទំនោរនៅជាដៃគូឥតប្រកែកប្រឆាំង។ ចូរចងចាំថា "ឥតប្រកែកប្រឆាំង" ទីនេះ មិនមានន័យថា "ទន់ខ្សោយ" នោះទេ។ ជាការពិតជាង វាជាគុណសម្បត្តិវិជ្ជមាននៃ "ភាពទន់ភ្លន់" និង "ភាពស្លូតបូត"។ បើស្ត្រីនិងបុរសរក្សាគុណសម្បត្តិជាមនុស្សស្រីនិងជាមនុស្សប្រុស ដែលជាកេរមរតកពីធម្មជាតិ ហើយទទួលស្គាល់ កម្លាំងដែលគួរឱ្យគោរពរបស់ពួកគេ អញ្ចឹងអាកប្បកិរិយានោះ អាចជួយផ្តល់នូវការយល់ដឹងទាំងសងខាង ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រវាងភេទទាំងពីរ។

ការកត់សម្គាល់របស់មហាត្មៈគន្ធី ÷

*"ខ្ញុំជឿទៅលើការអប់រំសមរម្យរបស់ស្ត្រី ។ ប៉ុន្តែខ្ញុំពិតជាជឿថាស្ត្រីនឹងមិនចូលរួមចំណែកក្នុងពិភពលោក ដោយធ្វើត្រាប់ ឬរត់ប្រណាំងជាមួយបុរសនោះទេ ។ នាងអាចរត់ប្រណាំង ប៉ុន្តែនាងនឹងមិនឡើងឋានៈខ្ពង់ខ្ពស់ ដែលនាងមានលទ្ធភាពធ្វើបាន ដោយធ្វើត្រាប់តាមបុរស ។ នាងត្រូវតែជាអ្នកបង្គ្រប់របស់បុរស" ។*

## ទំនួលខុសត្រូវរបស់ឪពុកម្តាយ

មូលដ្ឋាននៃសង្គមមនុស្សទាំងអស់ គឺចំណងទាក់ទងសាំញ៉ាំរវាងម្តាយនិងកូន ឪពុកនិងកូន ។ ទោះបីជាយ៉ាងណាក៏ដោយករណីយកិច្ចរបស់មាតា គឺសេចក្តីស្រឡាញ់ ការថែទាំ ការយកចិត្តទុកដាក់ និងការការពារ ។ ព្រះពុទ្ធទ្រង់សម្តែងថា នេះគឺជាសេចក្តីស្រឡាញ់ការលះបង់ ។ វាជាការដែលយកចិត្តទុកដាក់ថែរក្សា ប្រកបដោយចិត្តសប្បុរសនិងមានប្រយោជន៍ហើយជាអនត្តទត្ថបុគ្គល (មិនគិតតែខ្លួនឯង) ។ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀនប្រដៅសាវ័ករបស់ព្រះអង្គថា មាតាបិតាគប្បីរក្សាបុត្រ ប្រៀបដូចផែនដីរក្សារុក្ខជាតិនិងសព្វសត្វទាំងអស់ដូច្នោះដែរ ។

ឪពុកម្តាយ មានទំនួលខុសត្រូវចំពោះសុខុមាលភាព និងការលូតលាស់រីកចម្រើនរបស់កូន ។ បើកូនធំឡើងមានកម្លាំងខ្លាំងក្លា មានសុខភាព

ល្អបរិបូណ៌ និងជាពលរដ្ឋមានប្រយោជន៍ វាជាលទ្ធផលនៃកិច្ចប្រឹងប្រែង របស់ឪពុកម្ដាយហ្នឹងឯង។ បើកូនធំឡើង ប្រព្រឹត្តបទល្មើស ឪពុកម្ដាយត្រូវតែទទួលខុសត្រូវ។ គេមិនត្រូវស្ដីបន្ទោសអ្នកដទៃទៀត ឬសង្គមទេ បើកូនដើរផ្លូវខុស។ វាជាករណីយកិច្ចរបស់ឪពុកម្ដាយ ត្រូវតែណែនាំកូនឱ្យដើរតាមផ្លូវល្អសមរម្យ។

ស្ថិតនៅក្នុងវ័យងាយធ្វើឱ្យរំភើបបំផុតរបស់វា ក្មេងត្រូវការទំនោរសេចក្ដីស្រឡាញ់ ការថ្នាក់ថ្នម និងការយកចិត្តទុកដាក់ពីឪពុកម្ដាយ។ បើគ្មានសេចក្ដីស្រឡាញ់និងការណែនាំពីឪពុកម្ដាយគេ ក្មេងនឹងមានចិត្តវិកលហើយមើលថា ពិភពលោកគឺជាកន្លែងឡប់សតិដើម្បីរស់នៅ។ ទោះបីយ៉ាងណាក៏ដោយ ការបង្ហាញសេចក្ដីស្រឡាញ់ ការថែរក្សាថ្នាក់ថ្នម ការយកចិត្តទុកដាក់របស់ឪពុកម្ដាយ មិនមែនមានន័យថា ផ្គាប់ចិត្តការទាមទាររបស់កូនទាំងអស់ ទោះសមហេតុផល ឬយ៉ាងណានោះទេ។ ការថ្នាក់ថ្នមច្រើនពេក អាចនាំឱ្យកូនទំរើស។ នៅក្នុងការផ្ដល់សេចក្ដីស្រឡាញ់ និងការថ្នាក់ថ្នមរបស់នាង ម្ដាយគប្បីតឹងរឹងនិងរឹងមាំក្នុងការដោះស្រាយ កំហឹងនិងការម៉ូរម៉ៅរបស់កូន។ ការធ្វើតឹងរឹងនិងរឹងមាំហ្មត់ចត់ មិនមានន័យថា ប្រើពាក្យអាក្រក់ មិនពិរោះស្ដាប់ ដាក់កូននោះទេ។ ចូរបង្ហាញសេចក្ដីស្រឡាញ់របស់អ្នក ប៉ុន្តែចូរបង្អង់ដៃអប់រំធ្វើឱ្យមានវិន័យ កូននឹងយល់ចិត្ត។

ជាអកុសល ក្នុងចំណោមឪពុកម្ដាយបច្ចុប្បន្ន សេចក្ដីស្រឡាញ់របស់

ឪពុកម្ដាយចំពោះកូន គឺមានតិចតួចគួរឱ្យសោកស្ដាយ។ ការងប់ងល់ ការភ្លើតភ្លើន ប្រញាប់ប្រញាល់ចង់បានការរីកចម្រើនផ្នែកសម្ភារៈ ចលនាចង់បានសេរីភាព និងការប្រាថ្នាចង់បានសិទ្ធិស្មើគ្នា បានបណ្ដាលឱ្យមាតាជាច្រើន រួមនឹងស្វាមីរបស់ពួកគេ ចំណាយពេលធ្វើការនៅក្នុងការិយាល័យ និងហាងលក់ទំនិញច្រើនម៉ោង ជាងការនៅផ្ទះដោយទំនោរទៅរកការបន្តពូជរបស់ពួកគេ។ ក្មេងដែលគេបានផ្ញើរសាច់ញាតិឱ្យមើលថែរក្សា ឬជួលអ្នកបម្រើឱ្យមើល មានការឡប់ស្មារតីបដិសេធមិនទទួលសេចក្ដីស្រឡាញ់ និងការថ្នាក់ថ្នមរបស់ម្ដាយ។ ម្ដាយដែលមានអារម្មណ៍ថាមានកំហុសដោយខ្វះខាតការយកចិត្តទុកដាក់ចំពោះកូន ក៏ព្យាយាមធ្វើឱ្យកូនស្ងប់ដោយផ្ដល់គ្រប់ប្រភេទទាំងអស់នៃការទាមទារពីកូន។ អំពើបែបនេះធ្វើឱ្យកូនទំយើទំរើស។ ការឱ្យកូននូវល្បែងក្មេងលេងទំនើបៗគ្រប់ប្រភេទទាំងអស់ មានដូចជារថក្រោះជ័រ កាំភ្លើងវែង កាំភ្លើងខ្លីធ្វើពីជ័រ ដាវជ័រ និងឧបករណ៍ស្រដៀងគ្នាបែបជាការធ្វើឱ្យស្ងប់ចិត្ត គឺជាប្រការមិនល្អទាល់តែសោះ នេះបើពោលតាមបែបចិត្តសាស្ត្រ។

ការផ្ទុកផ្ដាក់កូនជាមួយល្បែងក្មេងលេងបែបនេះ មិនមែនជាវត្ថុជំនួសឱ្យទំនោរសេចក្ដីស្រឡាញ់និងសុឆន្ទៈរបស់មាតានោះទេ។ បើគ្មានសុឆន្ទៈនិងការណែនាំពីឪពុកម្ដាយសោះ វាមិនជាការគួរឱ្យភ្ញាក់ផ្អើលនោះទេ បើកូនជាផលវិបាកធំឡើងប្រព្រឹត្តបទល្មើសនោះ។ ដូច្នេះ តើគេត្រូវស្ដី

បន្ទោសនរណាចំពោះការចិញ្ចឹមកូន ចចេស មានះ មុខរឹង? ឪពុកម្ដាយមែនទេ! ម្ដាយដែលធ្វើការ ជាពិសេសបន្ទាប់ពីធ្វើការងារច្រើនពេញមួយថ្ងៃនៅការិយាល័យ ហើយបំពេញការងារកំប៉ិចកំប៉ុកនៅផ្ទះទៀត មិនអាចរកពេលវេលាសម្រាប់ផ្ដល់ឱ្យកូនដែលចង់បានការថ្នាក់ថ្នម និងការយកចិត្តទុកដាក់ពីនាងបានទេ។ ឪពុកម្ដាយដែលគ្មានពេលវេលាសម្រាប់កូនទាំងឡាយរបស់ពួកគេ គប្បីកុំត្អូញត្អែរ ពេលកូនជំពូកនេះ គ្មានសម្រាប់ពួកគេពេលពួកគេមានវ័យចំណាស់។ ឪពុកម្ដាយដែលប្រកាសថា ពួកគេចំណាយប្រាក់កាសច្រើនសន្ធឹកសន្ធាប់លើកូនទាំងឡាយរបស់ពួកគេ ប៉ុន្តែរវល់គ្មានពេលនៅថែទាំកូន មិនគួរត្អូញត្អែរ ពេលកូនទាំងឡាយ "ដែលមមាញឹក" របស់ពួកគេ ជាការតបស្នងសងគុណ បានទុកពួកគេឱ្យនៅក្នុងគ្រឹះស្ថានសម្រាប់មនុស្សចាស់!

សព្វថ្ងៃនេះ ស្ត្រីភាគច្រើនមានការងារធ្វើ ដូច្នេះហើយគ្រួសារអាចរីករាយនឹងប្រយោជន៍ផ្នែកសម្ភារៈកាន់តែច្រើន។ ស្ត្រីទាំងឡាយគប្បីពិចារណា ពាក្យទូន្មានរបស់មហាត្មៈគន្ធីចំពោះបុរសដែលស្វែងរកសេរីភាពពីសេចក្ដីលោភលន់ ជាងសេរីភាពពីសេចក្ដីត្រូវការឱ្យបានម៉ត់ចត់។ ពិតណាស់ ដោយទទួលបានគម្រោងរៀបចំផ្នែកសេដ្ឋកិច្ចសម្រាប់ពេលបច្ចុប្បន្ន យើងមិនអាចបដិសេធថា ស្ត្រីមួយចំនួនមិនត្រូវគេបង្ខំឱ្យធ្វើការនោះទេ។ ក្នុងករណីបែបនេះ ឪពុកនិងម្ដាយ ត្រូវតែធ្វើពលិកម្មអំពីពេលវេលាបន្ថែម

របស់ពួកគេ ដើម្បីសងជម្ងឺចិត្ត សម្រាប់អ្វីដែលកូនរបស់ពួកគេខកចិត្ត ពេលពួកគេនៅឆ្ងាយ ។ បើឪពុកម្ដាយទាំងពីរនាក់ចំណាយពេលវេលាមិនធ្វើការរបស់ពួកគេសម្រាប់នៅផ្ទះជាមួយកូនៗរបស់ពួកគេ នឹងមានការយល់ចិត្តគ្នាកាន់តែច្រើនឡើង រវាងឪពុកម្ដាយនឹងកូន ។

នៅក្នុងព្រះសូត្រទាំងឡាយរបស់ព្រះអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងលំអិតអំពីតួនាទីនិងភារកិច្ចដើមដំបូងមួយចំនួន ជាគោលការណ៍ណែនាំសំខាន់ៗ សម្រាប់ឪពុកម្ដាយយកទៅប្រតិបត្តិ ។ ដោយការប្រៀនប្រដៅ ការអនុវត្ត និងសកម្មភាព គោលការណ៍ណែនាំមួយក្នុងចំណោមគោលការណ៍ដើមដំបូងទាំងឡាយ គឺដឹកនាំកូនកុំឱ្យធ្វើអំពើអាក្រក់ និងតាមរយៈការបញ្ចុះបញ្ចូលលួងលោម ណែនាំពួកគេឱ្យធ្វើតែអំពើល្អគ្រប់បែបយ៉ាង ដើម្បីគ្រួសារ សង្គម និងប្រទេសជាតិ ។ នៅក្នុងការជាប់ទាក់ទិនបញ្ហានេះ ឪពុកម្ដាយ គប្បីប្រើការយកចិត្តទុកដាក់ឱ្យបានធំធេង ក្នុងការទំនាក់ទំនងជាមួយកូន ។ វាមិនមែនជាអ្វីដែលឪពុកម្ដាយហ្វឹកហាត់នោះទេ ប៉ុន្តែជាអ្វីដែលឪពុកម្ដាយមាននិងធ្វើពិតប្រាកដ ដែលកូនស្រូបយកដោយមិនដឹងខ្លួន និងដោយការអាណិតស្រឡាញ់ ។ ការចូលខ្លួនរបស់កូនទៅក្នុងពិភពលោក ត្រូវបានអប់រំនិស្ស័យដោយការប្រឹងធ្វើឱ្យដូច ឬឱ្យលើសអាកប្បកិរិយារបស់ឪពុកម្ដាយ ។ វាស្របទៅតាមតែអាកប្បកិរិយាល្អបណ្ដាលឱ្យល្អហើយអាកប្បកិរិយាអាក្រក់បណ្ដាលឱ្យអាក្រក់ ។ ឪពុកម្ដាយ

នៅជាមួយកូនរបស់ពួកគេបានច្រើន និងបញ្ជូនយ៉ាងប្រសប់នូវអត្តចរិតផ្ទាល់ទៅឱ្យកូនចៅរបស់ពួកគេ។

## ករណីយកិច្ចរបស់ឪពុកម្តាយ

វាជាករណីយកិច្ចរបស់ឪពុកម្តាយ ក្នុងការមើលថែទាំសុខុមាលភាពរបស់កូនពួកគេ។ តាមការពិត ឪពុកម្តាយដែលប្រកបដោយករណីយកិច្ច និងសេចក្តីស្រឡាញ់ រែកពុនការទទួលខុសត្រូវដោយរីករាយ។ ដើម្បីដឹកនាំកូនឱ្យដើរលើផ្លូវត្រូវ (ប្រកបដោយគន្លងធម៌) ដំបូងឪពុកម្តាយគប្បីធ្វើជាគំរូនិងដឹកនាំជីវិតប្រកបដោយឧត្តមគតិ។ ជាប្រការស្ទើរតែមិនអាច នឹងរំពឹងឱ្យមានកូនបរិបូណ៌ដោយតម្លៃ ពីឪពុកម្តាយគ្មានតម្លៃ។ ក្រៅពីទំនោរកម្មជាមរតករបស់កូនតាំងពីជាតិមុន កូនទាំងឡាយក៏ទទួលមរតកមិនផ្លាស់ប្តូរ នូវគុណវិបត្តិនិងគុណធម៌របស់ឪពុកម្តាយផងដែរ។ ឪពុកម្តាយមានទំនួលខុសត្រូវ គប្បីប្រុងប្រយ័ត្នជាមុនគ្រប់បែបយ៉ាង កុំធ្វើទំនោរដែលមានផលវិបាក ទៅឱ្យកូនចៅរបស់ផងខ្លួន។

នៅក្នុង**សិគាលោវាទសូត្រ** មានករណីយកិច្ចប្រាំស្ថានដែលមាតាបិតាគប្បីបំពេញ ÷

**ករណីយកិច្ចស្ថានទីមួយ គឺឃាត់ឃាំងបុត្រធីតាកុំឱ្យធ្វើអំពើអាក្រក់។**

ផ្ទះគឺជាសាលារៀនទីមួយ ហើយមាតាបិតា គឺជាបុព្វាចារ្យគ្រូបង្រៀន

ទីមួយ ។ បុត្រធីតាតែងតែរៀនមេរៀនបឋមស្តីអំពីអំពើល្អនិងអំពើអាក្រក់ពីមាតាបិតារបស់ពួកគេ ។ មាតាបិតាគ្មានការយកចិត្តទុកដាក់ ផ្តល់ចំណេះដឹងជាន់ដំបូងដោយផ្ទាល់និងដោយប្រយោល មានដូចជា ការនិយាយកុហក ការបោកប្រាស ការមិនស្មោះត្រង់ ការនិយាយមូលបង្កាច់ គំនុំគុំគួន ការសងសឹក ការគ្មានការអៀនខ្មាស និងការភ័យខ្លាចក្នុងការប្រព្រឹត្តអំពើអាក្រក់និងអសីលធម៌ ទៅឱ្យបុត្រធីតារបស់ពួកគេ អំឡុងវ័យកុមារភាព ។

មាតាបិតាគប្បីបង្ហាញគំនិតមារយាទគួរយកជាគំរូ និងមិនគួរបញ្ជូនគុណវិបត្តិទាំងឡាយខាងលើទៅក្នុងចិត្ត ដែលងាយទទួលយកដោយអារម្មណ៍របស់បុត្រធីតាឡើយ ។

**ករណីយកិច្ចស្ថានទីពីរ គឺបញ្ចុះបញ្ចូលបុត្រធីតាឱ្យតាំងនៅក្នុងអំពើល្អ ។**

មាតាបិតា ជាគ្រូអាចារ្យនៅផ្ទះ គ្រូអាចារ្យ ជាមាតាបិតានៅសាលារៀន ។ ទាំងមាតាបិតាទាំងគ្រូអាចារ្យ ទទួលខុសត្រូវចំពោះសុខុមាលភាពអនាគតរបស់កុមារ ដែលនឹងក្លាយទៅជាអ្វីដែលពួកគេត្រូវបាន ។ ពួកគេធ្វើ ឬពួកគេនឹងធ្វើនូវអ្វីដែលមនុស្សពេញវ័យធ្វើ ។ ពួកគេអង្គុយនៅជិតជើងរបស់មនុស្សពេញវ័យ ពេលកំពុងមានវ័យងាយទទួលយកអារម្មណ៍ ។ ពួកគេស្រូបយកអ្វីៗដែលពួកគេបានទទួល ។ ពួកគេដើរតាមស្នាមជើងមនុស្សពេញវ័យ ។ ពួកគេត្រូវទទួលឥទ្ធិពលពីសំណាក់ការគិត ការនិយាយ និងអំពើទាំងឡាយរបស់មនុស្សពេញវ័យ ។ ក្នុងលក្ខណៈបែបនេះ

ជាករណីយកិច្ចរបស់មាតាត្រូវបង្កើតបរិយាកាសគួរឱ្យចូលចិត្តបំផុត ទាំងនៅផ្ទះ ទាំងនៅសាលារៀន។

ភាពងាយស្រួល ការស្តាប់បង្គាប់ សហប្រតិបត្តិការ ឯកភាព ការលើកទឹកចិត្ត ការលះបង់ ការស្មោះត្រង់ ភាពត្រង់ទៅវិញទៅមក ការបម្រើប្រយោជន៍ ការទុកចិត្តខ្លួនឯង ការចូលចិត្តធ្វើល្អ ការសំថៃ ការសន្តោស ឬកពារល្អ ការជាប់ចិត្តខាងសាសនា និងគុណធម៌ផៅពង្ស ដទៃទៀត គួរត្រូវបានបណ្តុះគំនិតបណ្តុះនិស្ស័យ នៅក្នុងចិត្តរបស់យុវភាព បន្តិចម្តងៗ។ គ្រាប់ពូជដាំដុះបានល្អ នឹងលូតលាស់ជាលំដាប់ ក្លាយជាដើមឈើផ្តល់ផ្លែផ្កា។

**ករណីយកិច្ចស្ថានទីបី គឺ ផ្តល់ការអប់រំល្អដល់បុត្រធីតា។**

ការអប់រំគ្រប់គ្រាន់ ជាមរតកប្រសើរបំផុតដែលមាតាបិតាអាចចែកឱ្យដល់បុត្រធីតា។ គ្មានរតនសម្បត្តិណាដទៃ មានតម្លៃជាងការអប់រំនោះទេ។ វាជាការប្រសិទ្ធិពរជ័យដែលមាតាបិតាអាចប្រគល់ឱ្យបុត្រធីតា។

មាតាបិតា គប្បីផ្តល់ការអប់រំដល់បុត្រធីតា ល្អបំផុតតាំងពីវ័យនៅក្មេង នៅក្នុងបរិយាកាសសាសនា។ នេះមានផលវែងឆ្ងាយ លើជីវិតរស់នៅរបស់ពួកគេ។

**ករណីយកិច្ចស្ថានទីបួន គឺ រកភរិយាស្វាមីដ៏សមគួរអោយ។**

អាពាហ៍ពិពាហ៍ ជាការស្បថស្បែ ទាក់ទងនឹងជីវិតទាំងមូល ការរួប

រួមនេះ គឺជាការរួមមួយដែលមិនអាចធ្វើឱ្យរលាយបាត់ទៅងាយៗទេ។ ដូច្នេះហើយ គេត្រូវតែសង្កេតមើលអាពាហ៍ពិពាហ៍ឱ្យគ្រប់ជ្រុងជ្រោយ និង គ្រប់ទិដ្ឋភាពរបស់វា ដើម្បីឱ្យមានសេចក្ដីពេញចិត្ត ពីគ្រប់ភាគីទាំងអស់ មុនរៀបអាពាហ៍ពិពាហ៍។

តាមវប្បធម៌ព្រះពុទ្ធសាសនា ករណីយកិច្ចប្រគល់ឱ្យសិទ្ធិលើសលុប។ ចូរកុំទុកឱ្យភាគីទាំងពីរចចេសរឹងរូស ប៉ុន្តែអនុញ្ញាតឱ្យប្រើប្រាស់សេរីភាព ក្នុងការសម្រេចប្រកបដោយគតិបណ្ឌិតរបស់ពួកគេ ហើយចាប់ផ្ដើមដោះស្រាយប្រកបដោយការយោគយល់។ បើមិនដូច្នេះទេ នឹងមានការនិយាយស្ដីបន្ទោសទាំងសងខាង ព្រមទាំងការប៉ះទង្គិចផ្សេងៗទៀត។ ជារឿយៗ មិនអត់ ការធ្វើឱ្យខូច ត្រូវបានបញ្ជូនទៅឱ្យកូនចៅផងដែរ។

**ករណីយកិច្ចស្ថានទីប្រាំ គឺប្រគល់ទ្រព្យសម្បត្តិឱ្យបុត្រធីតាក្នុងសម័យដ៏គួរ។**

មាតាបិតាមិនត្រឹមតែស្រលាញ់ និងមានទំនោរទៅលើបុត្រធីតារបស់ពួកគេ ដរាបណាពួកគេនៅតែស្ថិតនៅក្នុងការគ្រប់គ្រងរបស់ពួកគេ ថែមទាំងរៀបចំអនាគតសម្រាប់ពួកគេប្រកបដោយសេចក្ដីសុខស្រួល និងមានសុភមង្គលទៀតផង។ មាតាបិតាសន្សំទ្រព្យទុក ក្នុងសភាពលំបាកលំបិនផ្ទាល់ខ្លួន ហើយប្រគល់ទ្រព្យសម្បត្តិទាំងនោះទុកជាមរតក ឱ្យបុត្រធីតារបស់ពួកគេ ដោយពេញចិត្តដោយឥតច្រណែនគុំគួន។

## សាសនានៃករុណាធម៌

ព្រះពុទ្ធសាសនា ជាសាសនានៃករុណាធម៌ ដូច្នេះមាតាបិតាគប្បីកុំភ្លេចបង្ហាត់បង្ហាញព្រះពុទ្ធសាសនាដល់បុត្រធីតា ដូចដែលបានពោលមកហើយ ខាងលើស្រាប់។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងព្រះធម៌ដោយករុណាសម្រាប់ពិភពលោក។ មាតាបិតាគប្បីប្រតិបត្តិ "ព្រហ្មវិហារធម៌បួន" ដែលព្រះពុទ្ធទ្រង់ត្រាស់សម្ដែង ក្នុងការចិញ្ចឹមបីបាច់ថែរក្សាបុត្រធីតារបស់ខ្លួន។

**ព្រហ្មវិហារធម៌បួននោះ គឺ** ÷

- **មេត្តា** ការស្រឡាញ់រាប់អានដោយស្និទ្ធចំពោះមនុស្សសត្វទាំងអស់។
- **ករុណា** ការអាណិតអាសូរមនុស្សសត្វដែលមានទុក្ខ។
- **មុទិតា** សេចក្ដីត្រេកអរទោរទន់ចំពោះមនុស្សសត្វដែលបានសុខ។
- **ឧបេក្ខា** ការតាំងចិត្តជាកណ្ដាលចំពោះមនុស្សសត្វ។

ការផ្សាយធម៌ទាំងបួនបានល្អ នឹងជួយមាតាបិតារក្សាបានការស្ងប់ស្ងាត់ មិនឆេវឆាវ ក្នុងអំឡុងពេលលំបាកលំបិនក្នុងការចិញ្ចឹមបីបាច់ថែរក្សាបុត្រធីតា។

នេះគឺជាវិធីប្រព្រឹត្តិត្រឹមត្រូវ ឬមានឧត្ដមគតិចំពោះសព្វសត្វ។ អាកប្បកិរិយានៃចិត្តទាំងបួននេះ ផ្ដល់នូវក្របខ័ណ្ឌការងារគ្រប់ស្ថានការណ៍ទាំងអស់ដែលបានកើតឡើងពីការទាក់ទងក្នុងសង្គម។ ព្រហ្មវិហារធម៌បួនជាអ្នករំលាយភាពតានតឹងដ៏ឆ្នើម ជាអ្នករកសន្តិភាពដ៏ឆ្នើមនៅក្នុងជម្លោះ

សង្គម ជាគ្រូពេទ្យព្យាបាលរបួសដែលបង្កមកពីការតស៊ូដើម្បីមានជីវិតដ៏ពូកែ ជាអ្នករំលាយរបាំងសង្គម ជាអ្នកកសាងស្ពាបនាសហគមមានការស្រុះស្រួលគ្នា ជាអ្នកដាស់ឱ្យភ្ញាក់នៃការដេកលង់លក់នៃចិត្តអធ្យាស្រ័យដែលបានភ្លេចជាយូរមកហើយ ជាអ្នកធ្វើឱ្យស្រស់ឡើងវិញនៃសោមនស្សចិត្ត និងសេចក្តីសង្ឃឹមដែលបានបោះបង់ចោលជាយូរហើយ និងជាអ្នកស្ថាបនិកភាតរភាពប្រឆាំងនឹងកម្លាំងអហង្ការនិយម ។

ប្រហែលជា ការធ្វើឱ្យខិតខំអស់ពីសមត្ថភាព ដែលគូស្រករដែលរៀបការហើយ ត្រូវប្រឈមមុខនោះគឺ ការផ្តល់ការអប់រំសមរម្យឱ្យបុត្រធីតា។ នេះជាទិដ្ឋភាពមួយផ្សេងទៀត ដែលធ្វើឱ្យឃើញថា យើងប្លែកពីសត្វ។ ក្នុងខណៈដែល សត្វពិតជាថែរក្សាការបន្តពូជរបស់វា ដោយភក្តីភាពដ៏ធំ មាតាបិតាមនុស្សមានទំនួលខុសត្រូវកាន់តែធំជាងដែលកំពុងថែរក្សានៅក្នុងចិត្ត។ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា ការខិតខំដ៏ធំធេងបំផុតដែលបុរសត្រូវប្រឈមមុខ គឺការផ្សាំងចិត្ត។ តាំងតែពីបុត្រធីតាបានប្រសូត្រមក ពីកុមារទៅដល់ពេញរូបពេញរាង រហូតក្លាយជាមាតាបិតាគេ ឪពុកទទួលខុសត្រូវជាដំបូងលើការអភិវឌ្ឍចិត្តគំនិតរបស់កូន។ មនុស្សម្នាក់ក្លាយជាពលរដ្ឋល្អ ឬអត់ អាស្រ័យសំខាន់លើទំហំចិត្តគំនិតដែលបានលូតលាស់។ នៅក្នុងព្រះពុទ្ធសាសនា ឪពុកល្អអាចផ្សាយគុណធម៌ដ៏ខ្ពង់ខ្ពស់ទាំងបួន ដើម្បីទប់កូនឱ្យនឹង ហើយយកឈ្នះលើការខូចចិត្តដ៏ធំ ដែលមាន

ទំនាក់ទំនងយ៉ាងជិតស្និទ្ធក្នុងភាពជាឪពុក ។

ពេលកូនប្រុសស្រី នៅជាកូនក្មេងនៅឡើយ វាមិនអាចបង្ហាញសេចក្តីត្រូវការរបស់វាបានទេ ពិតជាពិបាកបំពេញបំណងទៅតាមការម៉ូរម៉ៅនិងការយំយែករបស់វាណាស់ ។ ឪពុកឬម្តាយដែលមានព្រហ្មវិហារធម៌ទីមួយគឺមេត្តា អាចរក្សាភាពស្ងប់ស្ងាត់នៅក្នុងចិត្ត ដើម្បីបន្តស្រឡាញ់កូនពេលកំពុងលំបាកខ្លាំង ។ កូនដែលទទួលបានផលនៃមេត្តាធម៌នេះ នឹងរៀនផ្សាយមេត្តាធម៌ ដោយការស្ម័គ្រចិត្តដោយខ្លួនឯង ។

ពេលកូនក្លាយខ្លួនពេញលក្ខណៈជាមនុស្សពេញវ័យ មាតាបិតាគប្បីប្រតិបត្តិករុណាធម៌ចំពោះបុត្រធីតា ។ វ័យពេញរូបរាង ជាពេលវេលាពិបាកបំផុត សម្រាប់បុត្រធីតា ។ ពួកគេកំពុងព្រមព្រៀមគ្នាជាមួយភាពពេញវ័យ ហេតុនេះហើយ ពួកគេមិនឱ្យគ្រប់គ្រងបាន ដោយមានកំហឹង និងការខូចចិត្តច្រើនដាក់មាតាបិតា ។ ដោយមានករុណាធម៌ មាតាបិតានឹងដឹងថា ភាពមិនឱ្យគេគ្រប់គ្រងបានដោយងាយ នេះគឺជាផ្នែកធម្មជាតិមួយនៃការលូតលាស់ធំធាត់ព្រមទាំងដឹងថា បុត្រធីតាមិនមានបំណងធ្វើឱ្យមាតាបិតារបស់ពួកគេឈឺចាប់ដោយតាំងចិត្តនោះទេ ។ បុត្រធីតាណាម្នាក់ដែលបានទទួលយកមេត្តាធម៌ នឹងក្លាយជាមនុស្សល្អប្រសើរដោយខ្លួនឯង ។ ដោយមិនមានសេចក្តីស្អប់កើតមានចំពោះបុត្រធីតា បុត្រធីតានោះ នឹងផ្សាយសេចក្តីស្រឡាញ់និងករុណាធម៌ដល់អ្នកដទៃ ។

ដោយគ្រាន់តែបានក្លាយជាមនុស្សពេញវ័យម្នាក់ បុត្រធីតានឹងអាចជួបប្រទះជោគជ័យមួយចំនួនក្នុងការប្រឡង និងសកម្មភាពដទៃទៀតខាងក្រៅផ្ទះ។ នេះជាពេលវេលាសម្រាប់មាតាបិតាប្រតិបត្តិមុទិតាធម៌។ មាតាបិតាជាច្រើនណាស់នៅក្នុងសង្គមបច្ចុប្បន្ន ប្រើបុត្រធីតារបស់ពួកគេឱ្យប្រកួតប្រជែងជាមួយមនុស្សដែលធ្លាប់រាប់រករបស់ពួកគេ។ មាតាបិតាចង់ឱ្យបុត្រធីតារបស់ពួកគេពូកែដោយសារហេតុផលអត្តទត្ថបុគ្គល សរុបមកពួកគេចង់ឱ្យអ្នកដទៃគិតល្អអំពីបុត្រធីតារបស់ពួកគេ។ ដោយប្រតិបត្តិមុទិតាធម៌ មាតាឬបិតានឹងត្រេកអរជាខ្លាំងចំពោះជោគជ័យនិងសុភមង្គលរបស់បុត្រធីតារបស់គាត់ ដោយគ្មានចិត្តជំរុញអាថិកំបាំង។ ជាធម្មតា មាតាបិតាសប្បាយចិត្ត ព្រោះបុត្រធីតារបស់ពួកគេសប្បាយចិត្ត។ បុត្រធីតាដែលបានលាតត្រដាងផលនៃមុទិតាធម៌ឱ្យដឹង នឹងក្លាយដោយខ្លួនឯងជាបុគ្គលមិនច្រណែនអ្នកដទៃ និងជាអ្នកមិនចូលចិត្តប្រកួតប្រជែងហួសពេកនោះទេ។ មនុស្សប្រភេទនេះ នៅក្នុងបេះដូងរបស់គេនឹងមិនមានកន្លែងសម្រាប់អត្តទត្ថភាព លោភៈ និងទោសៈទេ។

ពេលបុត្រធីតាឈានចូលដល់មនុស្សពេញវ័យ ហើយមានមុខរបរការងារនិងគ្រួសារផ្ទាល់របស់គេ មាតាបិតាគប្បីប្រតិបត្តិព្រហ្មវិហារធម៌ចុងក្រោយគឺឧបេក្ខា។ ឧបេក្ខាធម៌នេះជាធម៌មួយក្នុងធម៌ពិបាកបំផុតសម្រាប់មាតាបិតានៅអាស៊ីប្រតិបត្តិ។ ពិបាកសម្រាប់ពួកគេ ដើម្បីអនុញ្ញាតឱ្យ

បុត្រធីតារបស់ពួកគេ ក្លាយជាអ្នកម្ចាស់ការក្នុងការប្រើសិទ្ធិផ្ទាល់របស់ពួកគេ។ ពេលមាតាបិតាប្រតិបត្តិឧបេក្ខាធម៌ ពួកគេនឹងមិនជ្រៀតជ្រែកកិច្ចការរបស់បុត្រធីតា និងមិនអត្តទត្តនិយមក្នុងការទាមទារពេលវេលានិងការយកចិត្តទុកដាក់ច្រើនជាង បុត្រធីតាអាចផ្តល់ឱ្យនោះទេ។ មនុស្សពេញវ័យក្មេងៗនៅក្នុងសង្គមសម័យទំនើប មានបញ្ហាច្រើន។ មាតាឬបិតាដែលយល់ចិត្តគូស្រករថ្មីថ្មោង មិនគួរគប្បីដាក់បន្ទុកបន្ថែមទៀត ដោយធ្វើសេចក្តីទាមទារមិនចាំបាច់ដល់ពួកគេទេ។ សំខាន់បំផុត មាតាបិតាដែលមានវ័យចាស់ គប្បីព្យាយាមកុំធ្វើឱ្យបុត្រធីតាដែលរៀបអាពាហ៍ពិពាហ៍ហើយមានអារម្មណ៍ ថាមានកំហុស ដោយធ្វើឱ្យពួកគេមានអារម្មណ៍គិតថាពួកគេមិនបានអើពើនិងកាតព្វកិច្ចក្នុងនាមជាកូន។ បើមាតាបិតាប្រតិបត្តិឧបេក្ខាធម៌ ពួកគេនឹងនៅស្ងប់ស្ងៀមក្នុងវ័យចាស់ជរារបស់ពួកគេ ហើយដោយហេតុនេះ មាតាបិតាទទួលបានការគោរពអំពីកូនចៅជំនាន់ក្រោយ។

ពេលមាតាបិតាផ្សាយព្រហ្មវិហារធម៌ទាំងបួននេះ ចំពោះបុត្រធីតារបស់ពួកគេ បុត្រធីតានឹងធ្វើតបដោយគាប់ចិត្ត ហើយបរិយាកាសរីករាយរាក់ទាក់ នឹងកើតមានជាទូទៅនៅក្នុងផ្ទះ។ ផ្ទះដែលមានមេត្តា ករុណា មុទិតា និងឧបេក្ខាធម៌ នឹងជាផ្ទះមានសុភមង្គល។ បុត្រធីតាដែលធំធាត់ក្រោមបរិស្ថានបែបនេះ នឹងលូតលាស់ធំឡើងនិងក្លាយជាអ្នកធ្វើការ ចេះយល់ចិត្ត ចេះអាណិតអាសូរ មានឆន្ទៈ និងជាបុគ្គលចេះគិតដល់អ្នកដទៃ។

នេះគឺជាមរតកដ៏ធំធេងបំផុតដែលមាតាបិតាណា ក៏អាចផ្ដល់ឱ្យបុត្រធីតារបស់ខ្លួនបានដែរ ។

## មាតាបិតានៅក្នុងសង្គមសម័យទំនើប

រឿងមួយក្នុងចំណោមរឿង គួរឱ្យសោកសៅបំផុតរបស់សង្គមសម័យទំនើប គឺការខ្វះខាតសេចក្ដីស្រឡាញ់របស់ឪពុកម្ដាយ ដែលកូននៅបណ្ដាប្រទេសឧស្សាហកម្មរីកចម្រើនរងគ្រោះ ។ ពេលគូស្រករជ្រៀបអាពាហ៍ពិពាហ៍ ជាធម្មតាពួកគេមានគម្រោងចង់បានកូនច្រើន ។ ហើយនៅពេលកូនប្រសូតមក ឪពុកម្ដាយតម្រូវឱ្យថែរក្សាកូនប្រកបដោយសីលធម៌តាមសមត្ថភាពប្រសើរបំផុតរបស់ពួកគេ ។ មាតាបិតាមានទំនួលខុសត្រូវមើលថាកូនមិនត្រឹមតែបំពេញបំណងជាសម្ភារៈនោះទេ ទស្សនវិស័យផ្នែកប្រាជ្ញាស្មារតីនិងចិត្តសាស្ត្រក៏សំខាន់ណាស់ដែរ ។

ការផ្ដល់សេចក្ដីសុខស្រួលផ្នែកសម្ភារៈ ជាសារៈសំខាន់ទីពីរ បើប្រៀបធៀបទៅនឹងការផ្ដល់សេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់របស់ឪពុកម្ដាយ ។ យើងបានដឹងអំពីមាតាបិតាជាច្រើនមកពីគ្រួសារមិនសូវធូរធា ជាអ្នកបានចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អ ហើយសម្បូណ៌សេចក្ដីស្រឡាញ់ទៀតផង ។ ម្យ៉ាងទៀត គ្រួសារមានទ្រព្យសម្បត្តិជាច្រើន បានផ្ដល់សេចក្ដីសុខស្រួលផ្នែកសម្ភារៈគ្រប់បែបយ៉ាងសម្រាប់កូនរបស់ពួកគេ

ប៉ុន្តែខ្វះខាតមិនបានផ្តល់ឱ្យពួកគេ នូវសេចក្តីស្រឡាញ់របស់ឪពុកម្តាយ។ កូនទាំងឡាយបែបនេះ ត្រឹមតែធំធាត់ឡើងគ្មានការរីកចម្រើនផ្នែកចិត្តសាស្ត្រនិងសីលធម៌សោះ។

មាតាម្នាក់ៗ គប្បីពិចារណាដោយប្រុងប្រយ័ត្នថា តើគួរបន្តក្នុងភាពជាមាតាធ្វើការ ឬជាមេផ្ទះដែលផ្តល់សេចក្តីស្រឡាញ់និងការថែទាំគ្រប់បែបយ៉ាង ដើម្បីសុខុមាលភាពរបស់កូនកំពុងធំធាត់របស់នាង។ (យ៉ាងចម្លែក មាតាសម័យទំនើបមួយចំនួន ក៏បានហ្វឹកហាត់កូនផងដែរឱ្យកាន់កាំភ្លើងនិងឧបករណ៍បណ្តាលឱ្យស្លាប់ដទៃទៀត ពេលពួកគេគួរថ្នាក់ថ្នមកូននិងបង្ហាត់បង្រៀនកូនឱ្យក្លាយជាពលរដ្ឋល្អ ជាពលរដ្ឋគោរពច្បាប់)។

និន្នាការនិងអត្តចរិតសម័យទំនើប របស់មាតាដែលធ្វើការងារចំពោះកូនៗរបស់ពួកគេ មានទំនោរផងដែរទៅរកការកាត់ការស្រឡាញ់និងគោរពសាសនារបស់កូន ដែលគេគោរពដ៏យូរលង់មកហើយដែលគេសង្ឃឹមថាកូនៗនឹងប្រស់ព្រំមាតាបិតារបស់ពួកគេ។ ការផ្លាស់ប្តូរការចិញ្ចឹមកូនដោយទឹកដោះ ដោយការចិញ្ចឹមឱ្យបៅទឹកដោះគោក្នុងកំប៉ុង អាចជាកត្តាមួយផ្សេងទៀតផងដែរ ដែលបានផ្តល់នូវការកាត់ផ្តាច់សេចក្តីស្រឡាញ់រវាងម្តាយហើយនឹងកូន។ ពេលមាតាបំបៅដោះ ហើយថ្នាក់ថ្នមទារកនៅក្នុងដៃរបស់ពួកគេ សេចក្តីស្រឡាញ់យ៉ាងថ្នាក់ថមរវាងម្តាយនិងកូន មានទំហំធំជាង ហើយឥទ្ធិពលមាតាមានទៅលើកូនសម្រាប់សុខុមាល

ភាពរបស់កូន គឺឃើញច្បាស់ទ្វេរជាពីរ។ ក្រោមកាលៈទេសៈបែបនេះ កូនបង្ហាញមិនផ្លាស់ប្តូរនូវការស្រឡាញ់និងការគោរពសាសនា ការទាក់ទងក្នុងគ្រួសារ និងការស្តាប់បង្គាប់។ លក្ខណៈពិសេសនៃប្រពៃណីទាំងនេះ មានសម្រាប់ជាគុណប្រយោជន៍ដល់សេចក្តីល្អនិងសុខុមាលភាពរបស់កូន។ វាអាស្រ័យលើមាតាបិតា ជាពិសេសគឺមាតាជាអ្នកផ្តល់អោយបុត្រធីតាហ្នឹងតែម្តង។ មាតាត្រូវទទួលខុសត្រូវចំពោះការធ្វើល្អ ឬចចេសមុខរឹងរបស់កូន។ មាតាទាំងឡាយអាចកាត់បន្ថយការប្រព្រឹត្តបទល្មើស!

## ការគ្រប់គ្រងរបស់មាតាបិតា

មាតាបិតាជាច្រើន ព្យាយាមរក្សាបុត្រធីតាដែលមានគូស្រករឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ។ ពួកគេមិនផ្តល់សេរីភាពតាមពេលដ៏សមសួនឱ្យទៅបុត្រធីតា ហើយមានទំនោរជ្រៀតជ្រែកជីវិតរបស់គូស្រករដែលរៀបអាពាហ៍ពិពាហ៍ថ្មោងថ្មី។ ពេលមាតាបិតាព្យាយាមគ្រប់គ្រងកូនប្រុសឬកូនស្រីដែលរៀបអាពាហ៍ពិពាហ៍ហើយ ហើយចង់ឱ្យពួកគេធ្វើតាមរបៀបរស់នៅរបស់ខ្លួនយ៉ាងតឹងរឹង ការនេះនឹងបង្កើតឱ្យមានការយល់ខុសជាច្រើនរវាងជំនាន់ពីរ ក៏ដូចជាភាពគ្មានសុភមង្គលរវាងគូស្រករផងដែរ។ មាតាបិតាអាចកំពុងធ្វើដូចនេះក្នុងជំនឿដ៏ល្អ ដោយសារតែសេចក្តីស្រឡាញ់ និងការជាប់ជំពាក់មានចំពោះកូន ប៉ុន្តែការធ្វើបែបនេះ

ពួកគេកំពុងអញ្ជើញបញ្ហាច្រើនថែមទៀតឱ្យខ្លួនគេ និងឱ្យកូនៗផងដែរ។

មាតាបិតា ត្រូវតែអនុញ្ញាតិឱ្យបុត្រធីតារបស់ពួកគេរៃកពុនទទួលខុសត្រូវជីវិតនិងគ្រួសារផ្ទាល់ខ្លួនរបស់ពួកគេ។ ជាតួយ៉ាង បើគ្រាប់ពូជដែលគេសាបព្រោះនៅក្រោមដើមឈើ ពេលខ្លះកូនរុក្ខជាតិអាចដុះ ក្នុងពេលបន្ទាប់។ ប៉ុន្តែបើលោកអ្នកចង់ឱ្យកូនរុក្ខជាតិទាំងនោះ លូតលាស់មានដើមធំធាត់ល្អនិងឯករាជ្យ លោកអ្នកត្រូវតែដកកូនរុក្ខជាតិទាំងនោះទៅដាំ ក្នុងទីវាលកន្លែងផ្សេងទៀត ដើម្បីឱ្យដាច់ៗដោយឡែកពីគ្នា ធ្វើដូច្នេះ កូនរុក្ខជាតិមិនត្រូវបានរារាំងដោយម្លប់នៃមេដើមឈើនោះទេ។

មាតាបិតា គប្បីអើពើនឹងចំណេះដឹងសម័យបុរាណដែលផ្អែកលើការប្រៀនប្រដៅដោយគ្រូអាចារ្យផ្នែកសាសនា ដែលជាអ្នកប្រាជ្ញនិងជារៀមច្បងដែលបានធ្វើឱ្យចំណេះដឹងអំពីពិភពលោក អភិវឌ្ឍតាមរយៈបទពិសោធន៍ច្រើនដង ដើម្បីសម្រេចអ្វីមួយរបស់ពួកគេ។

## ការលែងលះ

ការលែងលះ ជាបញ្ហាប្រជែងគ្នាក្នុងចំណោមអ្នកកាន់សាសនាផ្សេងៗគ្នា។ មនុស្សមួយចំនួនជឿថា អាពាហ៍ពិពាហ៍ត្រូវបានកត់ត្រារួចជាស្រេចនៅក្នុងឋានសួគ៌ ហេតុដូចនេះ វាមិនត្រឹមត្រូវទេ ដើម្បីយល់ព្រមលែងលះគ្នា។ ប៉ុន្តែបើប្ដីនិងប្រពន្ធពិតជាមិនអាចរស់នៅរួមគ្នា ជំនួសឱ្យការ

រស់នៅប្រកបដោយទុក្ខព្រួយនិងការប្រច័ណ្ឌ កំហឹងនិងទោសៈច្រើននៅក្នុងខ្លួន ពួកគេគួរតែមានសេរីភាពដើម្បីចែកផ្លូវគ្នាដើរ ហើយរស់នៅដោយសុខសន្តិភាព។

## ការទទួលខុសត្រូវចំពោះកូន

ទោះបីយ៉ាងណាក៏ដោយ ការចែកផ្លូវគ្នានៃគូស្រករ ត្រូវតែធ្វើឡើងនៅក្នុងបរិយាកាសនៃការយោគយល់គ្នាមួយ ដោយទទួលយកដំណោះស្រាយសមហេតុផល និងមិនដោយការបង្កើតឱ្យមានការប្រកាន់ខឹងកាន់តែខ្លាំងនោះទេ។ បើគូស្រករមានបុត្រធីតា ពួកគេគប្បីព្យាយាមធ្វើឱ្យការលែងលះមានការតក់ស្លុតដល់បុត្រធីតាកាន់តែតិចទៅ ហើយជួយពួកគេឱ្យសម្របសម្រួលទៅនឹងស្ថានការណ៍ថ្មី។ ហើយជាការចាំបាច់បំផុតមាតាបិតាផានាថែទាំរក្សាដើម្បីឱ្យពួកគេមានអនាគត និងសុខុមាលភាព។ វាមិនមែនជាអត្តចរិតមនុស្ស បើគូស្រករបោះបង់កូនៗរបស់ពួកគេ ហើយបណ្តោយឱ្យពួកគេរស់នៅដោយទុក្ខព្រួយ។

## ទស្សនៈព្រះពុទ្ធសាសនា

នៅក្នុងព្រះពុទ្ធសាសនា គ្មានវិន័យបញ្ញត្តិណាមួយសម្តែងថា ប្តីនិងប្រពន្ធ មិនគួរគប្បីលែងលះគ្នា បើពួកគេមិនអាចរស់នៅរួមគ្នាដោយការចុះសម្រុងគ្នា។ ប៉ុន្តែ បើមនុស្សទាំងឡាយប្រតិបត្តិតាមពុទ្ធឱវាទដែលព្រះ

សម្មាសម្ពុទ្ធ ទ្រង់បានសម្តែងដើម្បីបំពេញករណីយកិច្ចរបស់ពួកគេចំពោះគ្នាទៅវិញទៅមក ហេតុដូច្នេះការកើតឡើងជាអកុសលបែបនេះ ដូចជាការលែងលះគ្នា ការចែកផ្លូវគ្នា នឹងមិនកើតឡើងបានទេ។

នៅក្នុងអតីតកាល ដែលតម្លៃសាសនាបានត្រូវគេគោរពយ៉ាងខ្ពង់ខ្ពស់ មានកិច្ចប្រឹងប្រែងដ៏ធំធេងក្នុងនាមនៃគូស្រករទាំងឡាយដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ពោលគឺនៅក្នុងអាស៊ីក៏ដូចជានៅក្នុងបច្ចឹមប្រទេសផងដែរ ដើម្បីឈានដល់ការយល់ដឹងប្រកបដោយសមានចិត្ត ក្នុងការពង្រីកចំណងមិត្តភាពមានសុភមង្គល ដោយផ្អែកលើការគោរព សេចក្តីស្រឡាញ់ និងសេចក្តីរាប់អានសម្រាប់មនុស្សម្នាក់នឹងមនុស្សម្នាក់ទៀត។ គូស្រករទាំងឡាយ បានធ្វើឱ្យរីកចម្រើននិងធ្វើឱ្យអាពាហ៍ពិពាហ៍របស់ពួកគេ ក្លាយជាមានលក្ខណៈពិសេសយ៉ាងសំខាន់ ដែលពួកគេបានរក្សាទុកនៅក្នុងបេះដូងរបស់ពួកគេ។ ករណីលែងលះគ្នាកម្រកើតមានណាស់ និងបានត្រូវគេចាត់ទុកថាជាអាម៉ាសមួយ ពីព្រោះពួកគេបានបង្ហាញអត្តទត្ថភាពនៃភាគីម្ខាង ឬភាគីម្ខាងទៀត។

វាជាការពិត ដែលរហូតមកដល់ពេលថ្មីៗនេះ ករណីលែងលះនៅតែកម្រកើតមានណាស់ នៅក្នុងបណ្តាប្រទេសកាន់ព្រះពុទ្ធសាសនា។ បញ្ហានេះ មានលក្ខណៈពិសេសពីព្រោះគូស្រករទាំងឡាយគិតដល់ករណីយកិច្ចនិងកាតព្វកិច្ចរបស់ពួកគេចំពោះគ្នាទៅវិញទៅមក ហើយជាទូទៅការ

លែងលះមិនត្រូវបានយល់ព្រមផងដែរដោយសហគម ។ នៅក្នុងករណីជាច្រើន ពេលគូស្រករទាំងឡាយដែលបានរៀបអាពាហ៍ពិពាហ៍ហើយ មានបញ្ហារកាំរកូស ចាស់ទុំទាំងឡាយនៅក្នុងសហគម តែងតែប្រមូលផ្តុំគ្នាហើយដើរតួនាទីយ៉ាងសំខាន់ដើម្បីធ្វើឱ្យស្ថានភាពប្រសើរឡើងវិញ ។

ជាអកុសល នៅក្នុងសម័យទំនើបសព្វថ្ងៃនេះ ការលែងលះបានក្លាយទៅជាទម្លាប់សាមញ្ញទៅហើយ ។ នៅក្នុងបណ្តាប្រទេសជាក់ស្តែងមួយចំនួន ការលែងលះថែមទាំងក្លាយទៅជាទាន់សម័យទៅវិញ ។ ផ្ទុយទៅវិញ ការចាត់ទុកការលែងលះ ថាជាការគួរឱ្យអាម៉ាស់ ឬការបរាជ័យក្នុងការរៀបចំជីវិតរបស់ពួកគេ គូស្រករក្មេងៗមួយចំនួនហាក់ដូចជាពេញចិត្តវាទៅវិញ ។ បុព្វហេតុដ៏សំខាន់នៃការបរាជ័យក្នុងអាពាហ៍ពិពាហ៍នៅក្នុងសង្គមទំនើប គឺការប្រើប្រាស់សេរីភាពហួសប្រមាណ និងឯករាជ្យភាពច្រើនសម្បើមពេក ព្រមទាំងឯកត្តនិយម (ទ្រឹស្តីដែលចែងពីការនិយមខ្លួនមនុស្សម្នាក់ៗជាធំ) ក្នុងនាមជាដៃគូ ។ ត្រូវតែមានការកំណត់ព្រំដែនអំពីជីវិតរស់នៅឯករាជ្យរបស់ពួកគេ បើពុំនោះទេ ទាំងភរិយាទាំងស្វាមីនឹងដើរផ្លូវខុសបានយ៉ាងងាយស្រួល ។

## ៧. ពហុពន្ធភាព ឬឯកពន្ធភាព

ចំពោះសំនួរ ថាតើពុទ្ធសាសនិកអាចមានប្រពន្ធច្រើនជាងមួយបានដែរឬទេ? ចំលើយផ្ទាល់គឺថា មិនអាចទៅរួចទេនៅក្នុងការប្រៀនប្រដៅរបស់ព្រះពុទ្ធ ពីព្រោះដូចយើងបាននិយាយគ្នាខាងដើមហើយ ព្រះសម្មាសម្ពុទ្ធ ទ្រង់មិនបានដាក់ច្បាប់សាសនាណាមួយដែលទាក់ទងដល់ជីវិតអាពាហ៍ពិពាហ៍ បើទោះបីជាព្រះអង្គបានផ្តល់ឱវាទមានតម្លៃអំពីរបៀបដឹកនាំជីវិតអាពាហ៍ពិពាហ៍ល្អត្រឹមត្រូវក៏ដោយ ។

ទំនៀមទម្លាប់ វប្បធម៌ និងរបៀបរស់នៅដូចដែលបានទទួលស្គាល់ដោយចំនួនភាគច្រើននៃប្រទេសណាមួយ ត្រូវតែគេយកមកពិនិត្យផងដែរពេលយើងអនុវត្តជាក់ស្តែងនូវការងារពិតប្រាកដ ដែលជាប់ទាក់ទងទៅនឹងជីវិតរបស់យើង។ សាសនាមួយចំនួននិយាយថា បុរសម្នាក់អាចមានប្រពន្ធត្រឹមតែមួយប៉ុណ្ណោះ ចំណែកឯសាសនាដទៃទៀតនិយាយថា បុរសម្នាក់អាចមានប្រពន្ធច្រើនជាងមួយ ។

ទោះបីព្រះសម្មាសម្ពុទ្ធ ទ្រង់មិនបានសម្តែងបញ្ជាក់អ្វីមួយដែលទាក់ទងទៅនឹងចំនួនភរិយាដែលបុរសអាចមាន ព្រះអង្គទ្រង់សម្តែងបញ្ជាក់យ៉ាងជាក់ស្តែង នៅក្នុងព្រះសូត្រទាំងឡាយរបស់ព្រះអង្គថា បើបុរសបានទៅស្ត្រីមួយផ្សេងទៀតក្រៅអំពីភាពជាប្តីប្រពន្ធនឹងគ្នា នោះអាចក្លាយទៅជាហេតុនៃរឿងបង្កឱ្យមានទុក្ខផ្ទាល់ខ្លួនរបស់គេ ហើយបុរសនោះ

ត្រូវតែប្រឈមមុខនឹងបញ្ហា និងការរំខានផ្សេងៗជាច្រើនទៀត ។

របៀបប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គឺគ្រាន់តែពន្យល់អំពីស្ថានភាពនិងផលវិបាកប៉ុណ្ណោះ ។ អ្នកទាំងឡាយអាចគិតអំពីខ្លួនគេផ្ទាល់ដែលទាក់ទងទៅនឹងហេតុអ្វីដែលរឿងរ៉ាវ ឬបញ្ហាមួយចំនួនល្អ ហើយរឿងរ៉ាវឬបញ្ហាមួយចំនួនទៀតមិនល្អ ។ ព្រះពុទ្ធទ្រង់មិនបានដាក់កំហិតក្រិត្យក្រមច្បាប់អំពីភរិយាប៉ុន្មាននាក់បុរសគប្បីមានឬមិនគប្បីមាន ដែលបង្ខំឱ្យមនុស្សទាំងឡាយប្រតិបត្តិតាមនោះទេ ។ ក៏ប៉ុន្តែ បើច្បាប់របស់ប្រទេសមួយមានចែងលក្ខខណ្ឌថា អាពាហ៍ពិពាហ៍ទាំងអស់ ត្រូវតែជាអាពាហ៍ពិពាហ៍ដែលមានប្តីឬប្រពន្ធតែមួយដូច្នេះ ច្បាប់បែបនេះគេត្រូវអនុវត្តតាមពីព្រោះព្រះសម្មាសម្ពុទ្ធបានសម្តែងច្បាស់លាស់អំពី សាវ័កទាំងឡាយរបស់ព្រះអង្គគោរពច្បាប់របស់ប្រទេស បើច្បាប់ទាំងនោះជាប្រយោជន៍ដល់មនុស្សសត្វទាំងអស់ ។

## ៨. បច្ចេកវិទ្យាថ្មី

### គម្រោងការណ៍គ្រួសារ

សាសនាមួយចំនួន មិនយល់ស្របនឹងគម្រោងគ្រួសារនេះទេ។ សាសនាទាំងនោះនិយាយថា វាប្រឆាំងនឹងបំណងព្រះជាម្ចាស់។ ព្រះពុទ្ធសាសនាមិនជ្រៀតជ្រែកទៅក្នុងជម្រើសផ្ទាល់ខ្លួននេះទេ។ បុរសមានសេរីភាពអនុវត្ត វិធីសាស្ត្រណាមួយដើម្បីការពារការបង្កកំណើត។ យោងតាមព្រះពុទ្ធសាសនាលក្ខខណ្ឌផ្នែកផ្លូវចិត្ត ត្រូវតែបានគេបង្ហាញសម្រាប់ការចាប់បដិសន្ធិកើតមាន។ ពេលលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ គ្មានវត្តមាន (ដូចជាពេលគេអនុវត្តគម្រោងការណ៍គ្រួសារ )គ្មានការចាប់បដិសន្ធិកើតឡើងទេ ហេតុនេះ ជីវិតក៏មិនបានចាប់កំណើតដែរ។ ប៉ុន្តែបន្ទាប់ពីការចាប់បដិសន្ធិរបស់វិញ្ញាណ ការពន្លូតកូនមិនអាចទទួលយកបានទេនៅក្នុងព្រះពុទ្ធសាសនា ពីព្រោះវាមានន័យថា សម្លាប់ជីវិតសត្វដែលបានករជាទម្រង់នៃទារកក្នុងគភ៌រួចហើយ។

### ទារកដែលកើតមកដោយសិប្បនិម្មិត

មនុស្សមួយចំនួន ចាប់អារម្មណ៍ទៅលើការជាប់ជំពាក់ទាក់ទងផ្នែកសីលធម៌ ឬអាកប្បកិរិយាផ្នែកសាសនាដែលគិតគូរដល់ទារកដែលកើតមក

ដោយសិប្បនិម្មិត ។ បើស្ត្រីមិនអាចមានផ្ទៃពោះតាមវិធីធម្មតាបាន ហើយ បើនាងចង់មានកូនដោយប្រើមធ្យោបាយវេជ្ជសាស្ត្រទំនើប គ្មានហេតុផល អ្វីនៅក្នុងព្រះពុទ្ធសាសនាដែលនិយាយថា វាជាការអសីលធម៌មិនត្រឹម ត្រូវតាមសាសនានោះទេ។ សាសនាទាំងឡាយត្រូវតែផ្តល់ជំនឿទុកចិត្ត សមរម្យដល់ចំណេះដឹងរបស់មនុស្ស និងសម្របខ្លួនទៅនឹងការរកឃើញ ផ្នែកវេជ្ជសាស្ត្រថ្មីៗ បើការរកឃើញនោះមិនធ្វើទុក្ខទោសដល់មនុស្សនឹង ជាប្រយោជន៍ដល់មនុស្សជាតិពិតៗ។ ដូចបានថ្លែងពីខាងដើមមកហើយ ដរាបណា លក្ខខណ្ឌទាំងឡាយមានភាពត្រឹមត្រូវ ការចាប់បដិសន្ធិអាច អនុញ្ញាតឱ្យកើតមាន តាមធម្មជាតិឬតាមសិប្បនិម្មិត។

# ៩. សីលធម៌

## ទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ

ទំនាក់ទំនងផ្លូវភេទមុនពេលរៀបការ ជាបញ្ហាមួយដែលគេបានពិភាក្សាយ៉ាងច្រើននៅក្នុងសង្គមសម័យទំនើប។ យុវជនដែលមានវ័យក្មេងៗជាច្រើនចង់ដឹងទស្សនៈ ដែលទាក់ទងនឹងបញ្ហាពិបាកដោះស្រាយនេះ។ អ្នកកាន់សាសនាមួយចំនួននិយាយថា គេអាចចាត់ទុកវាជាការប្រព្រឹត្តខុសក្នុងកាម រីឯអ្នកកាន់សាសនាដទៃទៀតនិយាយថា វាជាអំពើអសីលធម៌ និងមិនអាចលើកទោសឱ្យបាន។

នៅក្នុងអតីតកាល ក្មេងប្រុសនិងក្មេងស្រីមានវ័យនៅក្មេងទាំងឡាយ មិនត្រូវបានការអនុញ្ញាតពីមាតាបិតារបស់ពួកគេ ឱ្យដើរលេងទៅណាមកណាដោយសេរី រហូតដល់ពួកគេបានរៀបអាពាហ៍ពិពាហ៍ហើយ។ មាតាបិតារបស់ពួកគេជាអ្នកសម្រេចចិត្តយល់ព្រមរៀបចំអាពាហ៍ពិពាហ៍របស់ពួកគេផងដែរ។ ពិតមែនហើយ ការនេះពិតជាបណ្តាលឱ្យមានការគ្មានសេចក្តីសុខ (អពមង្គល) នៅក្នុងករណីខ្លះ ពេលមាតាបិតាបានជ្រើសរើសគូស្រករ ឱ្យកូនដោយផ្អែកលើមាសប្រាក់ ឋានៈក្នុងសង្គមបំណុលគ្រួសារ ហើយនឹងបញ្ហាដែលជាប់ពាក់ព័ន្ធជាច្រើនទៀត។ ប៉ុន្តែជាទូទៅ ចំនួនច្រើននៃមាតាបិតា ពិតជាព្យាយាមយ៉ាងខ្លាំងដើម្បីជ្រើសរើសគូស្រករ ដែលសក្តិសមអាចទទួលយកបាន ឱ្យបុត្រធីតារបស់ពួកគេ។

សព្វថ្ងៃនេះ យុវជនក្មេងៗមានសេរីភាពចេញទៅដើរលេងខាងក្រៅ និងស្វែងរកដៃគូផ្ទាល់របស់ពួកគេ។ ពួកគេមានសេរីភាពនិងឯករាជ្យភាពយ៉ាងច្រើននៅក្នុងការរស់នៅរបស់ពួកគេ។ នេះមិនមែនជារឿងមិនល្អដោយខ្លួនវាទេ ប៉ុន្តែយុវជនទាំងនេះមួយចំនួនពិតជានៅក្មេងពេក និងមិនទាន់ពេញវ័យ ដើម្បីមើលឃើញភាពខុសគ្នារវាងការទាក់ទាញផ្លូវភេទ និងការចុះសម្រុងគ្នាពិតប្រាកដនៅឡើយទេ។ ហេតុនេះហើយ បានជាបញ្ហាទំនាក់ទំនងផ្លូវភេទមុនរៀបអាពាហ៍ពិពាហ៍ចេះតែកើតមាននោះ។

ខ្វះភាពជាការពិតជាក់ស្តែង ច្រើនពេកនៅក្នុងបញ្ហារឿងរ៉ាវទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងផ្លូវភេទ ដែលបណ្តាលឱ្យមានបញ្ហាសង្គមផងដែរនៅក្នុងសង្គមសម័យទំនើប។ ចំណែកដ៏សោកសៅមួយគឺសង្គមមួយចំនួន មិនបានបង្ហាញអាកប្បកិរិយាដែលប្រកាន់តាមសេរីភាពនិយមចំពោះមាតាទាំងឡាយដែលមិនបានរៀបអាពាហ៍ពិពាហ៍ កូនឥតខាន់ស្លានិងស្ត្រីដែលលែងប្តីហើយ ពេលដែលសង្គមពិតជាប្រកាន់តាមបែបសេរីភាពនិយមអំពីទំនាក់ទំនងផ្លូវភេទដោយសេរី។ សង្គមតែមួយដែលបានលើកទឹកចិត្ត ឱ្យមានការសេពគប់ដោយសេរីនៃទំនាក់ទំនងផ្លូវភេទ កំពុងដាក់ទោសយុវជនក្មេងៗ។ ពួកគេបានក្លាយជាមនុស្សដែលគេបន្សាត់ចោលរបស់សង្គម និងរងគ្រោះភាពខ្មាស់អៀន និងភាពអាម៉ាស់មុខជាច្រើន។ យុវនារីក្មេងជាច្រើនបានក្លាយជាជនរងគ្រោះ ដោយសារសេរីភាពផ្ទាល់ខ្លួន

របស់ពួកគេ បានធ្វើឱ្យខូចអនាគតរបស់ពួកគេ ដោយសារបំពានលើប្រពៃណីតាំងពីបរមបុរាណ និងដែលគេឱ្យតម្លៃនៅអាស៊ី ក៏ដូចជាបច្ចឹមប្រទេសផងដែរ ។

ទំនាក់ទំនងផ្លូវភេទ មុនពេលរៀបអាពាហ៍ពិពាហ៍ ជាវឌ្ឍនកម្មទំនើបដែលបានកើតឡើង ជាលទ្ធផលនៃសេរីភាពសង្គមហួសប្រមាណដែលបានរាលដាល ក្នុងចំណោមយុវវ័យក្មេងៗសម័យបច្ចុប្បន្ននេះ ។ ក្នុងខណៈពេលដែលព្រះពុទ្ធសាសនា មិនបានប្រកាន់ទស្សនៈខ្លាំងខ្លា ទាំងប្រឆាំង ទាំងគាំទ្រសកម្មភាពបែបនេះ គេគិតថាពុទ្ធសាសនិកទាំងអស់ពិសេសទាំងពីរភេទដែលស្ថិតនៅក្នុងសេចក្តីស្នេហា ឬបម្រុងរៀបការគប្បីប្រកាន់ខ្ជាប់នូវគំនិតជាប្រពៃណីមានតាំងពីបរមបុរាណដែលថា ពួកគេរក្សាព្រហ្មចរិយភាពរហូតដល់ថ្ងៃអាពាហ៍ពិពាហ៍ ។ ចិត្តរបស់មនុស្សមិនទៀងទាត់ទេ ហើយផ្លាស់ប្តូរមិនចេះឈប់ ដោយបង្ហាញផលថា សកម្មភាពខុសច្បាប់ ឬអំពើមិនលាក់អាថិកំបាំងណាមួយ អាចបង្កផលអាក្រក់ជ្រុលហួសហេតុដល់ភាគីណាមួយមិនខាន បើអាពាហ៍ពិពាហ៍ស្របច្បាប់ មិនបានប្រារព្ធធ្វើដូចដែលគេបានសង្ឃឹមទុក ។ គេត្រូវតែចងចាំថា ទម្រង់ណាមួយនៃការប្រព្រឹត្តខុសក្នុងកាម មុនពេលអាពាហ៍ពិពាហ៍សមរម្យមួយ ត្រូវបានធ្វើឱ្យជាឱឡារិកនោះ ចាស់ទុំដែលជាអ្នកថែរក្សាយុវវ័យក្មេងៗនឹងមើលងាយ ។

# ការប្រព្រឹត្តខុសក្នុងកាម

នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គ្រហស្ថត្រូវផ្ដល់ឱវាទឱ្យជៀសវាងការប្រព្រឹត្តខុសក្នុងកាម។ ការប្រព្រឹត្តខុសក្នុងកាមនោះមានន័យថា បើនរណាម្នាក់ចង់ប្រព្រឹត្តក្នុងកាម គេអាចធ្វើបានដោយគ្មានបង្កើតឱ្យមានអំពើហឹង្សា ឬដោយការប្រើប្រាស់កម្លាំងប្រភេទណាមួយមានការគម្រាមកំហែង ឬការបង្កឱ្យមានការភ័យខ្លាចជាដើម។ ជីវិតទំនាក់ទំនងផ្លូវភេទសមរម្យដែលគោរពដៃគូម្ខាងទៀត មិនប្រឆាំងនិងសាសនានោះទេ វាទទួលយកការពិតដែលថា វាជាភាពចាំបាច់សម្រាប់អ្នកទាំងឡាយដែលមិនទាន់រៀបចំខ្លួនដើម្បីលះបង់ជីវិតលោកិយ៍នៅឡើយ។

បើតាមព្រះពុទ្ធសាសនា អ្នកទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងការរួមរ័ក្សជាមួយអ្នកដទៃផ្សេងពីប្ដីឬប្រពន្ធឯង ជាមួយនឹងអ្នកណាម្នាក់ដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ជាមួយអ្នកណាដែលបានភ្ជាប់ពាក្យជាមួយអ្នកណាម្នាក់ទៀត ព្រមទាំងជាមួយអ្នកទាំងឡាយណាដែលស្ថិតនៅក្រោមការការពាររបស់មាតាបិតារបស់ពួកគេ ឬអ្នកថែរក្សារបស់ពួកគេ អ្នកនោះឈ្មោះថាមានទោសព្រោះប្រព្រឹត្តខុសក្នុងកាម ព្រោះមានការផ្ទុះធ្លាយបទដ្ឋានសង្គម ដែលបានធ្វើឱ្យភាគីទីបីរងគ្រោះ ជាលទ្ធផលនៃអត្តទត្ថភាពរបស់ភាគីមួយ ឬភាគីមួយផ្សេងទៀត។

# អត្តចរិតមិនទទួលខុសត្រូវផ្លូវភេទ

ព្រះពុទ្ធទ្រង់បានសម្ដែងផងដែរ អំពីផលពិបាកទាំងឡាយ ដែលបុរសមានវ័យចំណាស់ត្រូវប្រឈមមុខ បើគាត់បានរៀបអាពាហ៍ពិពាហ៍ ដោយមិនគិតពីការចុះសម្រុងអាយុគ្នានៃភាគីម្ខាងទៀត។ យោងតាមព្រះសម្មាសម្ពុទ្ធ អត្តចរិតផ្លូវភេទមិនមានការទទួលខុសត្រូវ អាចបង្កជាហេតុនៃការបង្កឱ្យមានទុក្ខមួយក្នុងចំណោមហេតុដទៃទៀត នៅក្នុងទិដ្ឋភាពជាច្រើននៃជីវិត។

គ្រប់ប្រទេសទាំងអស់នៅលើពិភពលោក បានចែងច្បាស់លាស់ទាក់ទងការរំលោភបំពានផ្លូវភេទ។ ដូចបាននិយាយមកខាងដើមហើយថា ព្រះពុទ្ធសាសនានិយាយគាំទ្រឱ្យបុគ្គលម្នាក់ៗ ត្រូវតែគោរពនិងប្រតិបត្តិតាមច្បាប់របស់ប្រទេស បើច្បាប់ទាំងឡាយនោះ ធ្វើឡើងដើម្បីជាប្រយោជន៏ដល់ប្រជាជន។

## ១០. បូព៌ាប្រទេស និង បច្ចិមប្រទេស

ខាងក្រោមនេះបានដកស្រង់ចេញពីសៀវភៅ សរសេរដោយអ្នកនិពន្ធជនជាតិជប៉ុនល្បីល្បាញម្នាក់ គឺបណ្ឌិត **និក្សូនិវ៉ាណូ**។ នៅក្នុងសៀវភៅរបស់គាត់មានចំណងជើងថា **(ជីវិតផ្អែមល្ហែម)** បណ្ឌិតនិវ៉ាណូធ្វើអង្គការបញ្ហាទាំងឡាយ ទាក់ទងនឹងសេចក្ដីស្នេហានិងអាពាហ៍ពិពាហ៍ទាំងជាទស្សនៈមកពីអាស៊ី និងបច្ចិមប្រទេស។

នៅលោកខាងលិច អាពាហ៍ពិពាហ៍ឈរលើមូលដ្ឋាននៃស្នេហាមនោសញ្ចេតនា ជាធម្មតាចាត់ទុកជាធម្មជាតិនិងពេលខ្លះថាមានឧត្តមគតិនិយម។ នៅអាស៊ី ប៉ុន្មានឆ្នាំថ្មីៗនេះ ចំនួនភាគច្រើននៃយុវជនក្មេងៗដែលបោះបង់ចោលអាពាហ៍ពិពាហ៍រៀបចំតាមប្រពៃណី ហើយជ្រើសរើសដៃគូដោយការគិតដល់មនោសញ្ចេតនា បាននឹងកំពុងកើនឡើង។ ប៉ុន្តែនៅក្នុងករណីខ្លះ អាពាហ៍ពិពាហ៍បែបមនោសញ្ចេតនា បានឈានទៅដល់ការបែកបាក់គ្នា និងមិនមានសុភមង្គលក្នុងរយៈពេលដ៏ខ្លី។ ចំណែកអាពាហ៍ពិពាហ៍ដែលមានការរៀបចំទុកដាក់ តែងតែបង្កើតឱ្យមានគូស្រករដែលរស់នៅនិងធ្វើការរួមគ្នាមានភាពសប្បាយរីករាយនិងសុភមង្គល។

ថ្វីបើការទាក់ទាញផ្នែកអារម្មណ៍របស់វា អាពាហ៍ពិពាហ៍មនោ-សញ្ចេតនាទាំងអស់ គេមិនអាចហៅថា ជាជោគជ័យទាំងស្រុងនោះទេ។ ស្នេហាមនោសញ្ចេតនា គឺដូចជាអណ្ដាតភ្លើងដែលឆេះចេញពីអុស វាឆេះ

ឡើងសន្ធោសន្ធៅហើយក៏រលត់ទៅវិញ ប៉ុន្តែមានរយៈពេលខ្លីប៉ុណ្ណោះ។ ស្នេហារវាងប្ដីនិងប្រពន្ធនេះឃឹតៗនិងស្ងប់ស្ងាត់ ដូចជាដុំរងើកភ្លើងដែលឆេះពីធ្យូង។ ពិតណាស់ ស្នេហាអណ្ដាតភ្លើងអាចធ្វើតាមឧត្ដមគតិនិយមគួរតែជាលំដាប់ ក្លាយជាភ្លើងមានសភាពស្ងប់ស្ងាត់នឹងឋិតថេរនៃសេចក្ដីស្រឡាញ់ពេញលក្ខណៈ។ ប៉ុន្តែជារឿយៗណាស់ អណ្ដាតភ្លើងនៃសេចក្ដីស្នេហាមនោសញ្ចេតនា រលត់វិញយ៉ាងឆាប់រហ័ស ដោយមិនបានបន្សល់ទុកអ្វីសោះ ក្រៅពីផេះដែលជាការបង្កើតដ៏ខ្សត់ខ្សោយ ឱ្យមានជីវិតអាពាហិពិពាហិប្រកបដោយជោគជ័យ!

យុវជនក្មេងៗ ស្ថិតនៅក្នុងសេចក្ដីស្នេហាគ្មានគិតគូរអ្វីទាំងអស់ក្រៅពីអារម្មណ៍រីករាយរបស់ពួកគេ។ ពួកគេមើលឃើញខ្លួនឯងត្រឹមតែក្នុងចំណុចនៃការមានអារម្មណ៍ក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ អ្វីៗដែលពួកគេគិតនិងធ្វើ គឺមនោសញ្ចេតនា និងសម្រេចបានសេចក្ដីស្នេហាពិតប្រាកដតិចតួចនៃជីវិតដែលពួកគេត្រូវតែមានបន្ទាប់ពីអាពាហ៍ពិពាហ៍។ បើគូស្នេហ៍ទាំងឡាយមានភ័ព្វគ្រប់គ្រាន់ ដោយមានបុគ្គលិកលក្ខណៈភាពចុះសម្រុងគ្នា មានគំនិតទស្សនៈត្រូវគ្នានិងត្រឹមត្រូវអំពីជីវិត មានចំណាប់អារម្មណ៍ត្រូវគ្នា គាប់ចិត្តនឹងទំនាក់ទំនងគ្រួសារចុះសម្រុងគ្នាទាំងពីរភាគី ហើយមិនខ្វះខាតដោយការចាត់ចែងខាងផ្នែកហិរញ្ញវត្ថុ បន្ទាប់ពីការរំជើបរំជួលលើកដំបូងបានស្ងប់ទៅ ពួកគេនៅតែមានជំហរសម្រាប់ជីវិតគាប់ប្រសើរ

រួមគ្នា។ បើពួកគេមិនសូវមានជោគវាសនាទេ ពួកគេអាចនឹងប្រឈមមុខនឹងបរាជ័យក្នុងភាពជាប្តីប្រពន្ធនឹងគ្នា។

នៅពេលដែលពេលវេលា នៃថ្ងៃកំណត់សរុបភាពមនោសញ្ចេតនាការរាំរែក និងពិធីអាពាហ៍ពិពាហ៍បានកន្លងផុតទៅ គូស្រករដែលរៀបអាពាហ៍ពិពាហ៍ហើយថ្មីថ្មោង នឹងត្រូវរស់នៅរួមគ្នា បរិភោគអាហាររួមគ្នា និងបង្ហាញឱ្យឃើញដល់គ្នាទៅវិញទៅមក នូវគុណវិបត្តិរបស់ពួកគេ ក៏ដូចជាគុណសម្បត្តិដែរ។ ពួកគេនឹងត្រូវចំណាយពេលវេលាជាងពាក់កណ្តាលនៃជីវិតរបស់ពួកគេ មួយថ្ងៃៗនៅជាមួយគ្នា ការរស់នៅប្រភេទនេះទាមទារខុសពីសេចក្តីត្រូវការ ដែលប្រិតប្រៀងតិចតួចនៃការណាត់ជួបនឹងស្នេហាគ្រាដំបូង។

"ការទាក់ទងក្នុងគ្រួសារ ក្លាយទៅជាមានសារៈសំខាន់ណាស់ក្នុងជីវិតអាពាហ៍ពិពាហ៍។ យុវជនក្មេងៗតែងគិតថា កម្លាំងនៃសេចក្តីស្នេហារបស់ពួកគេនឹងធ្វើឱ្យកាន់តែជិតស្និទ្ធជាមួយសាច់ថ្លៃ ដែលបង្កជាជម្លោះនិងពិបាកផ្គាប់ចិត្តបំផុតនោះ។ ប៉ុន្តែនេះមិនមែនតែងតែពិតនោះទេ។ សរុបសេចក្តីមក មនោសញ្ចេតនាជាបញ្ហាមួយនៃពេលវេលាដែលបានកំណត់ និងមិនក្លាយទៅជាមានដើមហេតុនៅក្នុងតថភាព ហើយគេត្រូវតែដាក់កម្រិតដើម្បីអនុលោមទៅតាមត្រូវការនៃការងារ និងបរិស្ថានដើម្បីចងភ្ជាប់គូស្រកររួមគ្នានៅក្នុងចំណងភក្តីភាពយូរអង្វែង។ ស្នេហាពីរប្រភេទនេះ ខុស

គ្នា។ ធ្វើឱ្យមនុស្សម្នាក់ខុសចំពោះមនុស្សម្នាក់ទៀត គឺអញ្ជើញបញ្ហាស្រគត់ស្រគំ ”។

“ដោយផ្តល់ការគិតប្រាកដប្រជា មិនលំអៀងចំពោះធម្មជាតិរបស់មនុស្ស បុគ្គលម្នាក់បម្រុងនឹងរៀបអាពាហ៍ពិពាហ៍ ធ្វើឱ្យអន់ចុះភវនីយភាពនៃបរាជ័យ។ ដើម្បីការពារមនោសញ្ចេតនា ពីការសាបសូន្យបន្ទាប់ពីអាពាហ៍ពិពាហ៍ ការដឹងចិត្តថ្លើមទាំងសងខាងរវាងគូស្រករមានសារៈសំខាន់ណាស់។ ប៉ុន្តែភាគរយនៃអាពាហ៍ពិពាហ៍មានជ័យជំនះ គឺខ្ពស់ជាងក្នុងចំណោមយុវជនក្មេងៗ ដែលការជ្រើសរើសដៃគូរបស់ពួកគេ គឺយល់ស្របជាមួយចិត្តគំនិត របស់ឪពុកម្តាយរបស់ពួកគេ។ ដើម្បីរស់នៅមានសុខសន្តិភាព ចាំបាច់ត្រូវយល់ឱ្យច្បាស់ពីភាពខុសគ្នា រវាងមនោសញ្ចេតនា និងស្នេហាដែលបានរៀបអាពាហ៍ពិពាហ៍”។

## ១១. ភាពនៅលីវ

### អ្វីទៅហៅថាភាពនៅលីវ?

ភាពនៅលីវ គឺការតមពីភាពរីករាយ នៃសកម្មភាពផ្លូវភេទ។ អ្នករិះគន់របស់ព្រះពុទ្ធសាសនាមួយចំនួននិយាយថា ពាក្យប្រៀនប្រដៅនេះប្រឆាំងនឹងធម្មជាតិ ហើយពួកគេប្រកាសថា ជីវិតផ្លូវភេទ គឺជាធម្មជាតិ ហេតុនេះចាំបាច់ត្រូវមានជីវិតផ្លូវភេទ។

ព្រះពុទ្ធសាសនា មិនប្រឆាំងនឹងទំនាក់ទំនងផ្លូវភេទទេ វាជាសេចក្តីរីករាយដែលត្រេកត្រអាលនឹងកាមរាគៈជាធម្មជាតិ ហើយជាភាគដ៏ច្រើននៃជីវិតលោកីយ៍។ គេអាចសួរថា អញ្ចឹងហេតុអ្វីបានជាព្រះពុទ្ធទ្រង់សម្តែងគាំទ្រភាពនៅលីវ ថាជាខប្រតិបត្តិ? តើវាស្របនិងមិនប្រឆាំងនឹងធម្មជាតិទេឬ? ពិតមែនហើយ ការប្រតិបត្តិភាពនៅលីវដើម្បីការអភិវឌ្ឍប្រាជ្ញាស្មារតី មិនមែនជាខប្រតិបត្តិផ្នែកសាសនាថ្មីមួយនៅសម័យពុទ្ធកាលនោះទេ។ សាសនាដែលមានស្រាប់ដទៃផ្សេងទៀតទាំងអស់ នៅក្នុងប្រទេសឥណ្ឌានៅសម័យនោះ ក៏បានណែនាំឱ្យប្រតិបត្តិខនេះដែរ។ សូម្បីតែសព្វថ្ងៃនេះ អ្នកកាន់សាសនាដទៃទៀតមួយចំនួន ដូចជាអ្នកកាន់សាសនាហិណ្ឌូ និងអ្នកកាន់សាសនាយេស៊ូគ្រីស្តនិកាយកាតូលិច ក៏ប្រតិបត្តិខនេះដែរ

ពុទ្ធសាសនិក ដែលបានលះបង់ជីវិតលោកីយ៍ ដោយស្មោះចិត្តសមាទានខប្រតិបត្តិនេះ ពីព្រោះពួកគេដឹងយ៉ាងច្បាស់ អំពីការប្តេជ្ញាចិត្ត

និងការរំខានដែលចូលមកដល់ បើគេប្រព្រឹត្តខ្លួនទៅនឹងជីវិតរបស់ឃរាវាស ជីវិតដែលបានរៀបអាពាហ៍ពិពាហ៍ហើយ អាចធ្វើឱ្យប៉ះពាល់ ឬបន្ថយការអភិវឌ្ឍប្រាជ្ញាស្មារតី ពេលតម្រេកនិងការជិតជាប់ផ្នែកផ្លូវភេទ គ្របសង្កត់ចិត្ត ហើយការប៉ុនប៉ង ព្យាយាមបាំងសេចក្តីស្ងប់ និងការធ្វើឱ្យចិត្តបរិសុទ្ធ ។

## សារៈសំខាន់នៃភាពនៅលីវ

មនុស្សទាំងឡាយ មានទំនោរសួរថា "បើព្រះពុទ្ធទ្រង់មិនបានទេសនាពន្យល់ប្រឆាំងជីវិតអាពាហ៍ពិពាហ៍ អញ្ចឹងហេតុអ្វីបានជាព្រះអង្គបានសម្តែងការគាំទ្រភាពនៅលីវ ជាខប្រតិបត្តិមួយក្នុងចំណោមខប្រតិបត្តិសំខាន់ៗសាវ័កទាំងឡាយត្រូវសមាទាន ហើយហេតុអ្វីបានជាព្រះអង្គទ្រង់ទូន្មានមនុស្សទាំងឡាយឱ្យចៀសវាងទំនាក់ទំនងផ្លូវភេទ និងលះបង់ជីវិតលោកីយ៍?"

គេត្រូវចង់ចាំថា ការចេញចាកបួស គឺមិនមែនជាការបង្ខិតបង្ខំទេនៅក្នុងព្រះពុទ្ធសាសនា ។ មិនមែនជាកាតព្វកិច្ចត្រូវលះបង់ជីវិតលោកីយ៍ទាំងស្រុងដើម្បីប្រតិបត្តិព្រះពុទ្ធសាសនានោះទេ ។ លោកអ្នកអាចកែតម្រង់មាគ៌ាជីវិតរបស់លោកអ្នក ដោយប្រតិបត្តិតាមគោល និងគុណសម្បត្តិផ្នែកសាសនាណាមួយ ។ លោកអ្នកអាចអភិវឌ្ឍគោលសាសនារបស់លោកអ្នក តាមសេចក្តីត្រូវការនៃជីវិតឃរាវាស ។ ទោះបីយ៉ាងណាក៏ដោយ ពេល

លោកអ្នកបានចម្រើនលូតលាស់ និងសម្រេចបានបញ្ញាកាន់តែខ្លាំងឡើង ហើយឃើញច្បាស់ថា មាគ៌ាជីវិតឃរាវាសមិនជួយឱ្យសម្រេចការអភិវឌ្ឍខ្ពស់បំផុតនៃ**គុណធម៌ផ្នែកប្រាជ្ញាស្មារតី និងការធ្វើចិត្តឱ្យបរិសុទ្ធ** លោកអ្នកអាចជ្រើសរើសដើម្បីលះបង់ជីវិតលោកីយ៍ និងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការអភិវឌ្ឍប្រាជ្ញាស្មារតី ។

ព្រះសម្មាសម្ពុទ្ធទ្រង់សរសើរភាពនៅលីវ ពីព្រោះទំនាក់ទំនងផ្លូវភេទនិងអាពាហ៍ពិពាហ៍ មិនអាចជួយឱ្យសម្រេចសេចក្តីស្ងប់និងការធ្វើចិត្តឱ្យបរិសុទ្ធខ្ពស់បំផុតបានទេ ហើយការចេញចាកបួសគឺចាំបាច់ បើមានបំណងចង់សម្រេចបានវឌ្ឍនភាព និងសុក្រិតភាពប្រាជ្ញាស្មារតីកម្រិតខ្ពស់បំផុត ។ ប៉ុន្តែការចេញចាកបួសនេះ គប្បីប្រព្រឹត្តទៅដោយឯកឯង និងមិនត្រូវមានគេ**បង្ខិតបង្ខំ** ។ ការចេញចាកបួស គប្បីប្រព្រឹត្តទៅតាមរយៈការយល់ដឹងពិតប្រាកដអំពីធម្មជាតិបំភ័ន្តភ្នែកនៃតួខ្លួន អំពីធម្មជាតិមិនគួរឱ្យត្រេកត្រអាលនៃសេចក្តីសប្បាយរីករាយគ្រប់ប្រភេទទាំងអស់ ។

## ភាពនៅលីវទល់នឹងទំនួលខុសត្រូវ-បទពិសោធន៍របស់ព្រះសម្មាសម្ពុទ្ធ

ព្រះសម្មាសម្ពុទ្ធធ្លាប់មានជីវិតឃរាវាសរបស់ព្រះអង្គ ជាព្រះអង្គម្ចាស់ ព្រះភស្តា និងបិតាមុនការចេញចាកបួសរបស់ព្រះអង្គ ហើយព្រះអង្គបានដឹងនូវអ្វីដែលជីវិតអាពាហ៍ពិពាហ៍តម្រូវចាំបាច់ ។ មនុស្សទាំងឡាយ

អាចសួរអំពីការចេញចាកបួសរបស់ព្រះសម្មាសម្ពុទ្ធ ដោយនិយាយថា ព្រះអង្គមានលក្ខណៈអត្តទត្ថបុគ្គល និងឃោរឃៅ និងថាវាមិនត្រឹមត្រូវចំពោះព្រះអង្គរត់ចោលមហេសីនិងបុត្រារបស់ព្រះអង្គ។ តាមសេចក្តីពិតជាក់ស្តែង ព្រះពុទ្ធទ្រង់មិនបានរត់ចោលរាជវង្សានុវង្សរបស់ព្រះអង្គ ដោយគ្មានទំនួលខុសត្រូវនោះទេ។

ព្រះអង្គមិនដែលមានការមិនយល់ចិត្តណាមួយ ជាមួយមហេសីរបស់ព្រះអង្គឡើយ។ ព្រះអង្គក៏មានសេចក្តីស្រឡាញ់ ការជាប់ជំពាក់ចំពោះមហេសីនិងបុត្រាដូចបុរសធម្មតាគប្បីមាន ប្រហែលថែមទាំងធំជាងផង។ ភាពខុសគ្នា គឺនៅត្រង់ស្នេហារបស់ព្រះអង្គ មិនមែនគ្រាន់តែជាស្នេហាផ្អែករូបរាងកាយនិងប្រកបដោយអត្តទត្ថភាពប៉ុណ្ណោះទេ ព្រះអង្គមានសេចក្តីក្លាហាននិងការយល់ដឹង ដើម្បីផ្តាច់សេចក្តីស្នេហាវេទនារម្មណ៍ និងប្រកបដោយអត្តទត្ថបុគ្គលនោះ ក្នុងគោលបំណងល្អ។ គេចាត់ទុកពលិកម្មរបស់ព្រះអង្គ ថាប្រសើរបំផុត ពីព្រោះព្រះអង្គទ្រង់មិនគិតគូរដល់សេចក្តីត្រូវការ និងសេចក្តីប្រាថ្នាផ្ទាល់ខ្លួនរបស់ព្រះអង្គ ដើម្បី **បម្រើមនុស្សជាតិទាំងអស់គ្រប់ពេលវេលាទាំងអស់**។

គោលបំណងសំខាន់នៃអភិនិស្រ្កមរបស់ព្រះអង្គ មិនត្រឹមតែដើម្បីសេចក្តីសុខ សេចក្តីស្ងប់ ឬការជួយសង្គ្រោះរបស់ព្រះអង្គប៉ុណ្ណោះទេ ថែមទាំងដើម្បីជាប្រយោជន៍ដល់**មនុស្សជាតិ**។ បើព្រះអង្គគង់នៅតែក្នុងព្រះ

រាជវាំង ការបម្រើរបស់ព្រះអង្គត្រូវបានគេឃុំឃាំងតែនៅក្នុងរាជវង្សផ្ទាល់ ឬអាណាចក្ររបស់ព្រះអង្គប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាព្រះអង្គសម្រេចចិត្តលះបង់អ្វីៗទាំងអស់ដើម្បីរក្សាសេចក្តីស្ងប់ និងសេចក្តីបរិសុទ្ធ ដើម្បីសម្រេចបានការត្រាស់ដឹងសម្មាសម្ពោធិញាណ ហើយបន្ទាប់មកបំភ្លឺផ្លូវដល់អ្នកដទៃទៀតដែលកំពុងរងទុក្ខក្នុងអវិជ្ជា។

ពុទ្ធកិច្ចដំបូងបំផុតមួយ បន្ទាប់ពីការត្រាស់ដឹងរបស់ព្រះអង្គ គឺត្រឡប់ទៅព្រះរាជវាំងរបស់ព្រះអង្គ ដើម្បីបំភ្លឺមាគ៌ាត្រាស់ដឹងដល់សមាជិកនៃព្រះរាជវង្សានុវង្សរបស់ព្រះអង្គ។ តាមពិត ពេលបុត្រារបស់ព្រះអង្គ រាហុលបានសុំកំណប់ទ្រព្យជាមរតករបស់ទ្រង់ ពីព្រះសម្មាសម្ពុទ្ធៗទ្រង់មានព្រះបន្ទូលថា រាហុលជាអ្នកទទួលមរតកអរិយទ្រព្យផ្នែកធម្មរតន គឺជាអ្នកប្រាថ្នាការសិក្សាក្នុងធម្មវិន័យ។ តាមវិធីនេះ ព្រះសម្មាសម្ពុទ្ធទ្រង់បានបម្រើប្រយោជន៍ដល់រាជវង្សានុវង្សរបស់ព្រះអង្គ ហើយព្រះអង្គបានត្រួសត្រាយផ្លូវឱ្យដើម្បីការជួយសង្គ្រោះ សេចក្តីស្ងប់ និងសេចក្តីសុខរបស់ពួកគេ។ ហេតុនេះ គ្មាននរណាម្នាក់អាចនិយាយថា ព្រះពុទ្ធទ្រង់ជាបិតាឃោរឃៅ ឬប្រកបដោយអត្តទត្ថភាពនោះទេ។ តាមពិតព្រះអង្គជាបុគ្គលករុណាធម៌ និងការលះបង់ច្រើនជាងអ្នកដទៃទាំងអស់។ ជាមួយវឌ្ឍនភាពប្រាជ្ញាស្មារតីកម្រិតខ្ពស់របស់ព្រះអង្គ ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ថាអាពាហ៍ពិពាហ៍ គឺជាដំណើរបណ្តោះអាសន្នក្នុងខណៈពេលដែល

ការត្រាស់ដឹងសម្មាសម្ពោធិញាណគ្មានទីបំផុតនោះទេ និងជាប្រយោជន៍ដល់**មនុស្សជាតិទាំងអស់**។

ភាពពិតសំខាន់មួយទៀត គឺព្រះពុទ្ធទ្រង់បានដឹងថាមហេសីនិងបុត្រារបស់ព្រះអង្គនឹងមិនសុគតដោយអត់អាហារ ដោយសារអវត្តមានរបស់ព្រះអង្គនោះទេ។ ក្នុងសម័យពុទ្ធកាល គេចាត់ទុកថាជាការធម្មតា និងគួរឱ្យគោរពកោតសរសើរ ចំពោះបុរសដែលមានវ័យនៅក្មេងគេចចេញពីជីវិតឃរាវាស។ សមាជិកដទៃទៀតនៃរាជវង្សានុវង្ស នឹងថែរក្សាអ្នកនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ដោយក្តីពេញចិត្ត។ ពេលព្រះអង្គបានត្រាស់ដឹង ព្រះអង្គអាចផ្តល់ឱ្យពួកគេនូវអ្វីៗដែលបិតាដទៃទៀតមិនអាចឱ្យបាន ពោលគឺការរួចចាកពីទាសភាពនៃឧបាទាន។

## ១២. សេចក្ដីសង្ខេប

អាពាហ៍ពិពាហ៍ គឺជាភាពជាដៃគូរបស់បុគ្គលពីររូប ហើយភាពជាដៃគូនេះត្រូវបានគេធ្វើឱ្យមានខ្លឹមសារ និងធ្វើឱ្យប្រសើរឡើងពេលវាអនុញ្ញាតិឱ្យបុគ្គលិកលក្ខណៈភាព ដែលជាប់ពាក់ព័ន្ធលូតលាស់ឡើង។ អាពាហ៍ពិពាហ៍ជាច្រើនបរាជ័យ ពីព្រោះដៃគូម្នាក់ព្យាយាម **"លេបសំដី"** ដៃគូម្នាក់ទៀត ឬពេលម្នាក់ទាមទារ ឱ្យមានសេរីភាពទាំងស្រុងពេញលេញ។ បើតាមព្រះពុទ្ធសាសនា អាពាហ៍ពិពាហ៍មានន័យថា ការយល់ដឹង និងគោរពជំនឿ និងការសម្ងាត់របស់ដៃគូម្នាក់ៗ។ អាពាហ៍ពិពាហ៍មានជោគជ័យ គឺជាផ្លូវពីរ "ទួល, រលាក់ " វាពិបាកប៉ុន្តែវាជាផ្លូវដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក។

យុវជនក្មេងៗនៅក្នុងប្រទេសនេះ និងទីកន្លែងដទៃទៀត តែងតែគិតថា "គំនិតបូរាណ" មិនទាក់ទងនិងសង្គមសម័យទំនើបនោះទេ។ ពួកគេគួរតែនឹកឃើញថា មានសច្ចៈជាអមតៈមួយចំនួនដែលមិនអាចក្លាយជាហួសសម័យបានទេ។ អ្វីដែលពិតអំឡុងសម័យពុទ្ធកាល ក៏នៅតែពិត នាពេលបច្ចុប្បន្ននេះ។

គំនិតសម័យទំនើបស្អីគេនោះ ដែលយើងទទួលបានតាមរយៈ កម្ម-វិធីទូរទស្សន៏ស្រស់បំព្រងបំផុត មិនបង្ហាញពីរបៀបដែលមនុស្សសមរម្យភាគច្រើនបំផុតនៅលោកខាងលិចគិតធ្វើនោះទេ។ មាន "ចំនួនភាគច្រើន

នៅនឹងថ្កល់"    នៃគូស្រករសមរម្យដ៏ធំធេងមួយដែលយកចិត្តទុកដាក់ខ្លាំងខាងសាសនានិង"អភិរក្សនិយម"អំពីអាពាហ៍ពិពាហ៍ដូចគូស្រករនៅអាស៊ី។ ពួកគេមិនប្រព្រឹត្តអត្តចរិត   ដែលបណ្តាញផ្សព្វផ្សាយពតិមានបានរៀបរាប់ប្រាប់ពួកគេនោះទេ។ មិនមែនប្រជាជនទាំងអស់នៅលោកខាងលិចរត់ទៅធ្វើការលែងលះ ឬពន្លួតកូនបន្ទាប់ពីជម្លោះ ឬការប្រកែកគ្នាខ្លាំងលើកដំបូងរបស់ពួកគេនោះទេ។

មនុស្សគួរជាទីពេញចិត្តនៅទូទាំងពិភពលោក គឺសុទ្ធតែដូចគ្នាទាំងអស់   ពួកគេមិនអាត្មានិយមហើយពួកគេយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះមនុស្សដែលគេស្រឡាញ់។ ពួកគេធ្វើពលិកម្មយ៉ាងធំសម្បើម និងអភិវឌ្ឍសេចក្តីស្រឡាញ់និងការយល់ដឹង    ដើម្បីធានាឱ្យអាពាហ៍ពិពាហ៍    មានស្ថេរភាព និងមានសុភមង្គល។ ដូច្នេះ បើលោកអ្នកចង់ធ្វើតាមលោកខាងលិច ចូរធ្វើតាម "ចំនួនភាគច្រើននៅនឹងថ្កល់" ពោលគឺចំនួនភាគច្រើននេះមិនខុសពីអ្នកជិតខាងសមរម្យ ដែលរស់នៅជិតខាងលោកអ្នកនោះទេ។

យុវជនក្មេងៗ គប្បីត្រូវតែស្តាប់ចាស់ទុំរបស់ពួកគេផងដែរ ពីព្រោះការយល់ដឹងរបស់ពួកគេអំពីជីវិតអាពាហ៍ពិពាហ៍ គឺមិនដល់កំណត់នោះទេ។ ពួកគេមិនគប្បីធ្វើការសន្និដ្ឋានដោយប្រញាប់ប្រញាល់  ទាក់ទងនឹងអាពាហ៍ពិពាហ៍និងការលែងលះនោះទេ។  ពួកគេត្រូវតែមានខន្តី  សេចក្តីអត់ធន់សន្តោស សេចក្តីអត់អោនត្រាប្រណី និងការយល់ចិត្តគ្នាទៅវិញទៅមកឱ្យ

បានច្រើន។ ពុំនោះទេ ជីវិតរបស់ពួកគេអាចក្លាយទៅជាមិនសប្បាយរីករាយខ្លាំង និងមិនដាច់ស្រេច។ **ខន្តី សន្តោស និងការយល់ចិត្តគ្នា** ជាវិធីសំខាន់ត្រូវសមាទាន និងយកទៅប្រតិបត្តិដោយគូស្រកររៀបអាពាហ៍ពិពាហ៍ហើយទាំងអស់។

អារម្មណ៍នៃសុវត្ថិភាពនិងការសប្បាយរីករាយ បានមកពីការយល់ដឹងទាំងសងខាង ដែលជា **អាថ៌កំបាំងនៃជីវិតអាពាហ៍ពិពាហ៍ប្រកបដោយសុភមង្គល**។

# បរិសិដ្ឋ

# មាតាដែលមានទឹកចិត្តសប្បុរស (ប្រេមវន្តមាតា)

*នៅក្នុងជាតក ព្រះពោធិសត្វ សោណនន្ទៈច្រៀងរៀបរាប់នូវគុណធម៌របស់មាតា ជាបទគាថាដូចខាងក្រោម៖*

*មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក ចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក ។*

*មាតាកាលប្រាថ្នាចង់បានផ្ទៃគឺកូន រមែងនមស្ការទេវតាសួរនក្ខត្តប្ញក្សទាំងឡាយផង សួររដូវនឹងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌ស៊ប់ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃដោយហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **សុហទា** (មានដួងហ្ឫទ័យល្អ) ។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយប្រសូត្របុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា **ជនយន្តី** ផង **ជនេត្តី** ផង (អ្នកបង្កើតកូន) ។ មាតាញុំាងកូន ដែលកំពុងយំឲ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេរផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **តោសេន្តី** (អ្នកញុំាងកូនឲ្យត្រេកអរ) ។ តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារក ដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់នឹងកំដៅថ្ងៃដ៏ពន្លឹក*

*ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា **ចោរសេន្ទី** (អ្នកចិញ្ចឹមកូន) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាក៏គ្រប់គ្រង ទ្រព្យទាំងពីរចំណែកដើម្បីកូននោះ (ដោយបំណងថា ទ្រព្យនេះ) ត្រូវមានដល់កូនរបស់យើង ។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូនដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាថក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ ។ កាលបើកូនមានវ័យចំរើនឡើងហើយ មាតា (បានដឹង) កូននោះប្រមាថក្នុងប្រពន្ធរបស់អ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ ។ សត្វដែលមាតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបំរើមាតា ប្រព្រឹត្តខុសក្នុងមាតា នោះតែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាកព្រោះមិនបំរើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាកព្រោះមិនបំរើបិតា ។ បណ្ឌិតបំរើមាតា គប្បីបាននូវសុខនុះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល ។ បណ្ឌិតបំរើបិតា គប្បីបាននូវសុខនុះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល ។ ទាន១ វាចាជាទីស្រឡាញ់១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុងជេដ្ឋាបចាយនធម៌នោះៗតាមសមគួរ១ ។*

*សង្គហធម៌ទាំង ៤ នុះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្ជៅនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំងនុះមិនមានទេ មាតាមិនត្រូវបាននូវសេចក្ដីរាប់អាននឹងការបូជា ព្រោះហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្ដីរាប់អាននឹងការបូជា ព្រោះហេតុនៃកូន ។ ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំងនុះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះរមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ។ មាតាបិតាជាអ្នកអនុគ្រោះដល់សត្វគឺបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតនឹងការលាងជើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបំរើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។*

*(ដកស្រង់ចេញពី សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក,*
*សត្តតិនិបាត សោណនន្ទជាតកទី២, ទំព័រ ៩៣-៩៦)*

# ក្រិត្យក្រមសីលធម៌

## ១. ក្រិត្យក្រមសីលធម៌ និងក្រិត្យក្រមសង្គម

ជាទូទៅ ធាតុសំខាន់បំផុតនៃបដិរូបការព្រះពុទ្ធសាសនា គឺក្រិត្យក្រមសីលធមិនិងសង្គម។ ក្រិត្យក្រមសីលធមិនោះដែលកាន់ខាងដោយខ្លួនវា គឺជាសុក្រិតភាពមួយក្នុងចំណោមសុក្រិតភាពបំផុត ដែលពិភពលោកធ្លាប់បានដឹង។ ត្រង់ចំណុចនេះ កសិណសាក្សីទាំងអស់ពីភាគីជាសត្រូវ និងភាគីជាមិត្តបានព្រមព្រៀងគ្នា អាចមានទស្សនវិទូ គ្រូបង្រៀនខាងសាសនា អ្នកបរមត្ថវិជ្ជាប៉ិនប្រសប់ និងមានអ្នកជជែកដេញដោលគ្នាក៏ប៉ុន្តែតើយើងនឹងរកឃើញវត្ថុតំណាងនៃសេចក្តីស្រឡាញ់នៅកន្លែងណា គឺសេចក្តីស្រឡាញ់ដែលមិនស្គាល់ការបែងចែកវណ្ណៈ និងគោលជំនឿ ឬពណ៌សម្បុរ សេចក្តីស្រឡាញ់ដែលបង្ហូរចេញនូវព្រំដែនមនុស្សជាតិ ដែលអោបសត្វទាំងអស់ឱ្យនៅក្នុងដំណើររបស់វា សេចក្តីស្រឡាញ់ដែលតំណាងសេចក្តីពិតនៃ**មេត្រី** និង**អហឹង្សាសកល**។

(**សាស្ត្រាចារ្យ ម៉ាក ម្វល័រ** អ្នកប្រាជ្ញពុទ្ធសាសនាជាតិអាឡឺម៉ង់)

## ២. សីលធម៌ផ្អែកលើសេរីភាព

សីលធមិព្រះពុទ្ធសាសនា គឺផ្អែកលើសេរីភាព ឧទាហរណ៏លើការអភិវឌ្ឍរបស់បុគ្គល។ ហេតុនេះ វាមានទំនាក់ទំនងគ្នា។ តាមសភាវៈ

ពិត មិនអាចមានគោលការណ៍ត្រឹមត្រូវតាមសីលធម៌ណាមួយទេ ប្រសិនបើមានការបង្ខិតបង្ខំ ឬការបញ្ជាពីអ្នកតំណាងខាងក្រៅខ្លួនរបស់យើងផ្ទាល់។

(**អនគរិកៈ ធ. ធម្មបាលៈ** អ្នកប្រាជ្ញពុទ្ធសាសនាជាតិអាឡឺម៉ង់)

## ៣. ពុទ្ធិនិងសីលធម៌

នៅក្នុងព្រះពុទ្ធសាសនា មិនអាចមានសីលធម៌ពិតទេ បើគ្មានពុទ្ធិ (ចំណេះដឹង) និងមិនមានពុទ្ធិពិតទេ បើគ្មានសីលធម៌ ទាំងពីរនេះជាប់ទាក់ទិនគ្នាយ៉ាងជិតស្និទ្ធ ដូចកំដៅនិងពន្លឺនៅក្នុងអណ្តាតភ្លើង។ អ្វីដែលរួមជាមួយ "ពោធិ" គឺមិនមែនប្រាជ្ញាវាងវៃ ការត្រាស់ដឹងនោះទេ ក៏ប៉ុន្តែគឺមនុស្សជាតិ (ភាពជាមនុស្ស)។ ព្រលឹងនៃឧត្តមភាពផ្នែកសីលធម៌ គឺជាខ្លឹមនៃ "ពោធិ"។

(ភិក្ខុ **ធម្មបាល** អ្នកប្រាជ្ញពុទ្ធសាសនាជាតិហូឡង់)